# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ លេខ ១០ ខែតុលា ព.ស. ២៤៩៩ គ.ស. ១៩៥៦

CENTRE ... BIBLIOTHEQUE
inventaire 8-63

ក-២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

— ចិត្តតាក់តែងរូប ............ យុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ ...... ៩០៣
— កុរុធម៌ ..................... ព្រះទេពសត្ថា កឹម-តូរ ....... ៩១១
— កម្មបថកថា ................ ព្រះមហា ម្យៀច-ង៍យ ........ ៩២១

*ផ្នែកអក្សរសាស្ត្រ*

— ប្រវត្តិការណ៍ខ្មែរបុរាណ ......... លោក មាស-ឆាន់ ប្រែ....... ៩៣១
— អក្សរសាស្ត្រខ្មែរសង្ខេប (តមក) .... លោក ប៉ាយ-ប៊ុក .......... ៩៣៤
— ពេជ្រព្រះរាជា (តមក) ........ លោក ស៊ុន-ហ៊ាន ប្រែ ..... ៩៤៤
— រឿងសាមកុក (តមក) ....... ឧកញ៉ា នូ-កន .......... ៩៥៥
— រឿងបល្ល័ង្កទិព្យ (តមក) ...... លោក ប៉ាយ-ប៊ុក ប្រែ....... ៩៦៥
— ការដាំដើមឈើយកផ្លែ ........... យុនអគ្គកោវិទ ជា-យូរ ប្រែ .... ៩៧២

*កំណត់នឹងប្រវត្តិការណ៍*

— ពិធីបុណ្យកតញ្ញូកតវេទិតានៃក្រុមសិស្ស
ធ្វើចំពោះសម្ដេចព្រះធម្មលិខិត ល្វី-ឯម
វត្តលង្កា ................ ព្រះមហា សម-សុទ ........ ៩៨២

មួយឆ្នាំមាន ១២ សៀវភៅ - ដំឡៃជាវ ២៣០ រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

**PARTIE RELIGIEUSE:** *Page*

— Formation des êtres et du monde . . . . . . . . . . *par M. BOU-PO . . . . . 903*

— Kurudharma . . . . . . . . *par le Vén. . . KEM-TO . 911*

— Kammapathakatha . . . . *par le Vén. , MEACH-CHEY 921*

**PARTIE LITTÉRAIRE:**

— Chronique de l'Antiquité Khmère . . . . . . . . *par M. MEAS-CHHAN . . 931*

— Littérature Khmère résumée (suite) . . . . . . . . . . *par M. RAY-BUC . . . . 934*

— Conte "Le Diamant de Raja" (suite) . . . . . . . . . . *Traduit par M. SIN-HEAN. 944*

— Histoire du Samkok (suite) . . *Traduit par M. NOU-KAN. 955*

— Les trente deux récits du Trône (suite) . . . . . . . *Traduit par M. RAY-BUC . 965*

— La culture des arbres fruitiers . . . . . . . . . . . . *Traduit par M. CHEA-YOU . . 972*

**NOTES ET CHRONIQUES:**

— Fête organisée par les disciples en l'honneur de Samdech Preah Dhammalikheta Louis-Em . . . . . . . . . *par le Vénérable SAM-SOK . 982*

Prix d'abonnement annuel (comprenant 12 numéros) 230$00

## ផ្នែកសាសនា

### ចិត្តតាក់តែងរូប[១]

# ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

### រៀបរៀង

ចិត្តជាអរូបធាតុ ជាធម្មជាតចំឡែកអស្ចារ្យណាស់ បើទុកជាចិត្តមានអវិជ្ជា គឺការមិនចេះមិនដឹងក៏ដោយ ក៏គង់ចិត្តនោះអាចតាក់តែងនូវរូបបានយ៉ាងច្រើនលើសលុប ទាល់តែរាប់មិនអស់ ។ បណ្ដាវត្ថុទាំងក្នុង ដូចរថយន្ត, រថភ្លើង, កប៉ាល់ចម្បាំង, វិទ្យុ, ផ្ទះធំ ៗ ខ្ពស់ច្រើនជាន់ ៗ ល ៗ ទាំងអស់នេះកើតមានឡើងប្រាកដជារូបរាងប្រើប្រាស់បានផលប្រយោជន៍ប្លែក ៗ ពីគ្នា ក៏មកតែពីចិត្តជាអ្នកគិតប្រឌិតតាក់តែងឡើង គឺចិត្តបញ្ចេញស្រមោលជាធាតុគិតមុនរូបហើយ ទើបកើតផលជាធាតុដឹងខាងក្រោយ ។ ធាតុដឹងដែលកើតប្រាកដឡើង ចាត់ជាលោកិយ-វិជ្ជា (គិតរូបចាំគូរ) ។ កាលចិត្តមានវិជ្ជាហើយ ទើបប្រើកាយឲ្យនាំធាតុផ្សេង ៗ ដ៏ជារូបធាតុមកផ្សំផ្គុំរួមគ្នាឡើង សម្រេចជារូបសព្វវត្ថុផ្សេង ៗ ។ រូបនោះល្អថ្លៃថ្លាខ្លះ អាក្រក់ខ្លះ ស្រេចតែការចេះដឹងនិងសេចក្ដីអង់អាចរបស់ចិត្ត ។ ជនដែលមានចិត្តប្រកបដោយធាតុចេះដឹងបែបនេះ ហៅថា អ្នកឈ្លាសវៃ ឬអ្នកប៉ិនប្រសប់ ។ រឿងនេះ យើងអាចពិសោធឲ្យ

---

១ អធិប្បាយតាមន័យនៃព្រះអភិធម្មត្ថសង្គហៈ ក្នុងចិត្តសង្គហវិភាគ បរិច្ឆេទទី ១ ។

ឃើញច្បាស់បានថា ចិត្តដែលមានធាតុបេះដូងនោះ អាចបាត់បែងកសាង
រូបយ៉ាងល្អស្រស់ថ្លៃថ្លាបានត្រឹមណា ខ្ញុំជឿទុកជាមុនថាលោកអ្នកទាំង
ឡាយគង់ធ្លាប់បានចូលទៅក្នុងវិហារព្រះកែវមរកត ដែលតាំងនៅទិស
ខាងត្បូងផ្ទាល់ព្រះបរមរាជវាំងចតុមុខក្រុងភ្នំពេញដែរ ។ រូបផ្សេងៗ
ដែលប្រាកដដល់ចក្ខុនៃអស់លោកអ្នក នៅវេលាចូលទៅក្នុងព្រះវិហារ
នោះ ជារូបដែលល្អស្រស់ឆើតឆាយត្រឹមណា ៗ អស់លោកអ្នកឃើញ
ហើយមុខជាមិនបដិសេធថា រូបទាំងអស់ក្នុងទីនោះជារបស់មិនគួរមើល
ឬមិនគួរសរសើរទេ សឹងតែយល់ឃើញត្រូវគ្នាថា វត្ថុមួយៗជារបស់
ចំឡែកអស្ចារ្យណាស់ ដូចយ៉ាងតួព្រះវិហារដែលក្រាលប្រាក់សុទ្ធជា
ដើម ៗ កាលបើឃើញហើយៗ ស្រាវជ្រាវរកហេតុផលទៅ គង់
ឃើញថា វត្ថុដែលមើលឃើញទាំងអស់នោះ សុទ្ធតែជាផល ៗ ផល
ទាំងនេះកើតឡើងអំពីអ្វីជាហេតុ? ផលទាំងនេះកើតឡើងពីកម្មជាហេតុ ។
ចុះកម្មនោះប្រែថាម៉េច? ប្រែថា ការធ្វើ ។ ចុះអ្នកណាធ្វើ? មនុស្ស
ជាម្ចាស់ធ្វើ ។ អ្នកណាប្រើឲ្យធ្វើ? ចិត្តនៃមនុស្សនោះឯងប្រើឲ្យធ្វើ ។
ប៉ុន្តែអស់លោកអ្នកដែលមានចិត្តប្រកបដោយការបេះដូងពិតប្រាកដហើយ
មុខជាឆ្លើយថា ចិត្តដែលមានលោកិយវិជ្ជាជាគុណសម្បត្តិប្រើឲ្យកាយធ្វើ
វត្ថុទាំងនោះឡើង ៗ នេះចម្លើយដ៏ត្រឹមត្រូវតាមសេចក្តីពិតរបស់ហេតុ
ផល ៗ កាយនោះជាធាតុឥតដឹងអ្វីបន្តិចបន្តួចសោះ ធ្វើអ្វីខ្លួនឯងក៏ឥត
ដឹង ៗ ចិត្តមានអំណាចលើកាយ មានសេចក្តីបេះដូងជាគុណសម្បត្តិ
ទើបអាចបង្គាប់បញ្ជាកាយឲ្យធ្វើវត្ថុនោះៗបាន ៗ ប្រសិនបើចិត្តគ្រាន់

តែមានអំណាចប្រើកាយប៉ុណ្ណោះ តែមិនបេះមិនជីងទេ ចិត្តក៏ទីងប្រើកាយឲ្យធ្វើតែនោះមិនបានជាដាច់ខាត ដូចចិត្តប្រើដៃឲ្យសរសេរសំបុត្រ បើចិត្តមិនបេះអក្សរ ១ តួសោះ តើដៃសរសេរកើតដែរឬទេ? ច្បាស់ជាមិនកើតសោះឡើយ ។ នេះជាឧទាហរណ៍របស់ចិត្តល្ងង់ខ្លៅ ជាចិត្តមានតែអំណាចម្យ៉ាង ជាចិត្តឥតចំណេះវិជ្ជា ។ ឧទាហរណ៍មួយទៀត ដូចរូបគំនូរនៅតាមថែវជុំវិញព្រះវិហារ ជាគំនូរមានបែបភាពប្លែក ៗ គ្នា ល្អខ្លះ អាក្រក់ខ្លះ ។ ចិត្តត្រូវមានវិជ្ជាក្នុងការគូរ ទើបអាចប្រើដៃឲ្យគូរជារូបយ៉ាងនោះ ៗ ទៅកើត ។ ហេតុដូច្នោះចិត្តត្រូវតែមានគុណសម្បត្តិជាច្រើនប្រការ ទើបទីងអាចតាក់តែងរូបឲ្យល្អទៅបាន ។

ចិត្តអ្នកតាក់តែងរូបនោះត្រូវមានគុណសម្បត្តិ ៤ យ៉ាងជាខាងដើមគឺ

១ – ត្រូវមានឆន្ទៈសេចក្តីស្រឡាញ់ពេញចិត្តក្នុងកិច្ចការដែលធ្វើនោះ,

២ – ត្រូវមានសេចក្តីព្យាយាមធ្វើកិច្ចនោះៗ,

៣ – ត្រូវយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ៗ,

៤ – ត្រូវពិចារណារកហេតុផលក្នុងកិច្ចនោះ ៗ ។

(ឥទ្ធិបាទ ៤ គឺ ឆន្ទៈ, វីរិយៈ, ចិត្តៈ, វិមំសា)

ក្រៅពីគុណសម្បត្តិ ៤ យ៉ាងនេះ នៅមានគុណសម្បត្តិផ្សេង ៗ ទៀតជាច្រើនប្រការណាស់ មិនអាចយកមកពណ៌នាក្នុងទីនេះឲ្យបប់បានទេ ។ សេចក្តីខាងដើមនេះបង្អួលឲ្យឃើញថា ចិត្តជាធម្មជាតិដ៏ចម្លែកអស្ចារ្យ ។ ចិត្តជាអរូបធាតុ ប៉ុន្តែមានគុណសម្បត្តិច្រើនប្រការណាស់ ។ ចិត្តទីងបញ្ចេញស្រមោលជាធាតុគិតបានប៉ុន្មាន ៗ, ។ ធាតុគិតនោះកើតឡើង

ហើយរលត់ទៅវិញជាធម្មតា ។ ប៉ុន្តែធាតុបេះដូងជាផលរបស់ធាតុគិត តែងមាននៅជាគុណសម្បត្តិជាប់ជានិច្ច មិនបានសាបសូន្យបាត់ទៅណាទេ ។ ចិត្តរើសប្រមូលយកធាតុបេះដូង ឬវិជ្ជាទាំងអស់នោះទុកឲ្យគង់នៅបាន ។ ចិត្តដទៃ ៗ ដែលគ្មានវិជ្ជាបែបនោះទេ មិនអាចនឹងបែងចែកឬឆក់ដណ្តើមយកវិជ្ជារបស់ចិត្តដែលមានវិជ្ជានោះ ៗ មកដាក់ក្នុងខ្លួនបានឡើយ ។ វិជ្ជាផ្សេង ៗ ប្រៀបដូចទ្រព្យមានកម្មសិទ្ធិ, ចិត្តប្រើប្រាស់មិនចេះអស់, សមដូចសុភាសិតដែលលោកជាចិន្តកវីពោលទុកថា “ មានវិជ្ជាដូចមានទ្រព្យកប់មុឺនសែន ទោះធ្លាក់ទីចង្អៀតណែនក៏មិនថប់ ព្រោះចិត្តមានវិជ្ជាប៉ុនប្រសប់ អាចត្រឡប់កើនខ្លួនរួចពីទុក្ខទោស ” ។ សូម្បីសម្តេចព្រះបរមសាស្តា ក៏ទ្រង់ត្រាស់សរសើរគុណរបស់វិជ្ជាលោកិយ ទុកក្នុងមង្គលសូត្រថា “ សិល្បៈជាមង្គលដ៏ឧត្តម ” ។

ចិត្តមានវិជ្ជាយ៉ាងនេះហើយ អាចតាក់តែងរូបប៉ែកខាងល្អឲ្យកើតឡើងបាន ដើម្បីថែរក្សាលោក គឺកាយ, កាយជាធាតុ ៤ ដែលតែងសាបសូន្យបាត់បង់ទៅវិញជាធម្មតា ។ ចិត្តអ្នកគ្រប់គ្រង ត្រូវគិតទំនុកបំរុងរូបកាយដោយបាយចំណីទឹកផ្លែឈើផ្សេង ៗ ត្រូវរកសំពត់អាវបិទបាំងកាយ ការពារក្តៅត្រជាក់ មូសសុចស្រួយស្រោង ទឹងត្រូវធ្វើទីលំនៅទុកសម្រាប់ឲ្យកាយសំណាក់អាស្រ័យ ។ កាលបើកាយមានអាពាធឈឺចាប់ ចិត្តក៏ត្រូវតែស្វះស្វែងរកពេទ្យរកថ្នាំសង្កូវបំបាត់រោគនោះ ៗ ដើម្បីឲ្យកាយរស់នៅបានយឺនយូរតទៅទៀត ។ ចិត្តទុកជាមេការ ឬជាមេជាងយ៉ាងសំខាន់ អាស្រ័យនៅក្នុងរូបកាយហើយទទួលនាទីជា

អ្នកគ្រប់គ្រងកាយថែមទៀត, ប្រើកាយ, ទំនុកបំរុងកាយ ជាអ្នកទទួលខុសត្រូវក្នុងមុខងារគ្រប់ប្រការ ។ ប៉ុន្តែកិច្ចការទាំងអស់ដែលជាខាងក្រៅ ចិត្តជាអ្នកបង្គាប់ឲ្យកាយធ្វើ ទើបកាយធ្វើបាន ។ ចំណែកការងារដទៃផ្សេងទៀត ត្រូវអវយវៈខាងក្នុងកាយបាត់គ្នាធ្វើឡើងក៏មាន ដូចចិត្តប្រើកាយឲ្យបរិភោគអាហារហើយ, អាហារកន្ទ្វងចូលទៅក្នុងក្រពះស៊ប់ហើយ, ទឹករំលាយអាហារ គឺគ្រឿងធាតុក៏ធ្វើនាទីរំលាយអាហារ រហូតដល់កើតទៅជាលោហិត, បេះដូងមាននាទីបញ្ជូនលោហិតទៅទំនុកបម្រុងអវយវៈពេញពងកាយ, ចិត្តមិនបានបង្គាប់ឲ្យធ្វើទេ, អវយវៈខាងក្នុងទើបជារបស់ដែលនៅក្រៅអំណាចនៃចិត្ត, ចំណែកការដកដង្ហើមចូលចេញដែលចិត្តបង្គាប់បានក៏មានដែរ ដូចចិត្តត្រូវការឲ្យដកដង្ហើមញាប់ក៏បានឲ្យដកដង្ហើមរង្វើលក៏បានតាមប្រាថ្នា ។ ប៉ុន្តែតាមប្រក្រតីរបស់ចិត្តមិនបានបង្គាប់បញ្ជាក្នុងការដកដង្ហើមទេ ត្រូវកាយធ្វើនាទីរបស់ខ្លួនឯង ។

សកលកាយនេះ សូម្បីជាធាតុ ៤ ក៏ពិតមែនហើយ ប៉ុន្តែជាសរីរយន្តដែលវិចិត្រពិស្ដារក្រៃលែងណាស់ ឥតវត្ថុដទៃដែលជាគ្រឿងប្រើប្រាស់ដ៏សំខាន់ក្រៃលែងជាងកាយឡើយ ។ វត្ថុផ្សេង ៗ ដែលចិត្តតុបតែងឡើងឲ្យជារបស់ដ៏អស្ចារ្យយ៉ាងណាក៏ដោយ ក៏នៅតែមិនទាន់អស្ចារ្យឬមានគុណមានដម្លៃក្រៃលែងជាងកាយឡើយ ។ សម្បត្តិខាងក្រៅជាវត្ថុដែលចិត្តនិយមថា មានដម្លៃច្រើន ទោះបីកាត់ថ្លៃវត្ថុនោះដល់ម៉ឺនសែនក្តី បើប្រៀបធៀបនឹងកាយហើយ ឃើញថាកាយជាវត្ថុមានដម្លៃច្រើនលើសលុបជាងវត្ថុនោះ ៗ យ៉ាងឆ្ងាយណាស់ ព្រោះហេតុអ្វី ព្រោះ

កាយជាទីសំណាក់អាស្រ័យរបស់ចិត្ត ជាគ្រឿងប្រើប្រាស់របស់ចិត្ត ដែលចិត្តត្រូវតែថ្នាក់ថ្នមថែរក្សាឲ្យយ៉ាងត្រូវលង់ជាងវត្ថុដទៃ ៗ ទាំងអស់ ៗ ទ្រព្យសម្បត្តិខាងក្រៅដែលចិត្តនិយមថាជារបស់ប្រសើរ ជារបស់ដែលនឹងឲ្យផលដល់ខ្លួនឲ្យបានសុខ តាមសំដីនិយាយគ្នាថា ប្រាក់ ឬ ធនប័ត្រនោះ ចិត្តប្រើឲ្យកាយធ្វើកិច្ចការហើយបានវត្ថុទាំងនោះមកទុកជាសម្បត្តិចិត្តរមែងរង្វេងទៅគោរពបូជាវត្ថុនោះ ៗ ដោយរីករាយយ៉ាងខ្លាំង ប៉ុន្តែស្រឡាញ់វត្ថុទាំងនោះតើដើម្បីប្រយោជន៍អ្វី? បើឆ្លើយយ៉ាងត្រឹម ៗ មុខជាឆ្លើយថា ដើម្បីយកមកចាត់ចែងអាហារខ្លះ ដើម្បីធ្វើ ឬ ជួសជុលទីលំនៅខ្លះ ដើម្បីទិញសម្ពត់អាវនឹងគ្រឿងតែងខ្លួនខ្លះ ដើម្បីទិញថ្នាំកែរោគដែលកើតជាប់នឹងកាយខ្លះ ។ រឿងនេះបង្អួលឲ្យឃើញថា សុទ្ធតែជារឿងទំនុកបម្រុងកាយទាំងអស់ ។ ចិត្តដែលអាស្រ័យនៅក្នុងកាយរមែងដឹងថាកាយជាសម្បត្តិយ៉ាងឯករបស់ខ្លួន ។ ចិត្តសំគាល់ថា សរីរៈចំណែកតូច ៗ ដូចភ្នែក, ច្រមុះ, មាត់, ធ្មេញ, ក្រចក ទាំងនេះក្នុងមួយ ៗ ជារបស់ល្អប្រពៃ ចិត្តចង់ឲ្យរឹតតែល្អខ្លាំងឡើងទៀត ទើបស្វែងរកគ្រឿងប្រដាប់មកតាក់តែងពងកាយ ឲ្យល្អស្រស់រុងរឿងប្រិនឡើង ដូចការ, ទំហូ, ខ្សែក, ចិញ្ចៀន វ៉ែនតាជាដើម ។ ចិត្តត្រេកអរនឹងកាយ ប្រើកាយឲ្យទំពាក់តែង ។ ឯកាយវិញមិនដឹងខ្លួនថាត្រូវគេប្រើទេ ទាំងសរីរៈចំណែកនោះ ៗ ដូចត្រចៀកក៏មិនដឹងថាត្រូវពាក់ទំហូ, ម្រាមដៃក៏មិនដឹងថាត្រូវពាក់ចិញ្ចៀន, កមិនដឹងថាត្រូវពាក់ខ្សែក, ចង្កេះមិនដឹងថាត្រូវពាក់ខ្សែក្រវាត់, មិនតែប៉ុណ្ណោះ ចិត្តនៅតែចង់ឲ្យកាយល្អលើសពីនោះទៅទៀត

ទើបបេះតែគិតតុបតែងឲ្យតែល្អខ្លាំងឡើង ដូចធ្វើភ្នែកឲ្យមានវែនតា, គូរចិញ្ចើមឲ្យខ្មៅហើយវែង, លាបបបូរមាត់ទឹកក្រចកឲ្យក្រហម កាត់សក់ឲ្យសមរម្យ កាត់ពោមភ្នែកឲ្យធំ រឹតបង្កេះឲ្យមូល ៗ នៅមានវិធីតុបតែងកាយដទៃទៀតជាយ៉ាងច្រើន ដែលចិត្តអ្នកប៉ុនប្រសប់គិតរបៀបតុបតែងកាយ ចំណាយប្រាក់ទិញគ្រឿងប្រដាប់សម្រាប់តាក់តែងកាយ លះបង់ពេលវេលាព្យាយាមតែងកាយ ៗ អវយវៈគ្រប់ចំណែកដូចជាកទឹងសក់មិនបានដឹងសោះថា ត្រូវពាក់ខ្សែប្តូរត្រូវកាត់ ៗ រឿងនេះ បើយើងពិនិត្យឲ្យសព្វគ្រប់ទៅហើយ គាបឃើញបានយ៉ាងជាក់ច្បាស់ថា កាយនោះជាធម្មជាតឥតដឹងអ្វីសោះមែន ៗ ៗ មានតែចិត្តទេទើបដឹង ប៉ុន្តែសូម្បីដូច្នោះ ចិត្តក៏នៅតែដឹងមិនត្រង់ មិនត្រូវតាមសភាវៈពិត ៗ ព្រោះចិត្តមិនដឹងថា ការតាក់តែងកាយនេះប្រព្រឹត្តទៅដើម្បីសន្សំកងកិលេសទឹងកងទុក្ខឲ្យច្រើនឡើង ៗ ចិត្តនេះវង្វេងភ្លេតភ្លើនស្រវឹងស្រឡាញ់រូបរាងកាយដូច្នោះ មិនបានទឹករលឹកដល់សេចក្តីប្រែប្រួលរបស់រាងកាយសោះ ៗ កាយចាស់ទ្រុឌទ្រោមទៅគ្រប់ខណៈ ចិត្តក៏មិនព្រមទទួលដឹងថាកាយចាស់ សំគាល់ថានៅក្មេងនៅក្រមុំកំលោះ ៗ ចិត្តស្ងឹងវង្វេងស្រវឹង សំឡឹងយកភេទផ្ទុយគ្នាទៅវិញ ៗ ចិត្តបែបនេះរមែងនិយមការគ្រប់គ្រងជីវិតផ្ទុយស្រឡះ ប្រទះបានតែសាមិសសុខទឹងសាមិសទុក្ខលាយឡំគ្នាជាដរាបទៅ ព្រោះថាកាមគុណ មានកាមសុខជាផល, កាមទោស មានកាមទុក្ខជាផល ៗ ជីវិតបែបនេះមិនបានទទួលសន្តិសុខដ៏ពិតប្រាកដទេ ប៉ុន្តែ របស់ទាំងនេះ កាលបើមានគុណ

ជាអនន្តរហើយ ក៏រមែងមានទោសជាមហន្តដែរ ។ កិច្ចទាំងនេះ ជាវិធីការគ្រប់គ្រងជីវិតរបស់ចិត្ត ដែលប្រកបដោយអវិជ្ជារង្វេងស្រឡាញ់ពនកាយ សំគាល់ថាពងកាយល្អ, ថាជាខ្លួនប្រាណ ។ ចំណែកចិត្តដែលប្រកបដោយវិជ្ជាវិញ បានពិនិត្យពិចារណាមើលសកលកាយទាំងខាងក្រៅទាំងខាងក្នុង ឃើញថាមិនល្អ គ្រាន់តែជាធាតុ ៤ ស្មើគ្នា មិនជារូបស្រីឬរូបប្រុសទេ ។ ចិត្តដែលឃើញយ៉ាងនេះទើបមិនត្រូវការរូបកាយដទៃ ៗ ទៀត ព្រោះមានកាយតែមួយប៉ុណ្ណោះ ក៏ល្មមប្រើការបានគ្រប់គ្រាន់ហើយ ។ ចិត្តដែលមានសេចក្ដីល្មមគ្រប់គ្រាន់ ទើបឈ្មោះថាជាអ្នកមានទ្រព្យស្ដុកស្ដម្ភ មិនទ័លក្រ មិនខ្វះខាត ។ ចិត្តដែលដឹងស្គាល់កាយច្បាស់លាស់តាមសភាវៈពិត រមែងជាចិត្តថ្លៃថ្នូរ ជាចិត្តគ្រប់គ្រងជីវិតយ៉ាងឯក មិនគិតបៀតបៀនគេ មិននិយាយពាក្យសំដីបៀតបៀនគេ មិនប្រើកាយឲ្យធ្វើការបៀតបៀនគេ ។ ជនអ្នកមានចិត្តវៀរចាកការបៀតបៀន រមែងមានសេចក្ដីសុខយ៉ាងត្រជាក់ត្រជុំជានិច្ច ។

ចិត្តអាចតាក់តែងរូបនានាឲ្យល្អក៏បាន ឲ្យអាក្រក់ក៏បាន តាមកំឡាំងការចេះដឹងនឹងការល្ងង់ខ្លៅរបស់ខ្លួន ដូចបានបរិយាយមកនេះឯង ៗ

កុរុធម៌

ក្នុងកុរុធម្មជាតក តិកនិបាត

# ព្រះទេពសត្ថា កឹម-ត្បូរ បន្ទមង្គលោ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

មានបុរសពីរនាក់ជាសំឡាញ់នឹងគ្នានៅក្នុងក្រុងសាវត្ថី. ព្រមព្រៀងគ្នាទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ៗ អ្នកទាំងពីរនាក់នោះវេលាបួសហើយទោះទៅកាន់ទីណាមួយ ក៏ច្រើនតែទៅជាមួយគ្នា ។ ថ្ងៃមួយ, ភិក្ខុទាំងពីររូបនោះ នាំគ្នាទៅងូតទឹកក្នុងស្ទឹងអចិរវតី លុះងូតរួចហើយ ក៏ឡើងមកអែកំដៅថ្ងៃលើផ្ទៃខ្សាច់ អង្គុយនិយាយសំណេះសំណាលគ្នាពីរឿងនេះខ្លះនោះខ្លះតាមដែលនឹកឃើញ ។ ខណៈនោះមានបក្សីហង្សមួយគូហើរមកតាមអាកាស, ភិក្ខុកំឡោះមួយរូបក្រឡេកទៅឃើញក៏ចាប់ដុំក្រួសប្រុងនឹងគប់បក្សីហង្សនោះ ហើយប្រាប់ទៅភិក្ខុជាសំឡាញ់ថា លោកចាំមើល, ខ្ញុំនឹងគប់ភ្នែកហង្សមួយដោយដុំក្រួសនេះ ។ -លោកមិនអាចគប់ត្រូវទេ ។ -បើលោកហ៊ានមើលងាយ, ទេ, ភ្នែកខាងអាយនេះ ខ្ញុំមិនគប់ទេ, ខ្ញុំគប់ឲ្យត្រូវភ្នែកខាងនាយឯណោះផង ។ -ទេ, បើភ្នែកខាងនាយនោះ ក៏រឹតតែមិនអាចទៅទៀតហើយ ។ -អើ លោកចាំមើលចុះ, ថាហើយក៏ចាប់ដុំក្រួសត្រីវែងគប់ទៅពីខាងក្រោយហង្ស ៗ ឮសូរសន្ធឹកដុំក្រួស ក៏ងាកក្បាលមើលមក, ភិក្ខុកំឡោះនោះចាប់ក្រួសមួយដុំផ្សេងទៀត គប់សំដៅភ្នែកហង្សខាងនាយ

ត្រូវមុតផ្ទះលៀនចេញមកតាមក្អែកខាងសាយ ។ បក្សីហង្សនោះ ក៏ស្រែកប្រកាច់ធ្លាក់ចុះមកជិតជើងភិក្ខុទាំងពីររូបនោះ ។ ចំណែកភិក្ខុទាំងឡាយដែលឋិតនៅក្នុងទីនោះដែរ បានឃើញហើយក៏ពោលថា "នែអាវុសោ លោកបួសក្នុងព្រះពុទ្ធសាសនា មិនគួរមកធ្វើអំពើបាណាតិ-បាតយ៉ាងនេះសោះ" លុះពោលដូច្នេះហើយក៏នាំភិក្ខុកំឡោះនោះទៅទូលបង្ហាញព្រះ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់សួរថា នែភិក្ខុ, អ្នកឯងធ្វើអំពើបាណាតិបាតពិតមែនឬ? ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តទៅទៀតថា នែភិក្ខុ, អ្នកឯងបួសក្នុងនិយ្យានិកសាសនា (សាសនាដែលស្រោចស្រង់សត្វឲ្យចេញផុតពីសេចក្ដីទុក្ខ) មានសភាពបែបនេះ, ព្រោះហេតុអ្វីបានជាប្រព្រឹត្តធ្វើអំពើលាមកយ៉ាងនេះ, អំពាលដូចយ៉ាងបណ្ឌិតអំពីបុរាណសូម្បីព្រះពុទ្ធមិនទាន់កើតឡើងក្នុងលោកផង គង់គេមានសេចក្ដីរង្កៀសសង្ស័យចំពោះអំពើមិនសមគួរបន្តិចបន្តួច, ឯអ្នកឯងមកបួសក្នុងសាសនាគឺជាគតត្រឡាំង មិនសមបើគ្មានសេចក្ដីរង្កៀសរអែងក្នុងចិត្តបន្តិចសោះ ។ ធម្មតាធ្វើជាភិក្ខុត្រូវតែប្រព្រឹត្តសង្រួមកាយវាចាចិត្តមែនឬ? ភិក្ខុទាំងឡាយក្រាបទូលអារាធនាសូមឲ្យព្រះអង្គសំដែងអតីតនិទាន អំពីបោរាណកបណ្ឌិតទាំងឡាយ ដែលមានសេចក្ដីរង្កៀសក្នុងហេតុដែលពុំគប្បីបន្តិចបន្តួច ។

ព្រះសម្មាសម្ពុទ្ធទ្រង់នាំអតីតនិទាននោះមកសំដែងថា: ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាម

ធនញ្ជយកោរព្យៈ សោយរាជ្យក្នុងក្រុងឥន្ទបត្តក្នុងដែនកុរុ, ពោធិសត្វទៅចាប់បដិសន្ធិកើតក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ លុះប្រសូតមក បានដឹងក្តីមានវ័យចំរើនតាមលំដាប់ ហើយបានទៅសិក្សាសិល្បសាស្ត្រទាំងពួងក្នុងក្រុងតក្កសិលា លុះចប់ការសិក្សាហើយត្រឡប់មកនគរវិញ, ព្រះបិតាទ្រង់តាំងព្រះពោធិសត្វក្នុងឋានៈជាឧបរាជ ។ លុះចំណេរកាលមកខាងក្រោយ អំណើះតពីព្រះបិតាទៅ, ព្រះពោធិសត្វបានសោយរាជ្យ ទ្រង់រក្សារាជធម៌ (ធម៌សម្រាប់ស្តេច) ១០ យ៉ាង ព្រមទាំងប្រព្រឹត្តកុរុធម៌ផង ។

រាជធម៌ ១០ យ៉ាងនោះ គឺ

១– ទាន ទ្រង់ព្រះរាជទានទ្រព្យមានកំណត់ចំពោះបុគ្គល,

២– សីល ទ្រង់រក្សាកាយវាចាឲ្យមានសណ្តាប់រៀបរយល្អ,

៣– បរិច្ចាគ ទ្រង់បរិច្ចាគព្រះរាជទ្រព្យជាសាធារណៈប្រយោជន៍,

៤– អាជ្ជវ ទ្រង់មានព្រះអធ្យាស្រ័យត្រឹមត្រង់ក្នុងសុចរិតធម៌,

៥– មទ្ទវ ទ្រង់មានព្រះអធ្យាស្រ័យទន់ព្រះកាយដ៏ទន់ក្នុងសុភាព,

៦– តប: ទ្រង់មានព្យាយាមកំចាត់សេចក្តីអាក្រក់ចេញ (រក្សាឧបោសថ),

៧– អក្កោធ: ទ្រង់មិនក្រេវក្រោធដោយខុសទំនង (មានមេត្តា),

៨– អវិហឹសា ទ្រង់មិនបៀតបៀនអ្នកដទៃដោយអយុត្តិធម៌,

៩– ខន្តិ ទ្រង់ចេះអត់ធន់ចំពោះហេតុការណ៍ផ្សេងៗ,

១០- អវិរោធន ទ្រង់មិនធ្វើឲ្យខុសចាកហេតុដ៏ត្រឹមត្រូវ ឬមិនប្រទ្បាតទៅតាមលោកធម៌ ឬក៏មិនរំលោភបំពានលើច្បាប់ ។

ឯកុសលធម៌នោះបានដល់សីល ៥ គឺ

១- ការមិនសម្លាប់សត្វ,

២- ការមិនកាន់យកទ្រព្យដែលគេមិនបានឲ្យ,

៣- ការមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

៤- ការមិនពោលពាក្យកុហក,

៥- ការមិនផឹកនូវទឹកស្រវឹង ។

ពោធិសត្វ រក្សាកុសលធម៌គឺសីល ៥ នោះឲ្យបរិសុទ្ធល្អយ៉ាងណា ឯជន ១០ នាក់ទៀតគឺ ព្រះមាតា, ព្រះអគ្គមហេសី, ឧបរាជជាព្រះអនុជនៃព្រះពោធិសត្វ, ព្រាហ្មណ៍ជាបុរោហិត, រជ្ជុគាហៈ (អមាត្យអ្នកកាន់ខ្សែវាស់ដី), នាយសារថី (អ្នកបររាជរថ), សេដ្ឋី, មហាមាត្យអ្នកវាល់ស្រូវដើម្បីហូតពន្ធ, នាយឆ្មាំទ្វារ, នគរសោភិនី (ស្រីពេស្យា) ក៏បានរក្សាសីល ៥ បរិសុទ្ធដូចជាព្រះពោធិសត្វយ៉ាងនោះដែរ ។ មិនត្រឹមតែប៉ុណ្ណោះ ពោធិសត្វបានឲ្យគេសាងទានសាលា (សាលាសម្រាប់ឲ្យទាន) ៦ ខ្នងគឺ ត្រង់ទ្វារនគរ ៤, ត្រង់កណ្ដាលនគរ ១ ត្រង់ទ្វារព្រះរាជដំណាក់ ១ ទ្រង់ចំណាយព្រះរាជទ្រព្យ ៦ សែនកហាបណៈរាល់ៗថ្ងៃ ព្រះរាជទានដល់សមណជនជម្ពូទ្វីបទាំងមូល ។ ពោធិសត្វទ្រង់មានព្រះ

អធ្យាស្រ័យត្រេកអរតែក្នុងទាន, ម៉្លោះហើយ កិត្តិស័ព្ទរបស់ព្រះអង្គក៏ល្បីរន្ទឺឮផ្សាយទៅពេញជម្ពូទ្វីបទាំងមូល ។

កាលនោះ ក្នុងដែនកាលិង្គៈ, ព្រះបាទកាលិង្គៈទ្រង់សោយរាជ្យក្នុងក្រុងទន្តបុរី ។ ក្នុងដែនរបស់ព្រះរាជាអង្គនោះ គ្មានភ្លៀងសោះ, ម៉្លោះហើយក៏កើតទុរភិក្សក្នុងដែនទាំងមូល ។ ភ័យទាំង ៣ គឺឆាតកភ័យ, រោគភ័យ, ទុព្ភិក្ខភ័យ ក៏កើតឡើងដល់មនុស្សទាំងឡាយ ព្រោះវិបត្តិនៃអាហារ ។ មនុស្សទាំងនោះ កាលបើត្រូវភ័យទាំង ៣ មានឆាតកភ័យជាដើមបៀតបៀនហើយ ក៏នាំគ្នាដឹកដៃកូនជញ្ជូនទៅត្រាច់ទៅក្នុងទីនេះខ្លះ ទីនោះខ្លះ ដើម្បីស្វែងរកអាហារនិងសេចក្ដីសុខរៀងៗខ្លួន ។ មិនតែប៉ុណ្ណោះ ពួកប្រជារាស្ត្រក្នុងដែនទាំងមូល ក៏កើតចលាចលលើកគ្នាទៅកាន់ក្រុងទន្តបុរី, សំដែងអាការហ៊ោកញ្ជ្រៀវនៅជិតទ្វារព្រះរាជដំណាក់នៃព្រះបាទកាលិង្គៈ ។ ខណៈនោះ ព្រះរាជាទ្រង់ប្រហាប់ត្រង់បង្អួច ទ្រង់ឮសម្រែកដ៏សំបើមអស្ចារ្យនោះ ទើបត្រាស់សួរថា ពួកមហាជនទាំងនោះ នាំគ្នាមកធ្វើអ្វីច្រើនម៉្លេះ? ជនទាំងឡាយក្រាបទូលថា បពិត្រមហារាជ ភ័យ ៣ យ៉ាងកើតឡើងក្នុងដែនទាំងមូល, ភ្លៀងមិនធ្លាក់ចុះមកសោះ, សំទូងស្រូវក្រៀមក្រោះវិនាសហិនហោចអស់, ការអត់ឃ្លានក៏កើតឡើងព្រម, មនុស្សទាំងឡាយបរិភោគភោជនមិនល្អត្រូវរោគបៀតបៀន ក៏នាំកូនទៅត្រាច់ទៅកាន់ទីផ្សេងៗ កាលបើដូច្នេះសូមព្រះអង្គញុំាងភ្លៀងឲ្យធ្លាក់ចុះមក ។ ព្រះរាជាទ្រង់ត្រាស់សួរថា ស្ដេចពីបុរាណកាលបើគ្មានភ្លៀងធ្លាក់ចុះមកទេ តើទ្រង់ធ្វើដូចម្ដេច?

– បពិត្រព្រះមហារាជ, ស្តេចពីបុរាណ កាលបើគ្មានភ្លៀងធ្លាក់ចុះមក តែងទ្រង់បំណាយព្រះរាជទ្រព្យឲ្យជាទាន ហើយទ្រង់អធិដ្ឋានឧបោសថ សមាទានសីល រួចហើយទ្រង់ចូលទៅកាន់បន្ទប់ដ៏មានសិរីផ្ទំអស់ ៧ ថ្ងៃ លើគ្រែលាស្មៅ ភ្លៀងទើបធ្លាក់ចុះមកក្នុងកាលនោះ ៗ ព្រះរាជា ទ្រង់ទទួលធ្វើតាមមានឲ្យទានជាដើម ដោយសព្វគ្រប់ហើយ, ភ្លៀង ក៏នៅតែមិនធ្លាក់ចុះមកសោះ, ទើបត្រាស់សួរទៅអមាត្យទាំងឡាយថា កិច្ចដែលគួរធ្វើ យើងបានធ្វើរួចអស់ហើយ, ភ្លៀងក៏នៅតែមិនធ្លាក់ចុះ មក តើឥឡូវនេះ ឲ្យយើងធ្វើដូចម្តេចទៀត? អមាត្យទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ព្រះបាទធនញ្ជយកោរព្យៈ សោយរាជ្យក្នុងនគរឥន្ទបត្តដែនកុរុ មានដំរីជាមង្គលមួយឈ្មោះអញ្ជន សន្និកៈ កាលបើយើងនឹងទៅនាំយកដំរីនោះចូលមក, ភ្លៀងមុខតែ នឹងធ្លាក់ចុះមកពុំខាន ៗ – ទ ព្រះរាជាអង្គនោះទ្រង់សម្បូរដោយពលនឹង ពាហនៈច្រើនណាស់ ទោះបីអ្នកណាក៏មិនអាចហ៊ានទៅគ្រោមកំហែង បានឡើយ កាលបើដូច្នេះ យើងនឹងទៅនាំយកដំរីរបស់ស្តេចនោះមក ដូចម្តេចបាន? – សូមទ្រង់ព្រះមេត្តាប្រោស, យើងមិនត្រូវទៅគ្រោម កំហែង ឬធ្វើចំបាំងជាមួយនឹងព្រះបាទធនញ្ជយកោរព្យៈនោះទេ ព្រោះ ថាព្រះរាជាអង្គនោះ ទ្រង់មានព្រះអធ្យាស្រ័យរីករាយក្នុងការបរិច្ចាគទាន ណាស់ ប្រសិនបើមានគេសុំព្រះសិរសៈក្តី សុំព្រះនេត្រក្តី ឬសុំរាជ-សម្បត្តិទាំងមូលក្តីរបស់ព្រះអង្គ ៗ ក៏អាចកាត់ព្រះសិរសៈ ឆ្កៀលព្រះនេត្រ ឬប្រគល់រាជសម្បត្តិឲ្យដល់ស្មូមនោះបានដែរ នឹងបាច់និយាយទៅថ្វីត្រឹម

ដំរីមួយប៉ុណ្ណោះ ដំរីនោះបើយើងសុំហើយ ព្រះរាជាអង្គនោះប្រហែលជាមិនជូនព្រះទ័យប៉ុន្មានទេ មុខតែនឹងព្រះរាជទានឲ្យដល់យើងពុំខាន ។

- អើបើដូច្នោះ តើអ្នកណាអាចទៅសុំដំរីនោះបាន? - សូមទានមេត្តាប្រោស, ពួកព្រាហ្មណ៍ ៗ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យអញ្ជើញពួកព្រាហ្មណ៍ទាំង ៨ នាក់មកជប់លៀង ដោយគ្រឿងសក្ការៈនិងសេចក្ដីកប់អាន រួចហើយទ្រង់បញ្ជូនទៅឲ្យសុំដំរី ៗ ព្រាហ្មណ៍ទាំងនោះ នាំយកស្បៀងទៅតាមខ្លួន ទាំងកាន់យកភេទជាអ្នកដំណើរ ដើរទៅដោយស្រូតរូត, សម្រាកនៅនាពាក់កណ្ដាលផ្លូវតែមួយយប់ប៉ុណ្ណោះ ក៏បានដល់ទៅនគរជេតុត្តរក្នុងដែនកុរុ ហើយឈប់សម្រាកនៅទទួលទានបរិភោគចំអែតកាយក្នុងសាលាទានទៀបទ្វារនគរអស់ពីរបីថ្ងៃ ហើយទើបសួរគេថា ថ្ងៃណាព្រះរាជាទ្រង់ស្ដេចមកកាន់រោងទាននេះ? មនុស្សទាំងឡាយបានប្រាប់ថា ព្រះរាជារបស់យើង ស្ដេចតែងមកក្នុងមួយបក្ស ៣ ថ្ងៃ គឺថ្ងៃទី ១៤ម្ដង ថ្ងៃទី ១៥ម្ដង និងថ្ងៃទី ៨ម្ដង, តែថ្ងៃស្អែកជាថ្ងៃទី ១៥ ពេញបូណ៌មី, ព្រះរាជានឹងយាងមកក្នុងថ្ងៃស្អែកនេះពុំខាន ៗ លុះដល់ថ្ងៃព្រឹកស្អែកឡើង ព្រាហ្មណ៍ទាំង ៨ នាក់ក៏នាំគ្នាទៅឈរចាំត្រង់ទ្វារនគរខាងកើត ៗ ពោធិសត្វ, ក្នុងវេលាព្រឹក ទ្រង់ស្រង់ព្រះគង្គាលុបលាបព្រះអង្គរួចហើយ ទ្រង់ប្រដាប់ព្រះអង្គដោយគ្រឿងអលង្ការទាំងពួង ហើយទ្រង់ឡើងគង់លើដំរី ជាព្រះទីនាំងដ៏ប្រសើរ ដែលគេតាក់តែងថ្វាយ, ទ្រង់ស្ដេចទៅកាន់សាលាទានតាមទ្វារនគរខាងកើត ដោយមានរាជបរិពារជាច្រើនតាមដង្ហែព្រះអង្គ, លុះដល់

ហើយ ទ្រង់យាងចុះពីព្រះទីនាំងចូលទៅកាន់សាលាទាន, ទ្រង់ព្រះរាជទានភត្តដល់ពួកស្មូមចំនួនជា ៧ ឬ ៨ នាក់ ដោយផ្ទាល់ព្រះហស្ត រួចហើយទើបត្រាស់បង្គាប់ឲ្យគេឲ្យទានតាមទំនងនេះ, លុះត្រាស់បង្គាប់ដូច្នេះហើយ ព្រះរាជាទ្រង់ឡើងគង់លើដំរីយាងទៅកាន់ទ្វារខាងត្បូង ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះ កាលដែលទៅឈរចាំត្រង់ទ្វារខាងកើត មិនបានឱកាសសោះ ដោយមានពួកត្រួតនៅការពារមាំមួនពេក ទើបនាំគ្នាទៅចាំទ្វារខាងត្បូងទៀត ឈរលើទីដីខ្ពស់មិនឆ្ងាយប៉ុន្មានអំពីទ្វារ រង់ចាំមើលព្រះរាជាទ្រង់ស្ដេចមក, លុះឃើញព្រះរាជាទ្រង់យាងមកជិតហើយ ក៏លើកដៃប្រណម្យឡើងក្រាបទូលថា ''សូមព្រះរាជតេជះដ៏កល់លើត្បូង, សូមព្រះអង្គមានជ័យជំនះ'' ។ ព្រះរាជាទ្រង់ទតទៅឃើញហើយ ក៏ត្រាស់បង្គាប់ឲ្យញ៉ាំងដំរីឲ្យងាកបែរទៅរកព្រាហ្មណ៍ទាំងនោះ ហើយទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ទាំងឡាយ, អ្នករាល់គ្នាត្រូវការអ្វី? ព្រាហ្មណ៍ទាំងឡាយ ក្រាបទូលសរសើរគុណព្រះពោធិសត្វថា

បពិត្រព្រះជនាធិបតី ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា បានដឹងច្បាស់នូវវណ្ណៈគឺសទ្ធានិងសីលរបស់ព្រះអង្គថា ព្រះរាជាដែលបរិបូណ៌ដោយសទ្ធានិងសីលដ៏លើសលុបយ៉ាងនេះ ប្រសិនបើមានគេសូមជីវិត ក៏គង់តែទ្រង់ប្រទានឲ្យដែរ និងបាច់និយាយទៅថ្វីដល់ដំរីជាសត្វតិរច្ឆាន ព្រោះហេតុនេះ ទូលព្រះបង្គំជាខ្ញុំ មកក្រាបបង្គំសុំដំរីរបស់ព្រះអង្គ ដែលមានសម្បុរដូចផ្កាអញ្ចាននេះយកទៅថ្វាយព្រះបាទកាលិង្គៈ ឯដែនកាលិង្គៈ សូមព្រះអង្គទ្រង់ជ្រាបនូវដំណើររបស់ទូលព្រះបង្គំជាខ្ញុំ ដែលមកក្នុងទីនេះចុះ ។

ព្រះពោធិសត្វ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ទាំងនោះហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ យើងនឹងឲ្យដំរីនេះមួយអន្លើ ដោយគ្រឿងអលង្ការទាំងប៉ុន្មាន ដែលតាក់តែងស្រេចស្រាប់នៅជាប់ញដ៏ខ្លួននៃដំរីព្រមទាំងហ្មដំរីដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយនាំយកដំរីនេះព្រមទាំងបរិវារទៅតាមសេចក្ដីប្រាថ្នាចុះ ។ ព្រះមហាសត្វកំពុងគង់លើកដំរី បានប្រទានដោយព្រះវាចាយ៉ាងនេះហើយ ក៏យាងចុះអំពីកនៃដំរី ទ្រង់ព្រះតម្រិះថា "បើកន្លែងណាមិនទាន់មានគ្រឿងប្រដាប់តាក់តែងនៅឡើយទេ អាត្មាអញនឹងតាក់តែងដំរីនេះដោយគ្រឿងប្រដាប់ឲ្យមានសព្វគ្រប់រួចហើយសឹមឲ្យ" លុះទ្រង់ពិនិត្យមើលទៅមិនឃើញមានខ្វះត្រង់កន្លែងណាមួយសោះ ទើបទ្រង់យាងប្រទក្សិណដំរីបីជុំ ហើយលើកប្រមោយដំរីដាក់លើដៃព្រាហ្មណ៍ទាំងឡាយ ហើយទ្រង់យកកុណ្ឌីមាសមកប្រួចទឹកដែលអប់ដោយក្លិនផ្កា ព្រះរាជទានដល់ព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះ កាលបើបានទទួលដំរីព្រមទាំងបរិវារហើយ ក៏នាំគ្នាឡើងជិះលើខ្នងដំរីនាំទៅថ្វាយព្រះរាជា នាក្រុងទន្តបុរីក្នុងដែនកាលិង្គៈ ។ សូម្បីដំរីជាមង្គលនោះចូលមកដល់ហើយ ភ្លៀងក៏នៅតែមិនធ្លាក់ចុះមកតាមបំណងឡើយ ។ ព្រះរាជាទ្រង់ត្រាស់សួរគេទៅទៀតថា "ព្រោះហេតុអ្វីបានជាដូច្នេះ?" ទើបទ្រង់ព្រះសណ្ដាប់ប្រាប់ដំណឹងច្បាស់ថា "ព្រះបាទធនញ្ជយកោរព្យៈ ទ្រង់រក្សាកុរុធម៌ដោយខ្ជាប់ខ្ជួន ព្រោះហេតុនោះ បានជាក្នុងដែនរបស់ព្រះរាជាអង្គនោះ មានភ្លៀងធ្លាក់ចុះមករឿយៗ ក្នុងរវាងកន្លះខែម្ដង ឬរវាង ១០ ថ្ងៃ

ម្តង ៗ ឯភ្លៀងដែលបង្អុរចុះមកនោះគឺដោយគុណានុភាពរបស់ព្រះ
រាជាតែម្យ៉ាង មិនមែនដោយគុណានុភាពនៃសត្វគិរប្រាននេះប៉ុន្មានទេ”
លុះទ្រង់ជ្រាបការណ៍ច្បាស់ហើយ ទើបត្រាស់បញ្ជូនពួកព្រាហ្មណ៍ នឹង
អមាត្យទៅឯនគរឥន្ទបត្តម្តងទៀតដោយព្រះតម្រាស់ថា បើដូច្នេះទេ,
អ្នកទាំងឡាយចូរនាំដំរីដែលតាក់តែងដោយគ្រឿងអលង្ការ ព្រមទាំង
បរិវារនេះ ត្រឡប់ទៅថ្វាយព្រះបាទធនញ្ជយកោរព្យៈវិញ បើព្រះរាជាអង្គ
នោះទ្រង់រក្សាកុរុធម៌ណា, ចូរសុំកត់ចម្លងកុរុធម៌នោះដាក់ក្នុងផ្ទាំងមាស
ហើយនាំមក ៗ ពួកជនទាំងនោះ នាំដំរីទៅថ្វាយព្រះបាទធនញ្ជយ-
កោរព្យៈហើយក្រាបបង្គំទូលថា “បពិត្រព្រះសម្មតិទេព ដំរីនេះស្ឋិត
ទៅដល់ហើយ ភ្លៀងក៏នៅតែមិនធ្លាក់ចុះមកក្នុងដែនរបស់យើង, ឥឡូវ
បានឮថាព្រះអង្គទ្រង់រក្សាកុរុធម៌ ឯព្រះរាជារបស់យើងទ្រង់បង់រក្សាកុរុ
ធម៌នោះដែរ បានជាទ្រង់ត្រាស់បញ្ជូនឲ្យយើងមកសុំចម្លងកុរុធម៌នោះ
អំពីព្រះអង្គ ចុះទុកនឹងផ្ទាំងមាសនេះហើយនាំយកទៅ, ដោយហេតុ
នេះ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសប្រទានកុរុធម៌នោះដល់យើង
ទាំងឡាយ” ៗ

ព្រះបាទធនញ្ជយកោរព្យៈទ្រង់ត្រាស់ថា ម្នាលអ្នកទាំងឡាយ,
យើងរក្សាកុរុធម៌ពិតមែន តែឥឡូវនេះ យើងមានសេចក្តីរង្កៀសក្នុងកុរុធម៌
ក្រែងកុរុធម៌របស់យើងនោះមានការសៅហ្មង, ដូច្នេះ យើងពុំអាចឲ្យកុរុធម៌
ដល់អ្នកទាំងឡាយទេ ៗ

(មានត)

កាម្មបឋកាថា

# ព្រះមហា មៀច-ជ័យ វិត្តសារ៉ាវ័ន

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមេ សេដ្ឋត្តិលោកគ្គំ នត្វា ធម្មំ សគម្ភីរំ

វន្ទេ ភវង្ឃំ វិសុទ្ធញ្ច ទក្ខិណេយ្យំ គិរង្គណំ ។

កន្លងដើមនៃធម៌ទេសនានេះ ខ្ញុំព្រះករុណា សូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រសើរវិសេស ជាកំពូលនៃទេវតានិងមនុស្សក្នុងត្រៃលោកផង; សូមថ្វាយបង្គំចំពោះព្រះនវលោកុត្តរធម៌ដ៏មានគម្ភីរភាពផង សូមថ្វាយបង្គំចំពោះព្រះអរិយសង្ឃមានព្រះទ័យដ៏ស្អាត ជាទក្ខិណេយ្យបុគ្គល ឥតមានទីទួលគឺកគាទិក្កិលេសផង; ដោយអំណាចនៃរតនត្តយណាមនេះ សូមសេចក្ដីសុខសួស្ដី ចូរមានដល់យើងខ្ញុំផង ដល់សាធុសប្បុរសទាំងឡាយផង សព្វកាលវៀងទៅ ។

ឥតោ បរំ បន្ទាប់អំពីបទនមស្ការនេះទៅ សូមលើកយកគព្ទ-កាសិតក្នុងបកកវសូត្រ ដែលទេវតាទូលសួរអំពីហេតុជាប្រធាននៃសេចក្ដីវិនាសរបស់បុគ្គល, ហើយព្រះបរមសាស្ដាទ្រង់ត្រាស់ឆ្លើយតបដោយបទគាថាទី ១ ថា :

សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ

ប្រែថា "បុរសបុគ្គលអ្នកមានសេចក្តីចំរើន អ្នកផងតែងដឹងតែងស្គាល់បានដោយងាយ, បុរសបុគ្គលអ្នកមានសេចក្តីវិនាស ក៏អ្នកផងតែងដឹងតែងស្គាល់ដោយងាយដែរ (ដូចជា) ជនអ្នកស្រឡាញ់ធម៌តែងមានសេចក្តីចំរើន, ជនអ្នកស្អប់ធម៌ តែងមានសេចក្តីវិនាស" ។

ព្រះបរមគ្រូទ្រង់ត្រាស់សំដែងបរាភវសូត្រនេះ ជាបុគ្គលាធិដ្ឋាន, មិនមែនសំដែងជាធម្មាធិដ្ឋានទេ ។

លំដាប់ពីនេះ សូមអធិប្បាយអំពីបុគ្គល ២ ប្រភេទគឺ ភវបុគ្គល (បុគ្គលចំរើន) និងបរាភវបុគ្គល (បុគ្គលវិនាស) ។ បុគ្គលអ្នកមានសេចក្តីចំរើន ហៅថា ភវបុគ្គល; អ្នកមានសេចក្តីវិនាស ហៅថា បរាភវបុគ្គល ។ បុគ្គលអ្នកស្រឡាញ់សុចរិតធម៌ តែងមានសេចក្តីចំរើន; អ្នកស្អប់សុចរិតធម៌តែងមានសេចក្តីវិនាស ។ សេចក្តីចំរើននិងសេចក្តីវិនាសទាំងពីរនេះ មានអ្វីជាមូលហេតុ? សេចក្តីចំរើនមានសុចរិត ៣ ជាមូលហេតុ ។ សេចក្តីវិនាស មានទុច្ចរិត ៣ ជាមូលហេតុ ។

សុចរិតនោះមាន ៣ គឺកាយសុចរិត ១, វចីសុចរិត ១, មនោសុចរិត១ ។ កាយសុចរិតមាន ៣ យ៉ាងគឺ វៀរចាកសម្លាប់សត្វ ដោយខ្លួនឯងទាំងមិនប្រើគេឲ្យសម្លាប់ ១, វៀរចាកលួចលាក់ឆក់ដណ្តើមទ្រព្យរបស់គេដោយខ្លួនឯង ទាំងមិនប្រើគេឲ្យលួចលាក់ ១, វៀរចាកការ

ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺមិនសេពសន្ថវៈជាមួយនឹងស្ត្រីដែលមានគេហួងហែងរក្សា ១ ។ វចីសុចរិតមាន ៤ យ៉ាងគឺ វៀរចាកពោលពាក្យកុហក ១, វៀរចាកពោលពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ១, វៀរចាកពោលពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃ ១, វៀរចាកពោលពាក្យរោយរាយឥតប្រយោជន៍ ១ ។ មនោសុចរិតមាន ៣ យ៉ាង គឺ មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបម្រុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ១, មិនមានចិត្តចងគំនុំគុំគួន គិតប៉ងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ១, គំនិតយល់ឃើញត្រូវពិត (សម្មាទិដ្ឋិ) ហើយប្រកាន់ឡើងថាជាត្រូវមែន ១ ។

បពិត្រអស់លោក - អ្នកសប្បុរសទាំងឡាយ ! សុចរិតទាំង ៣ ប្រការនេះ ជាប្រធាននៃសេចក្ដីចំរើន ។ បើបុរសបុគ្គលណាស្រឡាញ់សុចរិតធម៌ទាំងបីប្រការនេះ បុរសបុគ្គលនោះតែងបានសេចក្ដីចំរើនក្នុងលោកនេះនឹងលោកខាងមុខ (ទុកដូចជាមានស្នេហ៍មុខយ៉ាងវិសេស)ម្យ៉ាងទៀតអ្នកប្រព្រឹត្តសុចរិតធម៌ តែងប្រកបដោយគុណ ៤ ប្រការគឺអាយុ, វណ្ណៈ, សុខៈ, ពលៈ វៀរលែងតែបុគ្គលនោះមានឧបបីឡកកម្មមកបៀតៗ

មានសេចក្ដីដំណាលថា ព្រះបរមពោធិសត្វរបស់យើងកាលយោនយកកំណើតក្នុងត្រកូលព្រាហ្មណ៍មួយ នៅទៀបក្រុងពារាណសី មាននាមប្រាកដថា ធម្មបាលមាណព, ឯត្រកូលព្រាហ្មណ៍នោះតែងសមាទានប្រព្រឹត្តនូវសុចរិតទាំង ៣ ឬ កុសលធម៌ទាំង ១០ ប្រការ ជាប់បរិសុទ្ធមិនឲ្យបែកធ្លាយ ទាំងមិនសៅហ្មងដល់តិចតួចឡើយ ។ ជាទំនៀមរបស់

ត្រកូលនោះ គេតែងបង្ហាត់បង្រៀនប្រៀនប្រដៅកូនចៅរបស់គេ ឲ្យចេះរក្សាសុចរិតធម៌គ្រប់គ្នាទាំងអស់ ។ កាលធម្មបាលបានអាយុ ១៦ ឆ្នាំ, មាតាបិតាបានបញ្ជូនឲ្យទៅរៀនចំណេះវិជ្ជាសិល្បសាស្ត្រ អំពីសំណាក់អាចារ្យទិសាបាមោក្ខនៅនានគរតក្កសិលា ។ លុះទៅដល់សំណាក់អាចារ្យទិសាបាមោក្ខ ក៏ចូលទៅសូមរៀនចំណេះវិជ្ជា, អាចារ្យក៏បានសាកសួរស្រុកទេស, បានដឹងសព្វគ្រប់ហើយ ក៏ព្រមទទួលបង្រៀន ប៉ុន្តែគ្រាន់តែទទួលមិនទាន់បានបង្រៀននៅឡើយ ព្រោះមានកិច្ចធុរៈនឹងកូនឈឺជាទម្ងន់ ។ កូននោះមានអាយុ ១៦ ឆ្នាំ ដំណាលគ្នានឹងធម្មបាលកុមារដែរ ។ លុះធម្មបាលកុមារនៅបាន ២-៣ ថ្ងៃ កូនអាចារ្យនោះក៏ធ្វើមរណកាលស្លាប់ទៅ ។ មាតាបិតានឹងញាតិទាំងឡាយរបស់កុមារនោះក៏យំសោកស្តាយអាឡោះអាល័យតែពលគ្នា ។ ធម្មបាលកុមារឃើញគេយំសោកស្តាយមនុស្សស្លាប់ពីក្មេងដូច្នោះ អត់ទ្រាំពុំបាន ក៏សើចតែម្នាក់ឯង ។ អាចារ្យឃើញធម្មបាលសើចខុសទំនងដូច្នោះ ក៏សួរថា នែមាណព យើងកើតទុក្ខនឹងកូនស្លាប់ បានជាយំស្តាយអាឡោះអាល័យ, ម្តេចក៏ឯងសើចក្អាកក្អាយនឹងយើងទៅវិញ ? ។ ធម្មបាលមាណពជំរាបអាចារ្យថា: បពិត្រលោកអាចារ្យ ! ត្រកូលរបស់ខ្ញុំបាទមិនដែលមានមនុស្សណាមួយ ស្លាប់ក្នុងចន្លោះអាយុ ១០០ ឆ្នាំឡើយ លុះតែដល់កំណត់ ១០០ ឆ្នាំទើបស្លាប់ ។ ហើយគេមិនដែលយំសោកអាឡោះអាល័យចំពោះអ្នកដែលស្លាប់ទៅដូច្នេះទេ, ហេតុនេះហើយបានជាខ្ញុំបាទអត់សំណើចពុំបាន ។ អាចារ្យទិសាបាមោក្ខសួរថា ចុះត្រកូល

ឯងក្រោធម៌អ្វីបានជាមានអាយុកំណត់ ១០០ ឆ្នាំ ទើបស្លាប់ ហើយគេមិនយំសោកអាល័យគ្នាផង? ។ ធម្មបាលកុមារជំរាបថា: ត្រកូលរបស់ខ្ញុំបានក្រោកុសលកម្មបថ ១០ តាំងពីចាស់តាំងក្មេង មិនថែកឃ្លាយកម្មបថណាមួយឡើយ ។ អាចារ្យឮហើយក៏នៅស្ងៀម បាននាំគ្នាយកសពកូននោះទៅកាន់ព្រៃស្មសាន ។ លុះត្រឡប់មកវិញនិយាយថា: នែមាណព! យើងមិនជឿពាក្យដែលឯងនិយាយតាំងប៉ុន្មាននោះទេ ព្រោះក្រែងអាងតែយើងមិនស្គាល់ ។ ឯវិជ្ជាដែលឯងត្រូវការរៀនសូត្រនោះ បង្អង់សិនចុះចាំយើងបាត់ទុក្ខព្រួយបន្តិចសិន ។ តពីនោះមកអាចារ្យក៏ចេញដំណើរតម្រង់ទៅកាន់ក្រុងពារាណសី ដើម្បីបញ្ជាក់ការណ៍នោះមើលជាពិតដូចព្រោះមែន ឬពុំពិតទេ? លុះដើរទៅដល់ពាក់កណ្ដាលផ្លូវ ឃើញខ្មោចសត្វពពែមួយ ក៏ដើររើសឆ្អឹងពពែនោះ លុះដុតស្អុសហើយ ក៏រើសឆ្អឹងខ្ចប់បាន ១ កញ្ចប់ ប្រហែលឆ្អឹងមនុស្សម្នាក់ ទើបដើរយ៉ាងប្រញាប់ទៅដល់ក្រុងពារាណសី ស៊ើបសួររកផ្ទះធម្មបាល-កុមារ លុះឃើញហើយក៏ឡើងទៅអង្គុយលើផ្ទះនោះ ។ មាតាបិតារបស់ធម្មបាលកុមារក៏សួរថា អ្នកអញ្ជើញមកពីណា? ។ - ខ្ញុំហ្នឹងឯងជាអាចារ្យទិសាបាមោក្ខ នៅនគរតក្កសិលា ។ - អើ! លោកអាចារ្យបានឃើញកូនខ្ញុំឈ្មោះធម្មបាលមាណពដែរឬទេ? ។ អាចារ្យលើកដៃសំពះហើយក៏យំខ្សឹកខ្សួល ។ មាតាបិតាធម្មបាលសួរថា ហេតុអ្វីបានជាលោកអាចារ្យយំខ្សឹកខ្សួលយ៉ាងនេះ? ។ - ឱ! អ្នកអើយ! កូនអ្នកទៅកាន់សំណាក់ខ្ញុំ សុំរៀនសិល្បសាស្ត្រ នៅបានតែ ២ ៣ ថ្ងៃមិនទាន់

ទាំងបានរៀនផង ស្រាប់តែឈឺស្លាប់ទៅហើយ » រួចគាត់បង្ហាញឆ្អឹងពាក្យប្រាប់ថា: នេះហើយឆ្អឹងកូនអ្នក ខ្ញុំយកមកជូន ។ មាតាបិតានិងញាតិធម្មបាលនិយាយថា លោកអាចារ្យត្រកូលរបស់យើង មិនដែលស្លាប់ពីក្មេងដូច្នេះទេ ធ្លាប់តែអាយុ ១០០ ឆ្នាំទើបឈឺស្លាប់ៗ ហើយក៏មិនដែលយំសោកដែរ ព្រោះត្រកូលយើង សុទ្ធតែជាអ្នករក្សាកុសលកម្មបថ ១០ ឥតមានបែកធ្លាយកម្មបថណាមួយទេ បានជាមានអានិសង្សឲ្យមានអាយុកំណត់ ១០០ ឆ្នាំទើបស្លាប់, ឯធម្មបាលមាណពកូនយើង ដែលលោកអាចារ្យថាស្លាប់នោះ យើងមិនជឿទេ ។ អាចារ្យទិសាបាមោក្ខគិតថា: ពិតមែនហើយត្រកូលនេះ ត្រូវដូចពាក្យធម្មបាលមាណពប្រាប់មែន ។ អាចារ្យទិសាបាមោក្ខ ក៏សូមសមាទានរៀនយកកុសលកម្មបថទាំង ១០ អំពីសំណាក់បិតាធម្មបាលកុមារ គង់គ្រានោះ ។ កុសលកម្មបថទាំង ១០ នោះ ដូចបានសំដែងរៀបរាប់ខាងលើមកសព្វគ្រប់ហើយ ។

សំដែងរឿងនេះមកដើម្បីបញ្ជាក់សេចក្តីឲ្យឃើញថា អ្នកដែលស្រឡាញ់ធម៌ គឺអ្នកប្រព្រឹត្តតាមសុចរិតធម៌ទាំង ៣ ប្រភេទនេះ តែងមានសេចក្តីចំរើន គឺចំរើនទាំងអាយុ - កំណើត បានកើតក្នុងជាតិណា ៗ តែងបរិបូណ៌ដោយភោគសម្ប័ទ បរិវារសម្ប័ទ និងយសសក្តិ ថែមទាំងមិនសូវមានរោគាព្យាធិមកបៀតបៀនផង មានអាយុក៏យឺនយូរ មិនដែលធ្លាក់ទៅកាន់កំណើតថោកទាបឡើយ ។ សមដូចពុទ្ធភាសិតថា: ធម្មោ ហវេ

រក្ខតិ ធម្មចារឹ "ធម៌តែងរក្សាបុគ្គលអ្នកប្រព្រឹត្តនូវធម៌ជាប្រក្រតី" ។ ពាក្យថាធម៌ក្នុងទីនេះ គឺសំដៅយកសុចរិតធម៌នោះឯង ។

ម្យ៉ាងទៀត មានពុទ្ធភាសិតសំដែងថា បើបុរសបុគ្គលណា បាន ប្រព្រឹត្តសុចរិតធម៌ត្រឹមត្រូវល្អហើយ រមែងបានអានិសង្ស ៥ យ៉ាងគឺ

១– អត្តាបិ អត្តានំ ន ឧបវទតិ ខ្លួនឯងនឹងមិនតិះដៀលខ្លួនឯង ។

២– អនុវិច្ច វិញ្ញូ បសំសន្តិ វិញ្ញូជន គឺអ្នកដឹងការពិតទាំងឡាយ កាលពិនិត្យទៅឃើញហើយ តែងសរសើរ ។

៣– កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិសព្ទដ៏ល្អរមែងខ្ចរខ្ចាយសុសសាយទៅ ។

៤– អសម្មូឡ្ហោ កាលំ ករោតិ លុះអ្នកប្រព្រឹត្តសុចរិត ធ្វើមរណកាលទៅនឹងមិនវង្វេងវង្វាន់កាន់ច្រឡំស្មារតី ។

៥– សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ដល់ទំលាយខន្ធទៅតែងទៅកាន់សុគតិសួគ៌ទេវលោក ។

បើបុគ្គលណាបានសមាទានកាន់យកនូវកុសលកម្មបថ ឬ សុចរិតទាំង ១០ ប្រការនេះហើយ ឈ្មោះថាបានវៀរចាក អកុសលកម្មបថ ឬ ទុច្ចរិតទាំង ១០ ប្រការនោះដែរ ។

ឯទុច្ចរិតនោះមាន ៣ ប្រភេទ គឺ ១– កាយទុច្ចរិត, ២– វចីទុច្ចរិត,

៣ - មនោទុច្ចរិត ។ កាយទុច្ចរិតមាន ៣, វចីទុច្ចរិតមាន ៤, មនោទុច្ចរិតមាន ៣, រួមត្រូវជាទុច្ចរិតមាន ១០ ប្រការ ។

ឯកាយទុច្ចរិត ៣ នោះគឺ ១ - ការសម្លាប់សត្វដោយខ្លួនឯង ឬប្រើគេឲ្យសម្លាប់ ; ២ - ការលួចលាក់ឆក់ដណ្ដើមទ្រព្យគេដោយខ្លួនឯង ឬ ក៏ប្រើគេឲ្យលួចលាក់ឆក់ដណ្ដើម ; ៣ - ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺសេពសមជាមួយនឹងស្ត្រីដែលមានគេហួងហែងរក្សា ។ វចីទុច្ចរិត ៤ នោះគឺ ១ ការពោលនូវពាក្យកុហក ; ២ និយាយពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ ; ៣ និយាយពាក្យអាក្រក់ ; ៤ និយាយពាក្យរាក់រយឥតប្រយោជន៍ ។ មនោទុច្ចរិត ៣ គឺ ១ ការសំឡឹងរំពៃបំពោះទ្រព្យអ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ; ២ ចិត្តចងគំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាស; ៣ គំនិតយល់ខុសហើយប្រកាន់ឡើងជាត្រូវ ។ ទុច្ចរិតទាំង ៣ ប្រភេទនេះ ជាប្រធាននៃសេចក្ដីវិនាស ។ បុរសបុគ្គលអ្នកប្រព្រឹត្តទុច្ចរិតហើយ ឈ្មោះថាជាអ្នកស្អប់សុចរិតធម៌វិញ, អ្នកដែលស្អប់ធម៌នោះ តែងតែប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រភេទ គឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ។

បើបុរសបុគ្គលណាប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រភេទនេះ ត្រង់ទុច្ចរិតណាមួយហើយ បុរសបុគ្គលនោះតែងបានសេចក្ដីវិនាសពុំខាន ។

មានសេចក្ដីដំណាលថា: កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ លាភសក្ការៈកើតឡើងក្នុងព្រះពុទ្ធសាសនាជាច្រើន ពួកអន្យតិរ្ថិយ៍កើតសេចក្ដីច្រណែន ក៏ប្រើនាងចិញ្ចមាណវិកា ជាស្ត្រីមានរូប

លុះ ឲ្យទៅពោលពាក្យបង្កាច់ព្រះបរមសាស្តា ៗ នាងនោះបានយកឈើមក ចងរុំផ្ចាប់នឹងពោះ សំដែងអាការដូចជាស្ត្រីមានគភ៌ ៗ ក្នុងពេលដែល ព្រះសម្ពុទ្ធកំពុងសំដែងធម៌ទេសនា ក៏ទៅសំដែងកិរិយាក្នុងកណ្តាល បរិស័ទ ហើយពោលពាក្យមួលបង្កាច់ព្រះអង្គ ៗ ពួកមហាជនកំពុង ស្តាប់ធម៌ទេសនាស្រលាំងកាំងគ្រប់គ្នា ៗ ពេលនោះ ក្តៅក្រហាយ ដល់ព្រះឥន្ទ្រ ៗ បើកទិព្វចក្ខុមើលមកឃើញក៏គិតថា "យីអើ ! នាង ចិញ្ចមាណវិកានេះ ចង្រៃណាស់តើ ! ទៅនិយាយមួលបង្កាច់ដោយ ពាក្យអសុទ្ធ ចំពោះព្រះបរមសាស្តាដែលជាបុគ្គលមិនមានទទួល គឺ កិលេស" ៗ ព្រះឥន្ទ្រនិម្មិតខ្លួនធ្វើជាសត្វកណ្តុរបុះមកវារចូលទៅ កាត់ខ្សែចំណង ដាច់ធ្លាក់ដុំឈើមកត្រូវលើខ្នងជើងបែកចេញឈាម ក្នុងទីកណ្តាលពួកបរិស័ទ ពួកមហាជនឃើញអស្ចារ្យដូច្នោះហើយក៏នាំ គ្នាដេញវាយនាងនោះ ខ្លះរើសបានដុំដី ខ្លះដំបង ដេញពោលតាម ក្រោយ ៗ គ្រាន់តែរត់ឆ្ងាយបន្តិចទៅ ផែនដីក៏បែកស្នែកជា ២ ភាគ ស្រូបនាងចិញ្ចមាណវិកា ធ្លាក់ទៅសោយទុក្ខក្នុងនរកឈ្មោះមហាអវិចី ដរាបដល់សព្វថ្ងៃនេះ ៗ

សំដែងរឿងនេះមកដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថា បុរសបុគ្គលអ្នក ប្រព្រឹត្តទុច្ចរិត កុំថាឡើយតែដល់ទៅវាយដំចាក់កាប់សម្លាប់ដោយ កាយ សូម្បីគ្រាន់តែនិយាយពាក្យអាក្រក់ គឺវចីទុច្ចរិតណាមួយ ក៏គង់ បានសេចក្តីវិនាសពុំខាន ៗ

កាលបើសាធុសប្បុរសទាំងឡាយ ប្រាថ្នាចង់បានសេចក្ដីសុខ សេចក្ដីចំរើន គួរតែស្រឡាញ់ធម៌ គឺប្រព្រឹត្តតាមសុចរិតធម៌ ព្រោះសុចរិតធម៌ ជាឧបាយនៃសេចក្ដីចំរើន, ទុច្ចរិតធម៌ជាប្រធាននៃសេចក្ដីវិនាស ។

សំដែងមកអំពីករបុគ្គលទឹងបកករបុគ្គលកំល្មមនឹងបញ្ចប់តាមគួរដល់កាលវេលាហើយ តែមុននឹងបញ្ចប់នេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រះប្រិយមហាក្សត្រ ទ្រង់ជាប្រមុខរបស់ប្រជាជន កម្ពុជរដ្ឋ នៅអស់លោកនាម៉ឺនសព្វមុខមន្ត្រីគ្រប់តំណែង សូមទ្រង់បានប្រកបនឹងសូមឲ្យបានប្រកបដោយសិរីសុខមហាសម្បត្តិ ព្រមទាំងសូមឲ្យខេមរជនកម្ពុជរដ្ឋទាំងមូល ដល់នូវសេចក្ដីលូតលាស់ក្នុងអារ្យធម៌កុំបីអាក់ខានឡើយ ។

## ផ្នែកអក្សរសាស្ត្រ

### ប្រវត្តិការណ៍ខ្មែរបុរាណ

# លោកមាស-ធាត់ ឃោសកៈនៃក្រុមឃោសនាការកម្ពុជា

ដកស្រង់ពីសៀវភៅ ភូមិសាស្ត្រ – ប្រវត្តិសាស្ត្រ ភាសាថៃ

---

«ក្នុងគ្រាដែលព្រះមហាក្សត្រិយ៍ខ្មែរ វង្សសុរិយវរ្ម័នបានគ្រងរាជ-សម្បត្តិក្នុងប្រទេសកម្ពុជា រវាងពុទ្ធសករាជ ១៥៤៥-១៧២៥ ខម(ខ្មែរ) បានផ្សាយអំណាចចូលទៅគ្រប់គ្រងដែនដី ដែលជាប្រទេសថៃសព្វថ្ងៃនេះទាំងអស់ បានតាំងរាជធានីសម្រាប់ចាត់ការគ្រប់គ្រង ទីក្រុងនានាក្នុងប្រទេសជាច្រើនកន្លែង គឺ

ក្រុងលពបុរី សម្រាប់គ្រប់គ្រងបណ្តាទីក្រុងដទៃ ដែលនៅតាមភូមិភាគខាងត្បូងនៃរាជអាណាចក្រទ្វារាវតី,

ក្រុងសុខោទ័យ សម្រាប់គ្រប់គ្រងទីក្រុងនានា ដែលនៅតាមភូមិភាគខាងជើងនៃរាជអាណាចក្រទ្វារាវតី,

ក្រុងសិរីទេព សម្រាប់គ្រប់គ្រងទីក្រុងនានា ដែលនៅតាមភូមិភាគជួទំនាបដីទន្លេសាក់,

ក្រុងភីម៉ាយ សម្រាប់គ្រប់គ្រងទីក្រុងនានា ដែលនៅលើទីដីខ្ពស់ភាគខាងត្បូង,

ក្រុងសាកលនគរ សម្រាប់គ្រប់គ្រងក្រុងនានា ដែលនៅលើទឹកដីដ៏ខ្ពស់ភាគខាងជើង ។

បណ្ដាទីក្រុងបុរាណរបស់ខ្មែរ(ខ្មែរ)ទាំងនេះ ទីក្រុងលពបុរីជាទីក្រុងសំខាន់បំផុតក្នុងសម័យនោះ ។ ខាងបុរាណគតិ គេហៅសម័យដែលខ្មែរមានអំណាចគ្រប់គ្រងប្រទេសនេះ ថា "សម័យលពបុរី" ។

ព្រះមហាក្សត្រិយ៍ ទីងប្រជាជនខ្មែរកាន់ពុទ្ធសាសនាលទ្ធិមហាយាន ដែលបានចម្លងមកអំពីកោះសុមាត្រា ។

តែអំណើះតមកជាយូរអង្វែងឆ្នាំ ខ្មែរបានផ្ដួចផ្ដើមបង្កើតសិល្បកម្មរបស់ខ្លួនឡើង ដែលមានលំនាំខុសអំពីបែបភាពដែលបានទទួលមកអំពីឥណ្ឌូនេស៊ីកោះសុមាត្រា ទើបកើតរបៀបជាងមួយត្រកូលឡើង ហៅថា សម័យស្នាដៃខមែ(ខ្មែរ)។ កាលដែលខ្មែរបានគ្រប់គ្រងដែនដីដែលជាប្រទេស (ថៃសព្វថ្ងៃនេះទាំងអស់) ខ្មែរក៏បានកសាងវត្តអារាមទីងទេវស្ថានជាច្រើន ដែលគេហៅថា ប្រសាទថ្ម ដូចយ៉ាងប្រសាទថ្មស្រុកភីម៉ាយ ប្រសាទថ្មភ្នំរុងជាដើម ។ វត្តអារាមក្នុងព្រះពុទ្ធសាសនា ដែលជាស្នាដៃរបស់ខ្មែរសាងឡើងក្នុងសម័យនោះ ច្រើនជារបៀបមហាយាន; ក្រៅអំពីបុរាណស្ថានផ្សេងៗ នៅមានបុរាណវត្ថុជាច្រើនបែបទៀត ដូចយ៉ាងព្រះពុទ្ធរូប, ព្រះពោធិសត្វរូបទីងទេវរូបជាដើម" ។

ដែនដីក្នុងភូមិភាគដូចបានរៀបរាប់មកហើយនេះ គឺជាកេរ្តិ៍ដំណែលរបស់បុព្វបុរសខ្មែរយើងពីដាន់ដើម ដែលលោកខំចំណាយសាច់ឈាម

ទឹងជីវិត ដើម្បីរួបរួមទុកឲ្យអនុជនគឺយើងពលរដ្ឋសព្វថ្ងៃនេះ ។ គួរជនជាតិខ្មែរគ្រប់រូបចាំកេរ្តិ៍ដំណែលនេះទុកក្នុងដួងចិត្តគ្រប់ៗគ្នា កុំបីភ្លេចឡើយ ។

តាមសេចក្តីក្នុងសៀវភៅនោះពោលថា: ប្រជាជនដែលជាម្ចាស់ដែនដីត្រង់នេះ មិនបានកាន់លទ្ធិមហាយានតាមខមទាំងអស់ទេ មាននៅកាន់លទ្ធិហីនយានដែលជាប់តមកពីសម័យទ្វារវតីនោះក៏ច្រើនណាស់ដែរ គេបានឃើញសិលាចារឹកមួយនៅក្នុងអាណាខេត្រលពបុរី ដែលចារឹកជាភាសាខ្មែរ បានពោលថា " ក្នុងសម័យនោះ លពបុរីមានព្រះសង្ឃពីរនិកាយគឺ ស្ថវិរៈ ជានិកាយដើមដែលតំណមកអំពីសម័យទ្វារវតី, មហាយាន ជានិកាយដែលទើបនឹងរុងរឿងក្នុងសម័យដែលខមចូលមកមានអំណាចគ្រប់គ្រងលើដែនដីភូមិភាគត្រង់នេះ (គឺប្រទេសថៃសព្វថ្ងៃនេះឯង)" ។ តាំងពីលទ្ធិមហាយានចំរើនរុងរឿងក្នុងប្រទេសនេះកាលគ្រានោះ គេបានចារឹកធម្មវិន័យជាភាសាសំស្ក្រឹតជំនួសភាសាមគធៈដែលគេធ្លាប់ប្រើមក តាំងពីមុនលទ្ធិមហាយានចូលមកនោះ ។

---

# អក្សរសាស្ត្រខ្មែរសង្ខេប

## លោកប៉ាយ-ប៊ុក ក្រុមការដើមខ្សែលេខពីរ

### ប្រែនិងរៀបរៀង

(តមក)

---

ព្រះពុទ្ធសាសនាខាងហីនយាននេះឯង ដែលផ្សាយចេញពីកោះសីឡង់ទៅកាន់ប្រទេសថៃ ហើយបានចូលមកប្រតិស្ឋាននៅប្រទេសកម្ពុជា រាតសកម្មភាពទៅគ្រប់និគមជនបទស្រុកខែត្រភូមិភាគ ទាល់តែព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាខាងឧត្តរនិកាយ (និកាយខាងជើង) ដែលហៅថា មហាយាន ប្រើភាសាសំស្ក្រឹត និងព្រះពុទ្ធសាសនាខាងហីនយាន ប្រើភាសាសំស្ក្រឹតចុះអន់ទន់ខ្សោយតាមលំដាប់ ។ អក្សរចារឹកទំនើបនេះ គឺមានលក្ខណៈទៅតាមលំនាំ នៃអក្សរសាស្ត្រខ្មែរពិតៗ ដែលពណ៌នាអំពីបូជនីយដ្ឋាន, ពិធីបុណ្យព្រះពុទ្ធសាសនា, មហាជាតក ឬ ពុទ្ធប្រវត្តិ បានបញ្ចេញឲ្យយើងឃើញច្បាស់ពិតប្រាកដនូវវប្បធម៌អក្សរសាស្ត្រ ប្រទេសកម្ពុជាសម័យទំនើប ។ មានអក្សរចារឹកនៅសសរប្រាសាទអង្គរវត្តមួយនោះ មានកាលបរិច្ឆេទតាំងពី គ. ស. ១៧០២ ។

ក្រៅពីសិលាចារឹកអង្គរវត្តដែលលោកស្យ - សីដេស បានប្រែរួបរួមពីសតវត្ស ទី ១៥ ដល់សតវត្ស ទី ១៨, នៅមានអក្សរសាស្ត្រប្រភេទពាក្យកាព្យ និងប្រភេទពាក្យរាយទៀត គឺ

## អក្សរសាស្ត្រប្រភេទពាក្យកាព្យ

១) រឿងខ្យងស័ង្ខ និពន្ធក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជយជេដ្ឋា ពីថ្ងៃ ៥ ៗ ៨ ៦ ឆ្នាំរកា ម.ស. ១៦១៥ គ.ស. ១៦៩៣ ជាច្បាប់សាស្ត្រស៊ីកតែ, អ្នកតែងមិនស្គាល់ឈ្មោះ ។

២) ប្រជុំពាក្យកាព្យ អ្នកតែងមានឈ្មោះផ្សេងៗ មានព្រះរាជនិពន្ធព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសម្ភារជាដើម, អ្នកនិពន្ធឯទៀតមិនស្គាល់ឈ្មោះ, តែងក្នុងរវាងសតវត្ស ១៧ ១៨;

៣) ច្បាប់ចាស់ របស់ព្រះអង្គសដ្ឋា ទ្រង់និពន្ធក្នុង ព.ស. ២២៦៦ (គ.ស. ១៧២៣) ជាសាស្ត្រស៊ីកតែ;

៤) ច្បាប់សុភាសិត របស់ឧកញ៉ាវង្សាសារពេជ្ជនង និពន្ធពីថ្ងៃ ២ ១៥ ៗ ៨ ឆ្នាំច ម.ស. ១៧១២ (គ.ស. ១៧៩០);

៥) លោកនេយ្យជាតក របស់ឧកញ៉ាវង្សាក្សត្រីនង រជ្ជកាលព្រះនារាយណ៍រាជាព្រះអង្គអេង, តែងក្នុងថ្ងៃ ៤ ៗ ១៥ ១០ ឆ្នាំខាលសំរឹទ្ធិស័ក ព.ស. ២៣៣៧, ម.ស. ១៧១៦, គ.ស. ១៧៩៤ ជាច្បាប់សាស្ត្រស៊ីកតែ;

៦) រឿងបុញ្ញាសាសិរិសា របស់ឧកញ៉ាវង្សាក្សត្រីនង, រជ្ជកាលព្រះនារាយណ៍រាជា (ព្រះអង្គអេង) តែងក្នុងថ្ងៃ ៦ ៗ ៨ ១១ ឆ្នាំម្សាញ់ ម.ស. ១៧១៩ គ.ស. ១៧៩៧ សាស្ត្រស៊ីកតែ;

៧) ប្រជុំពាក្យកាព្យ អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរវាង សតវត្សទី ១៨-១៩ ;

៨) រឿងភោគកុលកុមារ របស់ឧកញ៉ាព្រះឃ្លាំងនង តែងក្នុង ម.ស ១៧២៦ ព.ស. ២៣៤៧ គ.ស. ១៨០៤ ជាច្បាប់សាស្ត្រាស្លឹករឹត;

៩) រឿងវិរនុជវិរនេត្រ របស់ឧកញ៉ាពៅហ្វាយ ឃ្លាំង-មៀប តែងក្នុងថ្ងៃ ១៥ ៗ ១២ ម.ស. ១៧២៨ ព.ស. ២៣៤៩ គ.ស. ១៨០៦ ជាច្បាប់សាស្ត្រាស្លឹករឹត;

១០) រឿងកាកី ព្រះរាជនិពន្ធព្រះបាទសម្តេចព្រះហរិរក្សរាមា ព្រះអង្គឌួង ទ្រង់និពន្ធក្នុង ព.ស. ២៣៥៨ គ.ស. ១៨១៥ ជាច្បាប់សាស្ត្រាស្លឹករឹត;

១១) រឿងទេវ័ន្ទ របស់លោកអម្ពុតក្សត្រីម៉ុក តែងក្នុង ព.ស. ២៤០២ - គ.ស. ១៨៥៩ ជាច្បាប់សាស្ត្រាស្លឹករឹត;

១២) រឿងវិមានចន្ទ របស់ឧកញ៉ាបញ្ញាធិបតី យ៉ែម ពៅ ក្រមអាល័ក្ស តែងក្នុង ព.ស. ២៤០៨, គ ស ១៨៦៥ ជាច្បាប់សាស្ត្រាស្លឹករឹត;

១៣) រឿងពៅមាស របស់ឃុនសុន្ទរពិនិត្យ តែងក្នុងថ្ងៃ ៣ ៗ ៦ ឆ្នាំចសំរិទ្ធិស័ក ព.ស. ២៤៣០, គ.ស. ១៨៨៧ ជាច្បាប់សាស្ត្រាស្លឹករឹត;

១៤) កាព្យសារវិលាសិនី ក្បួនតែងកាព្យឃ្លោងផ្សេងៗ របស់ ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ កាលនៅធ្វើការឯបាត់ដំបងក្នុងគោរម្យងារជាទីហ្លួងវិចិត្រវោហារ ឥន្ទ តែងក្នុងរវាង ព.ស. ២៤៣២ (១៨៨៩) ។

១៥) រឿងសព្វសិទ្ធិ របស់ហ្លួងភក្តីអក្សរ គង់ តែងក្នុង ថ្ងៃ ៣ ១០ ៗ ១ ឆ្នាំកុរ ឯកស័ក ព.ស. ២៤៤២ គ.ស. ១៨៩៩ ជាច្បាប់សាស្ត្រាស្លឹករឹត (កាព្យពាក្យ ៧);

## អក្សរសាស្ត្រប្រភេទពាក្យរាយ

១) ព្រះរាជក្រឹត្យក្រមផ្សេងៗ អ្នកនិពន្ធមិនស្គាល់ឈ្មោះតែងក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះជ័យជេស្ឋា រវាង ម.ស. ១៦១៥ ឬ ១៦១៩ - គ.ស. ១៦៩៣ ឬ ១៦៩៧ ជាច្បាប់សាស្ត្រាស្លឹករឹត;

២) រឿងបឋមសម្ពោធិ អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរវាងសតវត្សទី ១៨ - ១៩ ច្បាប់សាស្ត្រាស្លឹករឹត ។

៣) រឿងទសជាតក៍ អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងរវាងសតវត្សទី ១៨-១៩ ច្បាប់សាស្ត្រាស្លឹករឹត ។

៤) ព្រះរាជក្រិត្យក្រមចៅហ្វាយស្រុក អ្នកនិពន្ធមិនស្គាល់ឈ្មោះ តែងក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាព្រះអង្គចន្ទ តែងក្នុង ព. ស. ២៣៧២ គ. ស. ១៨២៩ ជាច្បាប់សាស្ត្រាស្លឹករឹត ។

៥) ព្រះរាជក្រិត្យក្រមផ្សេង ៗ អ្នកនិពន្ធមិនស្គាល់ឈ្មោះ,

តែងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គឌួង, តែងរវាង ច.ស. ១២១២ ឬ ១២១៥ · គ.ស. ១៨៣៥ ឬ ១៨៣៨ ។

៦) ព្រះរាជក្រឹត្យក្រមផ្សេងៗ អ្នកនិពន្ធមិនស្គាល់ឈ្មោះតែងក្នុងរជ្ជកាលសម្តេចព្រះបាទនរោត្តម រវាង ច.ស. ១២៣៥-១២៣៨ គ.ស. ១៨៧៦-១៨៧៨ ។

៧) គតិលោក របស់លោកឧកញ៉ាសុត្តន្តប្រីជា "ឥន្ទ" តែងចប់នៅថ្ងៃ ៥ ៗ ១១ ឆ្នាំរកាតោស័ក ព.ស. ២៤៦៤, គ.ស. ១៩២១ ។

ក្រៅពីនេះ, មានរឿងព្រេង, ប្រលោមលោក, ចម្រៀង, កាព្យនិទាន, កវីនិពន្ធ ។ល។

## គ) សម័យបច្ចុប្បន្ន

ពី គ.ស. ១៨៦៣ មកដល់សព្វថ្ងៃ

សម័យបច្ចុប្បន្ន មានអក្សរសាស្ត្រជាភាសាបាលី, ខ្មែរ, ជាពាក្យពាយ និង ជាពាក្យកាព្យ, ហើយមានចំរុះទាំងពាក្យពាយនិងពាក្យកាព្យក៏មាន, មានអក្សរសាស្ត្រខាងពុទ្ធសាសនា, គុណការ, បច្ចេកទេស, ប្រវត្តិសាស្ត្រ, ល្ខោនខ្មែរ, ចម្រៀង, រឿងព្រេង, ប្រលោមលោក ។ល។ ។

១_ អក្សរសាស្ត្រខាងពុទ្ធសាសនា, អក្សរសាស្ត្រនេះមាននិពន្ធទាំងភាសាបាលី ទាំងភាសាខ្មែរ, តែភាសាបាលីដែលគេសរសេរនៅប្រទេសកម្ពុជាជាតួ "មូល" ។ ភាសាបាលីដែលជាភាសាសាសនានៅកោះស៊ីឡង់, ប្រទេសសៀម, ភូមា និងលាវ គេ

សរសេរនិយមទៅតាមភាសានិងអក្សរប្រទេសនោះៗ ។ អក្សរសាស្ត្រពុទ្ធសាសនា គឺព្រះត្រៃបិដក មានជាសេចក្តីប្រែនិងអត្ថាធិប្បាយជាអក្សរខ្មែរ ព្រមទាំងជាភាសាបាលី ចំពោះត្រង់អត្ថបទណាដែលគេនិយមចង់ដឹងជាងគេ ។ អត្ថបទនិងសៀវភៅខាងព្រះពុទ្ធសាសនានេះព្រមទាំងគម្ពីរស៊ុករឹត ឬក្រាំងជាច្រើន ព្រះសង្ឃបានរក្សាទុកនៅបណ្ណាល័យគន្ថៈ; មានអត្ថបទខ្លះតែងតាំងពីចុងសតវត្សទី ១៨ ឬដើមសតវត្សទី ១៩ ។ ក្រៅពីព្រះត្រៃបិដក មានធម៌សម្រាប់សូត្រនិងគម្ពីររយជាច្រើន ព្រមទាំងជាតក ។ គន្ថបំណាមជាតកទាំងអស់, ជាតកដែលសំខាន់ជាងគេ គឺព្រះវេស្សន្តរដែលព្រះពោធិសត្វបានបំពេញពុទ្ធការកធម៌ដោយធ្វើទានបរមត្ថបារមី គឺអំណោយព្រះអគ្គមហេសីព្រះនាងមទ្រី និងព្រះរាជបុត្រាព្រះរាជបុត្រីជាលី, ក្រឹស្នា ។ ចំណែកខាងនិពន្ធបច្ចេកទេស, គឺសម្រេចបទៅនិងលទ្ធិពុទ្ធសាសនាបឋមសម័យដែលមានមូលដ្ឋានត្រង់អនិច្ចំ, ទុក្ខំ, អនត្តា, ចតុរារិយសច្ច ។

អក្សរសាស្ត្រខាងព្រះពុទ្ធសាសនាសព្វថ្ងៃ កំពុងតែចម្រើនពេញលក្ខណៈ, មានសៀវភៅគប់បែបគប់យ៉ាង ដែលអ្នកនិពន្ធបានយកអត្ថបទគន្ថព្រះពុទ្ធសាសនា គឺព្រះត្រៃបិដកមករៀបតាមគន្ថធម៌, តាមរឿងជាតក, តាមសីល, សមាធិ, បញ្ញា . . . ។ល។

២– **អក្សរសាស្ត្រខាងតុលាការៈ** មានការតែងច្បាប់ក្រមព្រហ្មទណ្ឌ, ច្បាប់រដ្ឋប្បវេណី, ច្បាប់ក្រមពិភាក្សាព្រហ្មទណ្ឌ, ច្បាប់រាជនីតិ ។ ច្បាប់ទាំងអស់នេះ តែងឡើងប្រហែលមុនសតវត្សទី

១៧ ខ្លះ តែគេបានយកមកកែសម្រួលទៅតាមសម័យ, តាមកាលៈទេសៈ, តាមនិយម ។ អត្ថបទនេះ ជាសេចក្ដីដកស្រង់យកពីព្រះរាជក្រមនឹងព្រះរាជក្រឹត្យព្រះមហាក្សត្រិយ៍ តាមព្រះរាជសន្តតិវង្សជាតំណតមកក្រោយដែលបានសម្រេចពីក្រមគុណការជាន់ខ្ពស់ ។ សេចក្ដីទាំងនេះគេបានដកស្រង់យកពីធម្មសាស្ត្របុរាណសំស្ក្រឹតខ្លះ, សីលធម៌បុរាណខ្មែរខ្លះ, ច្បាប់ព្រះពុទ្ធសាសនាខ្លះ ប្រមូលរួបរួមយកមកធ្វើអត្ថាធិប្បាយជាច្បាប់អនុវត្តន៍ទៅតាមទោសកំហុស ។ ក្រៅពីនេះ, មានច្បាប់ក្រម, កេរ្តិ៍កាល, ត្រីនេត្រ, ពាក្យចាស់, វិធូរបណ្ឌិត ។ល។ សម្រាប់ប្រដៅជនប្រុសស្រីឲ្យយល់ករណីយកិច្ចរបស់ខ្លួន, សីលធម៌, ការបម្រើន, កាតព្វកិច្ច ដែលជាពាក្យសុភាសិត ឬ បាវចនា ។

៣– អក្សរសាស្ត្របច្ចេកទេស: មានអត្ថបទតូចៗដែលពណ៌នាអំពីក្បួនវេជ្ជសាស្ត្រ, ហោរាសាស្ត្រ, គាថាសាស្ត្រ, តម្រានុសាថ, និម្មាបនកម្ម, លោកវិទ្យា, ចក្រវាឡវិទ្យា, លោកធាតុវិទ្យា, ធរណីសាស្ត្រ . . . ល . . ។ គេបានឃើញចំពោះអត្ថបទទាំងនេះ មានតម្រានុសាថ ៨៣ យ៉ាង, ការបង្កើតលោក, រឿងទេវតា . . . ល . . . ។ ក្រៅពីនេះ មានរឿងទំនៀមទម្លាប់ប្រពៃណីនិយម, វេយ្យាករណ៍, ភាសាសាស្ត្រ . . . ល . . . ។

៤ ប្រវត្តិសាស្ត្រ.– ប្រវត្តិសាស្ត្រជាឯកសារនៃត្រៃសារ, វត្តអារាម, នឹងជាព្រះរាជពង្សាវតារព្រះបរមរាជវាំង ។ ឯកសារនេះមាន

ច្រើនតែពិធីបុណ្យ, ចំណែកឯព្រឹត្តិការណ៍នយោបាយមិនសូវមាន, បើមានច្រើនតែធ្វើសង្ខេបបីបួនបន្ទាត់ ។ ប្រវត្តិសាស្ត្រនេះ, បើតាមខ្ញុំពិនិត្យមើល, ឃើញមាននិពន្ធមកតាំងពី ព. ស. ២៣៩៥ គ. ស. ១៧៦២ ។ អ្នកនិពន្ធពេលនោះ គ្មានឯកសារអ្វីជាមូលដ្ឋានទេ គឺធ្វើតាមរឿងព្រេងបុរាណ តាមពាក្យដែលនិយាយពីមាត់មួយទៅមាត់មួយ ឥតមានគោលចារឹកសោះ ។ លុះមកដល់រជ្ជកាលព្រះបាទសម្តេចព្រះអង្គឌួងទ្រង់បានត្រាស់បង្គាប់ក្រុមព្រះអាល័ក្សឲ្យធ្វើព្រះរាជពង្សាវតារ ប្រទេសកម្ពុជា ។ តែព្រះរាជពង្សាវតារនេះ គឺធ្វើពីរជ្ជកាលព្រះបាទសម្តេចព្រះបរមនិព្វានបទ មកដល់រជ្ជកាលព្រះបាទសម្តេចព្រះឧទ័យ ។ លំដាប់តមក, ព្រះបាទសម្តេចព្រះនរោត្តមទ្រង់មានព្រះរាជឱង្ការ ឲ្យឧកញ៉ា-បញ្ញាធិបតី យ៉ែម និងឧកញ៉ាសន្ធរពេហារ មុក ឲ្យធ្វើព្រះរាជពង្សាវតារខ្មែរ ។ លុះមកដល់ថ្ងៃ ១៤ រោច ខែមិគសិរ ឆ្នាំថោះ ព. ស ២៤៤៥ ត្រូវនឹងថ្ងៃទី ២៧ មីនា ១៩០៣ ទ្រង់ត្រាស់បង្គាប់ឲ្យឧកញ៉ាពង្សវរៈវៀងជ័យ ជួន ប្រមូលឯកសារប្រវត្តិសាស្ត្រដែលមាននៅក្នុងក្រុមព្រះអាល័ក្សនិងក្រុមព្រះរាជនិពន្ធ, ហើយស្ថាបនានូវគណៈកម្មការមួយដើម្បីរៀបចំធ្វើព្រះរាជពង្សាវតារប្រទេសកម្ពុជា ។ តែក្នុងពេលនោះ, គណៈកម្មការមិនទាន់រៀបចំចូលជំនុំជាលើកដំបូងនៅឡើយ, ស្រាប់តែព្រះបាទនរោត្តមទ្រង់ព្រះទិវង្គតទៅ ។

លំដាប់តមក, ព្រះបាទសម្តេចព្រះស៊ីសុវត្ថិទ្រង់មានព្រះរាជឱង្ការនូវព្រះបន្ទូលសូរសីហនាទចំពោះឧកញ៉ាវង្សាអគ្គរាជ ឌុច ឲ្យរើធ្វើព្រះរាជ-

ពង្សាវតារជាថ្មី ៗ ក្រោយទៀត, បានលោកហ្សត្រ ម៉ាស្ប៉េរ៉ូ អតីតរេស៊ីដង់សុប៉េរីយើរ ប្រទេសកម្ពុជា បានសុំព្រះអង្គម្ចាស់ការទុវង្ស អគ្គមហាសេនាបតី ឲ្យលៃលកកែថែមសេចក្ដីទៅតាមឯកសារដែលស្រាវជ្រាវបានមក ៗ តែប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក៏មិនទាន់មានសភាពពិតនៅឡើយ ៗ

យោបល់ខ្ញុំ ខ្ញុំយល់ថា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា មានប្រភពបី :

ប្រភពទី ១ – ប្រវត្តិសាស្ត្រខ្មែររបស់សម្ដេចចៅហ្វាកាំង ជួន;

ប្រភពទី ២ - ប្រវត្តិសាស្ត្រខ្មែរជាអក្សរសៀមរបស់ព្រះរាជបណ្ណាល័យ វជិរញ្ញាណ, អ្នកនិពន្ធនាមលោកចាងហ្វាងត្រីព្រះយ៉ាក្រពេជ្ររតនៈសង្គ្រាមក្រុងទេព បាងកក ( ប្រទេសថៃ );

ប្រភពទី ៣ គឺ សិលាចារិកនឹងឯកសារប្រទេសចិន ពីសម័យបុរាណ ៗ

បើស្រាវជ្រាវឲ្យធំទូលាយជាងនេះទៅទៀតមាន ៧ ប្រភពទៀតគឺ

ក ) ព្រះរាជពង្សាវតាររបស់ព្រាហ្មណ៍ ដែលជាអ្នករក្សាទុកមានន័យតាំងពីព្រះពុទ្ធទំនាយ តមកដល់ព្រះរាជវង្សព្រះមហាក្សត្រិយ៍ ទេវង្សអស្ចារ្យ, ព្រះកេតុមាលានឹងព្រះបទុមវរវង្ស;

ខ ) ព្រះរាជពង្សាវតារជាតៃថខាងជើង ដែលដកស្រង់យកមកពីទំនាយព្រះកែវ មានសេចក្ដីពិស្ដារពោលពីសន្តតិវង្សព្រះបាទទុទ្ឋយរាជទៅដល់ព្រះបាទបទុមសុរិយវង្ស;

គ) សៀវភៅរតនកិមវង្ស ដែលមានសេចក្តីពោលពីព្រះរាជវង្ស ព្រះបាទធនញ្ជយកោរព្យៈរាជ មកដល់រជ្ជកាលព្រះបាទសេនករាជទឹង ព្រះសិង្ហកុមារ;

ឃ) "ឫស្សីទំនាយ" ដែលពោលតាំងពីព្រះរាជវង្សព្រះបាទស័ង្ខចក្រ, ព្រះចក្រពត្រាធិរាជ ព្រះបាទបក្សីចាំក្រុង រហូតដល់ទៅព្រះបាទតាត្រសក់ផ្អែម;

ង) ព្រះរាជពង្សាវតារខែខាងដើមទឹងលាវ ដែលអធិប្បាយតាំងពីព្រះរាជវង្សព្យាក្រែក ឬ ព្រះបាទដំបងក្រញូងនឹងព្រះបាទបក្សីចាំក្រុង;

ច) គម្ពីរបុរាណដែលពណ៌នាពីព្រះរាជពង្សាវតារនេះដែរ;

ឆ) តាមពាក្យចាស់បុរាណព្រឹទ្ធាចារ្យ, អ្នកដែលមានវ័យចំរើន ឬអ្នកដែលចេះដឹងប្រវត្តិសាស្ត្របុរាណ ឬអ្នករៀនរន្ទេញចាំពីសៀវភៅផ្សេងៗ ។

បើយើងប្រៀបមើលប្រភពទាំងអស់, ឃើញតែប្រភពសិលាចារឹកមួយទេដែលគួរទុកជាបានការ ។

(មានត)

## ពេជ្រព្រះរាជា

# លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង
# លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

''ថ្ងៃស្អែកខ្ញុំនឹងធ្វើពិធីបុណ្យប្រសិទ្ធិវិជ្ជាដល់ពួកអ្នក ដែលរៀនវិជ្ជានឹងខ្ញុំ ដូច្នេះ ខ្ញុំសូមឲ្យពួកអ្នកគ្រប់គ្នាជួយខ្វល់ខ្វាយផង ព្រោះព្រឹកនេះខ្ញុំនឹងនិមន្តភិក្ខុសង្ឃមកឆាន់អាហារនៅនឹងផ្ទះខ្ញុំនេះ ហើយយប់ឡើងសូត្រមន្តដើម្បីឲ្យជាសិរីមង្គលដល់ពួកអ្នកជាសិស្ស តែបើអ្នកណាមិនចង់បាននូវសិរីមង្គលដល់ខ្លួនទេ នឹងមិនមកក៏បាន'' ។

បណ្ដាសិស្សទាំងឡាយ ដែលបានឮពាក្យរបស់សុរពលជាអាចារ្យហើយ មិនមានសិស្សណាម្នាក់ហ៊ានជំទាស់ទេ ។

ព្រឹកឡើង ព្រះភិក្ខុសង្ឃនិមន្តមកដល់ផ្ទះសុរពល ។ សិស្សរបស់សុរពលដែលកាន់អានព្រះពុទ្ធសាសនា បានចាត់ចែងអាហារពីផ្ទះខ្លួនយកមកប្រមូលនឹងអាហាររបស់សុរពល ។ មានសិស្សរបស់សុរពលម្នាក់ឈ្មោះ សញ្ជ័យ ជាបុត្ររបស់ព្រាហ្មណ៍ មាត់អាក្រក់ទាំងស្វាមីនិងភរិយា, សិស្សនេះបានលួចលាក់ផ្លែឈើមួយថាសធំផ្ញើនឹងមិត្រភក្ដិ ដោយមិនឲ្យមាតាបិតាដឹង ហើយសូមអនុញ្ញាតពីបិតាមាតាចេញមកជាខាងក្រោយ ដោយជំរាបមាតាបិតាថា នឹងនាំប្អូនតូចម្នាក់ទៅដើរលេង, បិតាមាតាក៏អនុញ្ញាត តែហាមថាកុំឲ្យទៅវិរជិតជិតនឹងភិក្ខុសង្ឃដែល

សុពេលទិមន្តមក ។ សញ្ជ័យក៏ទទួលពាក្យមាតាបិតា តែដោយសេចក្តីគោរពអាចារ្យ នឹងដោយនិស្ស័យរក់សនាផ្ទុយពីបិតាមាតា ក៏ត្រឡប់ជាមិនធ្វើតាមបង្គាប់វិញបានលបដើរជាមួយនឹងមិត្តភក្តិមកផ្ទះសុពេល ហើយក៏យកថាសពេញដោយផ្លែឈើនោះទៅជូនសុពេល ហើយដំកបដោយសេចក្តីគោរពថា:

– "ខ្ញុំបាទនាំផ្លែនេះមកចូលបុណ្យផង លោកអាចារ្យ!" ។

សុពេលស្គាល់ចិត្តថ្មើមសិស្សនេះថា ជាអ្នកកាន់សាសនាព្រាហ្មណ៍កាលឃើញសិស្សនេះនាំថាសផ្លែឈើមកឲ្យនោះ នឹកស្មានថាក្រែងយកមកឲ្យទាំងទើសទាល់ ទើបប្រាប់ថា:

– "សញ្ជ័យ! ដែលអ្នកឯងយកផ្លែឈើមកឲ្យខ្ញុំនេះ ខ្ញុំត្រេកអរណាស់ហើយ តែអាហាររបស់ខ្ញុំដែលសម្រាប់ប្រគេនព្រះភិក្ខុសង្ឃ នឹងសម្រាប់ជប់លៀងពួកអ្នកឯងសឹងមានគ្រប់គ្រាន់ឥតខ្វះទេ, ដូច្នេះផ្លែឈើនេះចូរអ្នកឯងយកទុកប្រគេនដល់សមណ:ខាងក្រៅទៅវិញចុះ" ។

សញ្ជ័យកាលបានឮសុពេលនិយាយដូច្នោះ ក៏តូចចិត្តឈរបែរមុខមិននិយាយតបវិញ ។

– "អ្នកឯងមិនពេញចិត្តឬ?" សុពេលសួរបញ្ជាក់ដោយឃើញកិរិយាស្ងៀមស្ងាត់របស់សញ្ជ័យ ។

– "បាទ លោកអាចារ្យ! លោកបានប្រាប់ខ្ញុំបាទថា ការធ្វើពិធីបុណ្យនេះ ដើម្បីជាសិរីមង្គលដល់ខ្ញុំៗ ទើបបានប្រឹងប្រៀបផ្លែឈើនេះ

យកមកចូលបុណ្យផង ដូច្នេះ សូមលោកអាចារ្យទទួលវត្ថុរបស់ខ្ញុំនេះដោយសេចក្ដីអនុគ្រោះ" ។

សុរពលកាលបានស្ដាប់ពាក្យសញ្ជ័យហើយ ក៏មានសេចក្ដីពេញចិត្តទើបទទួលថាសផ្លែឈើនោះ យកទៅឲ្យបិតាចាត់ការរៀបផាក់គាជន៍ប្រគេនព្រះភិក្ខុសង្ឃ ។ កាលព្រះភិក្ខុសង្ឃឆាន់អាហារស្រេចហើយ សុរពលបានបង្គាប់សិស្សគ្រប់គ្នា ឲ្យមករួមនៅត្រង់លានផ្ទះ ខ្លួនគេឈរនៅត្រង់កណ្ដាលពួកសិស្ស ហើយប្រាប់សិស្សទាំងនោះថា:

– "ថ្ងៃនេះ ខ្ញុំមានចិត្តត្រេកអរពន់ពេកចំពោះពួកអ្នកជាសិស្សដែលបានព្រមព្រៀងគ្នាមកជួបជុំក្នុងទីនេះ; ខ្ញុំដែលតាំងផ្ដើមធ្វើបុណ្យនេះឡើង ដើម្បីជាសិរីមង្គលដល់បណ្ដាអ្នកជាសិស្ស ឥឡូវនេះ ខ្ញុំសូមឲ្យអ្នកជាសិស្សទាំងឡាយ ប្រុងប្រៀបរៀបចំខ្លួនទទួលគូរសិរីមង្គលដែលខ្ញុំនឹងឲ្យ" ហើយសុរពលនិមន្តព្រះភិក្ខុសង្ឃឲ្យប្រោះព្រំទឹកមន្តដល់សិស្សគ្រប់គ្នា ។

កាលព្រះភិក្ខុសង្ឃត្រឡប់ទៅកាន់អាវាសរបស់លោកហើយ ពួកសិស្សរបស់សុរពល បានទទួលអញ្ជើញការដប់លៀងពីសុរពល លុះបរិភោគរួចហើយ ក៏នាំគ្នាអង្គុយជាពួក ៗ ជជែកគ្នាយ៉ាងសប្បាយ ។ សុរពលចាំស្ដាប់សំដី តើនឹងមាននរណានិយាយយ៉ាងដូចម្ដេចខ្លះ ៗ ក្នុងឱកាសនោះ សញ្ជ័យ បានចូលទៅជិតសុរពលហើយដំកបថា:

– "លោកអាចារ្យ ! ឲ្យខ្ញុំបាទសុំថាសវិញផង មួយទៀតខ្ញុំបាទ

មានសេចក្ដីសង្ស័យមួយ, សូមលោកអាចារ្យដោះប្រស្នានោះឲ្យខ្ញុំបាទបាត់ពិកាល់ តើបានឬទេ?" ។

—"បាន, មានសេចក្ដីសង្ស័យដូចម្ដេចសួរមកខ្ញុំចុះ ខ្ញុំតបបានក៏នឹងតបជូន បើតបមិនបានទេ ខ្ញុំក៏ប្រាប់ថាមិនបាន" និយាយហើយសុរពលក៏ចាប់ថាសហុបឲ្យ ។

—"លោកអាចារ្យ ដែលខ្ញុំសុំសួរលោកនេះ កុំថាខ្ញុំមើលងាយលោកឡើយ ព្រោះខ្ញុំបាទមានសេចក្ដីឆ្ងល់ខ្លាំងព្រាស្មៀមពុំបាន ទើបសុំសួរ, ការណ៍ដែលខ្ញុំបាទសង្ស័យនោះ គឺកាលពីម្សិលមិញ លោកអាចារ្យបានប្រាប់ពួកខ្ញុំបាទថានឹងឲ្យសិរីមង្គលដល់ពួកខ្ញុំបាទ ដោយធ្វើពិធីបុណ្យនេះ ហើយលោកអាចារ្យបានឲ្យពួកខ្ញុំបាទចាំទទួលទឹកមន្ដដែលព្រះភិក្ខុសង្ឃប្រោះព្រំឲ្យ ខ្ញុំបាទមានសេចក្ដីសង្ស័យថា សិរីមង្គលតើដូចម្ដេច?" ។

សុរពលបានស្ដាប់ពាក្យសួររបស់សញ្ជ័យ ក៏មានសេចក្ដីត្រេកអរ ព្រោះគេនឹងចាំឲ្យតែមានអ្នកសួរ គេនឹងឆ្លើយពន្យល់ឲ្យពួកសិស្សដឹងរឿងការដែលជាប់ទាក់ទងនឹងផ្លូវពុទ្ធសាសនា ដើម្បីឲ្យពួកសិស្សចុះចិត្តស៊ប់ចំពោះពុទ្ធសាសនា គេទើបតបថា៖

—"អើ! សញ្ជ័យ អ្នកឯងសង្ស័យនឹងសិរីមង្គលនោះគួរណាស់ហើយ ខ្ញុំស្មានថាមិត្តភក្ដិរបស់អ្នកច្រើនគ្នាទៀត ដែលសង្ស័យដូចអ្នកឯងដែរ ដូច្នេះខ្ញុំនឹងប្រាប់នូវសិរីមង្គល ដល់អ្នកនឹងពួកមិត្តអ្នកឲ្យបានដឹងក្នុងពេលនេះ" ។

និយាយនឹងសញ្ជ័យដូច្នេះហើយ សុរពលក៏ប្រាប់សិស្សទាំងអស់ឲ្យបានឮគ្រប់គ្នា :

– "នែ! អ្នកគ្រប់គ្នា ចូរចាំស្តាប់! ខ្ញុំនឹងដោះស្រាយប្រស្នាដែលសញ្ជ័យសួរខ្ញុំ" ។

ពួកសិស្សដែលកំពុងសន្ទនាគ្នាជាពួកៗ កាលបានឮហើយក៏បែរមុខត្រង់មករកសុរពល ។

–"ខ្ញុំបានប្រាប់អ្នកទាំងអស់គ្នាកាលពីថ្ងៃត្រង់ថា ខ្ញុំនឹងឲ្យសិរីមង្គលដល់ពួកអ្នក ហើយព្រះភិក្ខុសង្ឃក៏បានប្រោះព្រំទឹកមន្តឲ្យដល់ពួកអ្នក, ទឹកមន្តដែលព្រះភិក្ខុសង្ឃប្រោះព្រំឲ្យនោះឯងជាសិរីមង្គល, ពួកអ្នកគង់មានសេចក្តីសង្ស័យថាដូចម្តេចហៅថាសិរីមង្គល តែមិនហ៊ានសួរខ្ញុំ, ខ្ញុំសូមសរសើរសញ្ជ័យដែលមានសេចក្តីសង្ស័យហើយមិនបិទទុក, ការធ្វើដូច្នេះប្រពៃណាស់ ព្រោះកាលបើមិនពេញចិត្តរបស់ណាត្រូវប្រាប់ ឬសង្ស័យរបស់ណាត្រូវតែសួរ ទើបមានប្រយោជន៍ច្រើន, តទៅនេះពួកអ្នកសង្ស័យអ្វីសួរមកខ្ញុំចុះ ឬមិនពេញចិត្តអ្វីប្រាប់មកខ្ញុំចុះ; មុននឹងដោះស្រាយសិរីមង្គលដែលសញ្ជ័យសួរមកខ្ញុំ ខ្ញុំសុំសួរពួកអ្នកគ្រប់គ្នា តើបណ្តាអ្នកទាំងអស់គ្នា នរណាធ្លាប់បានឮពាក្យអាស្រូវកាសមកខ្លះទេ?" ។

ពួកសិស្សជំរាបថា បានធ្លាប់ឮមកហើយ ។

សុរពលត្រឡប់សួរសិស្សទាំងនោះទៀតថា "ពាក្យអាស្រូវសកាទាំងនោះ ជាសិរីមង្គលឬទេ?" ។

-"មិនមែនទេ លោកអាចារ្យ" សម្ដេចសិស្សគ្រប់គ្នាទទួលឡើងៗ ស្រពេលទើបនិយាយតទៅទៀត:

-"បើដូច្នោះ ពាក្យរបស់ខ្ញុំដែលថា សេចក្ដីសុខចូរមានដល់អ្នក, អ្នកចូរមានសតិបញ្ញា, ភ័យទាំងឡាយកុំបីបៀតបៀនអ្នក, សូមឲ្យអ្នកបានជាទីស្រឡាញ់របស់មនុស្សទាំងឡាយ, ពាក្យដែលខ្ញុំនិយាយមកទាំងនេះជាសិរីមង្គលឬទេ?" ៗ

-"ជាសិរីមង្គល លោកអាចារ្យ!" សម្ដេចពួកសិស្សតបត្រូវគ្នាៗ ស្រពេលញញឹមដោយសេចក្ដីត្រេកអរនឹងពួកសិស្ស ដែលយល់ត្រូវតាមការណ៍ពិត ទើបទឹករកពាក្យដែលប្រកបដោយសេចក្ដីពិតមកនិយាយពន្យល់តទៅទៀត:

-"ព្រះភិក្ខុសង្ឃស្បូត្រពុទ្ធមន្តនោះ ដោយចេតនាប្រសិទ្ធិពរចុះក្នុងទឹកដែលដាក់ក្នុងផ្តិលឬក្នុងក្អម ហើយបាចទឹកមន្តនោះប្រោះព្រំដល់ពួកអ្នក, ការដែលព្រះសង្ឃប្រោះព្រំទឹកមន្តឲ្យដល់ពួកអ្នកនោះ ទុកស្មើពួកអ្នកបានទទួលនូវសិរីមង្គល ព្រោះព្រះសង្ឃដែលស្បូត្រសែកទឹកមន្ត គឺលោកស្រង់យកធម៌ជាពាក្យប្រៀនប្រដៅដ៏ល្អរបស់ព្រះសម្មាសម្ពុទ្ធមកស្បូត្រសែកចុះក្នុងទឹក ហាក់ដូចជាលោកប្រដៅយើងឲ្យធ្វើល្អ ឲ្យលះបង់អំពើអាក្រក់ ឲ្យផ្សាយមេត្តាដល់គ្នានឹងគ្នា កុំឲ្យបៀតបៀនគ្នា, ខ្ញុំជឿពាក្យប្រដៅដែលថាឲ្យចែងចែកចំណោះដល់ពួកមនុស្ស ខ្ញុំទើបប្រដៅពួកអ្នកដោយមិនមានអគតិ គឺមិនលំអៀង ព្រោះស្រឡាញ់ ព្រោះស្អប់ ឬជាទង្វាក់វណ្ណៈដូចពួកអ្នកឃើញស្រាប់ហើយ ខ្ញុំត្រេកអរក្នុង

ការឲ្យ ព្រោះជឿថាអ្នកដែលបានទទួលអំណោយតែងត្រេកអរ មានសេចក្ដីសុខដោយសារវត្ថុដែលទទួលពីយើងទៅ, កាលគេកើតមានសេចក្ដីសុខ យើងក៏បានសុខដែរ ហើយយើងមិនមែនបានទទួលសេចក្ដីសុខតែក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ ទៅក្នុងអនាគតយើងនឹងត្រូវទទួលសេចក្ដីសុខដោយកម្រៃបុណ្យនោះទៀត ។ វិជ្ជាស្ទាត់ជំនាញក្នុងគ្រឿងអាវុធផ្សេងៗ ដែលពួកអ្នករៀនអំពីខ្ញុំជាវិជ្ជាធម្មតា ហើយនរណាៗក៏អាចរៀនបានដូចគ្នា តែវិជ្ជាមួយយ៉ាងទៀត ពួកអ្នកគាត់ប្រឹងនៅមិនទាន់ចេះដឹងនៅឡើយ វិជ្ជានោះហៅថាវិជ្ជារបស់បណ្ឌិត គឺវិជ្ជាខាងព្រះពុទ្ធសាសនា បើពួកអ្នកពេញចិត្តនឹងរៀនខ្ញុំក៏នឹងបង្រៀន" ។

ពួកសិស្សទាំងឡាយ កាលបានស្ដាប់ពាក្យមានហេតុផលរបស់សុរពល ក៏នាំគ្នាប្រឹក្សាហើយជំរាបសុរពលថា ចាំសាកសួរឪពុកម្ដាយសិន រួចលាសុរពលនាំគ្នាត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ។

ចំណែកសញ្ជ័យប្រញាប់ប្រញាល់នាំប្អូនត្រឡប់ទៅផ្ទះ ដោយខ្លាចក្រែងបិតាមាតាដឹងថា ខ្លួននាំអាហារមកប្រគេនព្រះភិក្ខុសង្ឃនាផ្ទះសុរពលនឹងដេរកាយ ។ ទទួលក្នុងថ្ងៃនោះ មិត្តភក្តិខ្លះដែលនៅជិតផ្ទះសញ្ជ័យត្រឡប់ទៅដល់ផ្ទះមុនសញ្ជ័យ ។ មាតាបិតាសញ្ជ័យឃើញសញ្ជ័យមិនទាន់នាំប្អូនត្រឡប់ទៅផ្ទះក៏សង្ស័យ ទើបសួរមិត្តភក្តិសញ្ជ័យ ។ មិត្តភក្តិនោះប្រាប់ថាសញ្ជ័យនាំផ្លែឈើទៅប្រគេនព្រះភិក្ខុសង្ឃ កាលប្រាប់ហើយទើបនឹកឃើញថា សញ្ជ័យបានផ្ដាំមិនឲ្យប្រាប់បិតាមាតា ។ ការធ្វើរបស់សញ្ជ័យដូច្នេះ ជាហេតុឲ្យឪពុកម្ដាយក្រោធខឹងដូចភ្លើង

ចេះឡើង ១ រំពេច ក្នុងពេលដែលបានដឹងរឿង តាំងចិត្តខឹងជេរវាយឲ្យសមតាមកំហុស ៗ លុះសញ្ជ័យត្រឡប់មកដល់ផ្ទះ បិតាក៏ស្ទុះទៅចាប់កដៃម្ខាង វាយវាត់ដោយរំពាត់ជាច្រើន ៗ ក្មេងកម្លោះដូចយ៉ាងសញ្ជ័យជាមនុស្សទន់ ស្រឡាញ់ឪពុកម្តាយណាស់ បានឈរស្ងៀមបណ្តោយឲ្យបិតាវាយវាត់តាមចិត្ត ៗ បិតារបស់សញ្ជ័យវាយយ៉ាងច្រើនរាប់មិនបាន មាត់ក៏ជេរស្តីដោយពាក្យអាស្រូវកាស បន្ទោសសញ្ជ័យដែលមិនធ្វើតាមពាក្យហាមប្រាម សញ្ជ័យក៏យំសុំទោសឪពុកតែតាព្រាហ្មណ៍មិនអាណិតអាសូរសោះ គាត់វាយទាល់តែអស់កម្លាំងកាលបើមិនមានកម្លាំងនឹងវាយតទៅគាត់ក៏ស្រែកជេរ សម្ដីដែលគាត់ជេរនោះបានឮទៅស្ទើរតែគ្រប់ផ្ទះ នៃសិស្សរបស់សុរពល គាត់ជេរទៅដល់សុរពលផង :

—"មនុស្សបោកគ្មានខ្លឹមសារថោកទាបអាក្រក់ លើកតាំងខ្លួនជាអាចារ្យ តែងធ្វើឲ្យមនុស្សអ្នកជឿស្តាប់បានសេចក្តីវិនាស មនុស្សយ៉ាងខ្ញុំនឹងមិនទៅគប់រកអាមនុស្សអាក្រក់នោះទេ ប្រយ័ត្នចុះ បើអញដើរកាត់មុខផ្ទះវា អញនឹងជេរប្រទេចវាគ្រប់ពេលដែលបានដើរទៅ" ៗ

ថ្ងៃក្រោយមក តាព្រាហ្មណ៍នឹងយាយព្រាហ្មណី ក៏ធ្វើតាមពាក្យដែលគាត់និយាយមែន គឺកាលគាត់ដើរកាត់មុខផ្ទះនន្ទិអមាត្យពេលណាគាត់ក៏ជេរប្រទេចប្រៀចប្រាយដោយពាក្យអាស្រូវកាសពេលនោះ ៗ

តាំងអំពីថ្ងៃនោះមក សញ្ជ័យក៏ត្រូវឪពុកម្តាយហាមមិនឲ្យមកផ្ទះសុរពលជាដាច់ខាត, ថ្ងៃខ្លះព្រាហ្មណ៍បិតា ឬព្រាហ្មណីជាមាតានៃ

សញ្ញ័យ ដើរមកតាមផ្លូវកាត់មុខផ្ទះនន្ទិអមាត្យ ក៏ដេរដោយពាក្យអាស្រូវ ការសផ្សេង ៗ សុរពលបានឮក៏នៅស្ងៀមគ្រប់ពេល ។ ការស្ងៀមរបស់សុរពលជាហេតុធ្វើសេចក្ដីក្រោធខឹង របស់ព្រាហ្មណ៍ឲ្យរឹងរិតតែខ្លាំងឡើង ជួនកាលព្រាហ្មណ៍ដេរសុរពលដែលកំពុងបង្ហាត់សិស្ស ។ សុរ-ពលបានហាមសិស្សគ្រប់គ្នា មិនឲ្យប្រែមុខសំពះព្រាហ្មណ៍វិញ ដោយឲ្យទុកទដល់សិស្សថា

— "អ្នកទាំងឡាយចូរកាន់ចិត្តកុំខឹងតបនឹងគេដែលដេរយើងដោយទុកពាក្យដេរដូចជាវត្ថុសម្រាប់ទទួលភ្ញៀវ ធម្មតាអ្នកម្ចាស់ផ្ទះតែងមានវត្ថុសម្រាប់ទទួលភ្ញៀវ វត្ថុនោះមានទឹកតែ ស្លា ម្លូ បារីជាដើម បើភ្ញៀវមិនត្រូវការដោយវត្ថុដែលម្ចាស់ផ្ទះនាំមកទទួលទេ របស់នោះក៏ធ្លាក់ទៅជារបស់ម្ចាស់ផ្ទះវិញដដែល យ៉ាងណាមិញ ការដេរប្រទេចក៏យ៉ាងនោះដែរ បើយើងមិនទទួលដោយមិនក្រោធតបមិនយកចិត្តទុកដាក់ទេពាក្យដេរនោះក៏ធ្លាក់ទៅជារបស់អ្នកដេរវិញ ដូច្នោះឯង" ។

ដោយបានស្ដាប់ពាក្យសុរពលពន្យល់នេះ ពួកសិស្សក៏បាត់ខឹងទាំងអស់គ្នា កាលណាតាព្រាហ្មណ៍ ឬ យាយព្រាហ្មណីមកដេរក៏នាំគ្នាសើចសប្បាយទៅវិញ ។

ថ្ងៃមួយ យាយព្រាហ្មណី ត្រូវដើរកាត់មុខផ្ទះសុរពលទៀតតាមធ្លាប់, វេលាដែលគាត់ដើរមក សុរពលកំពុងបង្ហាត់សិស្ស ហើយប្រាប់ឲ្យសិស្សប្រឹងខ្នះប្រយ័ត្នក្រែងគោឆ្កួត ១ ដល់ ។ គោនោះពុំដឹងមកពីណាដើរវិលវល់នៅក្នុងបរិវេណផ្ទះសុរពល ។ លុះយាយព្រាហ្មណីមកដល់ផ្ទះ

សុរពលហើយ កំឈរដេរសុរពលទៀត ៗ សិស្សសុរពលលុះឃើញ
យាយព្រាហ្មណីដើរចូលមកហើយដេរសុរពល កំនាំគ្នាសើចសប្បាយ
ពុសម្លេងគឹកកង់ទៅឆ្ងាយ ៗ ខណៈនោះគោឆ្កួតដើរចូលមកជិតផ្ទះសុរ-
ពល លុះបានឮសម្លេងហើយកំបោលទៅរកសម្លេងនោះ ឯផ្លូវដែល
គោឆ្កួតនោះបោលមក គឺជាផ្លូវដែលនាងព្រាហ្មណីកំពុងឈរដេរសុរ-
ពល ៗ សម្លេងគោឈឺត ៗ មកជិតធ្វើឲ្យយាយព្រាហ្មណីបែរមើល
លុះគោឃើញយាយព្រាហ្មណីហើយ ក៏បោលចូលទៅប្រែងជល់យាយ
ព្រាហ្មណី ៗ កិតភ័យឈប់ដេរ ក្នុកក្រឡឹកក្រឡាប់ រត់ទៅត្រង់
ទីលានផ្ទះសុរពល ស្រែកសុំឲ្យពួកសិស្សសុរពលជួយ ៗ

ខណៈនោះ សិស្សរបស់សុរពលនាំគ្នារត់យកព្រះអាយុតែរៀងខ្លួន
គេចចេញទៅអំពីបរិវេណនោះ សល់តែសុរពលឈរនៅដោយខ្ទេតចិត្ត ៗ
សិស្សខ្លះស្រែកប្រាប់ឲ្យសុរពលរត់ចេញមកជាប្រញាប់ ខ្លះក៏ប្រាប់ថា
បណ្តោយឲ្យយាយព្រាហ្មណីមាត់អាក្រក់នោះស្លាប់ទៅចុះ ៗ យាយ
ព្រាហ្មណីរត់មករកសុរពល, គោកាចនោះបោលមកជិតនឹងទាន់គាត់
ហើយ, យាយព្រាហ្មណីរត់មកដល់សុរពល ក៏ជំពប់ជើងនឹងបុស
ឈើដួលទៅ គោកាចនោះបោលទៅរកជល់យាយព្រាហ្មណី ៗ
សុរពលឃើញដូច្នោះ ក៏មានសេចក្តីករុណាយាយព្រាហ្មណី ទើប
កាត់ចិត្តប្រថុយជីវិត រត់តម្រង់ទៅផ្ទល់មុខគោកាច ហើយបញ្ឆោតឲ្យវា
ដេញតាម ៗ គោកាចឃើញដូច្នោះក៏ស្ទុះទៅរកជល់សុរពលដោយពេញ

ទំហឹង សុរពលគេចខ្លួនផុតវិសទឹងត្រូវដោយស្នែងស្រួចរបស់វា គោកាចនោះក៏ជ្រុលខ្លួនហួសទៅ លុះវាធ្វើសុរពលមិនបាន វាក៏បែរត្រឡប់ទៅជាថ្មីយ៉ាងរហ័ស វាបញ្ចេញសម្លេងឈឺតៗ បោលទៅដល់សុរពលទៀត ។ គ្រានេះសុរពលគេចមិនទាន់ ក៏ចាប់ស្នែងគោដោយដៃទាំងពីរ យាយព្រាហ្មណ៍លុះបានរួចខ្លួនពីការស្លាប់ហើយ ក៏រត់ឡើងទៅអង្គុយលើផ្ទះសុរពល ។

ខណៈនោះ នាងកាញ្ចនាអង្គុយយំលើផ្ទះ ហើយប្រាប់ឲ្យសិស្សរបស់សុរពលជួយសុរពលផង តែមិនមានអ្នកណាម្នាក់ហ៊ានចេញទៅជួយសោះ ។ មុខគួរឲ្យស្រៀវខ្លួនក្រៃពេក គោកាចរុញសុរពលទ្រេតទៅមក សុរពលចាប់សង្កត់ស្នែងវាមិនលែង ។ គោកាចក្រវីលាល់ចោលសុរពលៗ របូតចេញពីស្នែងរបស់វាខ្ទាតចេញទៅឆ្ងាយ, មួយរំពេចនោះគោកាចបោលតម្រង់ទៅរកសុរពលៗ ក្រោកគេចខ្លួនយ៉ាងរហ័ស ។ គោកាចក៏ដល់ត្រូវដី ធ្វើឲ្យករបស់វាគ្រេចឈឺចាប់យ៉ាងខ្លាំង ទោះបីដូច្នោះវាក៏នៅតែបោលតម្រង់មករកសុរពលទៀត ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ២៥

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

កាន់យ៉ុងនិយាយនឹងអ៊ូនសៀវថា ដែលលោកប្រើឡៅពីឲ្យទៅបញ្ចុះបញ្ចូលឡៅប៉ឺនោះ ខ្ញុំបាទក្រែងឡៅពីមិនព្រមត្រឡប់មកនៅនឹងលោកវិញ បើដូច្នោះខ្ញុំបាទនឹងសូមអាសាកាន់កាប់ឡៅពីទៅផង ហើយនឹងបាននិយាយពន្យល់ឡៅប៉ឺឲ្យចូលចិត្តមកនៅរួមធ្វើការជាមួយនឹងលោកឲ្យខាងតែបាន ។ អ៊ូនសៀវមិនយល់កលឧបាយក៏ជឿថាកាន់យ៉ុងនិយាយត្រូវក៏ព្រមឲ្យកាន់យ៉ុងទៅ, កាន់យ៉ុងក៏លាអ៊ូនសៀវតាមឡៅពីទៅដល់ទីលំនៅ ។

គួតៅនិយាយនឹងអ៊ូនសៀវថា: កាលគ្រាមុនលោកបានឲ្យឡៅពីទៅបញ្ចុះបញ្ចូលឡៅផេក តែមិនបានសមដូចប្រាថ្នា ឥឡូវនេះលោកឲ្យឡៅពីនឹងកាន់យ៉ុងទៅបញ្ចុះបញ្ចូលឡៅប៉ឺទៀតនោះ ខ្ញុំបាទ

យល់ឃើញថាឡៅពីនឹងកាន់យ៉ុង ទឹងមិនព្រមត្រឡប់មករកលោកវិញទេ ។ អ៊ួនសៀវតបថា ឯកាន់យ៉ុងនោះមានសតិបញ្ញាចៀងត្រង់នឹងយើងណាស់ ទោះបីឡៅពីព្រងើយកន្តើយមិនមកយ៉ាងណា មុខជាកាន់យ៉ុងនឹងរិះគិតនាំខ្លួនឡៅពីមកវិញពាល់តែបាន ។ គួកៅបានស្តាប់ហើយក៏ដកដង្ហើមធំមិនឆ្លើយតបថាអ្វីសោះ ។

ឯឡៅពីក៏ប្រើស៊ុនខៀនឲ្យត្រឡប់ចេញទៅប្រាប់គួនអ៊ីថា ឥឡូវអ៊ួនសៀវប្រើយើងនឹងកាន់យ៉ុង ឲ្យទៅបញ្ចុះបញ្ចូលឡៅប៉ៀវចៅហ្វាយស្រុកកេងជីវ ដូច្នេះកុំឲ្យគួនអ៊ីចូលមកឡើយ ឲ្យនៅចាំនៅទីនោះចុះ ។ ស៊ុនខៀនក៏លាឡៅពីចេញទៅប្រាប់គួនអ៊ីតាមបង្គាប់ ។ ឯឡៅពីក៏នាំកាន់យ៉ុងចេញពីស្រុកគីជីវទៅ គួនអ៊ីឃើញឡៅពីទៅដល់ក៏មានអំណរណាស់ ចុះពីលើខ្នងសេះទៅគំនាប់ឡៅពី ហើយក៏ពណ៌នាពៀងការដែលត្រាត់ប្រាសនិរាសគ្នាតាំងពីដើមដល់ចប់ឲ្យឡៅពីស្តាប់គ្រប់ប្រការ ហើយនាំឡៅពីចូលទៅក្នុងផ្ទះគួនគេង ទើបនិយាយនឹងគួនគេងថា ដែលខ្ញុំមកតាមជិតដោយដូច្នេះ ព្រោះសេចក្តីចាំចិត្តគិតអាល័យវិស័យជួបបងខ្ញុំបង្កើត ឥឡូវបានជួបនឹងឡៅពីជាបងខ្ញុំហើយ ។

គួនគេងក៏ហៅកូនទាំង ២ ឲ្យចេញមកគំនាប់ឡៅពី ក៏សួរថា អ្នកនឹងកូនទាំង ២ នេះឈ្មោះអ្វី? គួនអ៊ីប្រាប់ថា: បិតាឈ្មោះគួនគេងជាសែស្រឡាយជាមួយនឹងខ្ញុំ, ឯកូនទាំង ២ នោះ កូនច្បងឈ្មោះគួនហ្វេង ប្អូនឈ្មោះគួនប៉េង ។ គួនគេងឆ្លើយតបឡៅពីថា: ខ្ញុំបាទនឹងឲ្យគួនប៉េងជាកូនចៅខ្ញុំទៅនៅនឹងគួនអ៊ី តែក្រែងថាលោកមិនយល់ព្រម

ផង ៗ ឡៅពីក៏សួរថា អាយុកូនប៉េងប៉ុន្មានឆ្នាំហើយ? កូនតេងឆ្លើយថា អាយុកូនប៉េង ១៥ ឆ្នាំហើយ ៗ ឡៅពីជាអ្នកឲ្យកូនប៉េងទៅនៅនឹងកូនអ៊ុំនោះ យើងក៏មានសេចក្តីត្រេកអរណាស់ ព្រោះកូនអ៊ុំគ្មានកូនសោះ ចូរអ្នកតាំងចិត្តប្តេជ្ញាឲ្យកូនប៉េងទៅជាកូនចិញ្ចឹមកូនអ៊ុំចុះ ៗ កូនតេងបានស្តាប់ដូច្នោះក៏ពេញចិត្តណាស់ ទើបសូមអនុញ្ញាតឲ្យកូនប៉េងធ្វើជាកូនចិញ្ចឹមកូនអ៊ុំ ហើយឲ្យហៅឡៅពីជាអាពុកធំ ៗ ឡៅពីក៏និយាយនឹងកូនតេងថា កាលបើយើងនឹងបង្អង់នៅទីនេះយូរទៅ ខ្លាចអ៊ួនសៀវដឹងការណ៍នឹងគិតកែប្រែឡើងវិញ ឲ្យទាហានមកតាមយើងយកទៅ ដូច្នេះយើងត្រូវស្រូតចេញទៅឲ្យផុតទើបស្រួល ៗ កូនអ៊ុំយល់ត្រូវផងក៏នាំគ្នាលាកូនតេង នាំកូនប៉េងនឹងទាហានទាំងពួងតម្រង់ទៅផ្លូវភ្នំឆៅជំរស៊ន កូនអ៊ុំជិះសេះនាំមុខ ទទួលជួបនឹងជំរធងលើកទាហានប្រហែលជាង ៣០ នាក់ ឃើញកាយត្រូវអាវុធមុតអស់ទាំងខ្លួន ឈាមក៏ប្រលាក់ជោកពេញកាយទាំងនាយទាំងកូនទាហាន កូនអ៊ុំក៏នាំជំរធងចូលទៅគំនាប់ឡៅពី ជំរធងគំនាប់ឡៅពីរួចហើយជំរាបថា កាលកូនអ៊ុំប្រើខ្ញុំបាទទៅរកហ៊ុយងួនសៀវនោះ មានទាហានម្នាក់ជិះសេះមកតែម្នាក់ឯងសម្លាប់ហ៊ុយងួនសៀវស្លាប់ ខ្ញុំបាទក៏ចូលទៅច្បាំងតាំងគ្នានឹងទាហាននោះទៀត ទាហាននោះពូកែណាស់ កាប់ចាក់ខ្ញុំបាទនឹងទាហានត្រូវរបួសពិការគ្រប់គ្នា ខ្ញុំបាទរងពុំឈ្នះក៏ប្រាសរត់មក ឥឡូវទាហាននោះឃុំនាំទាហានហ៊ុយងួនសៀវទៅលើភ្នំឆៅជំរស៊ន ៗ ឡៅពីសួរថា ទាហាននោះរូបពង់មុខមាត់យ៉ាងដូចម្តេច អ្នកឯងស្គាល់ឬទេ? ជំរធងឆ្លើយថា:

ឈ្មោះនោះខ្ញុំបាទមិនស្គាល់ទេ តែឃើញរូបរាងខ្ពស់ធំមាំមួនណាស់ ។ ទៀតពីទីនេះគួនអ៊ូកឲ្យនាំឡើងទៅលើភ្នំនោះដែរសិន ហើយដើរចេញទៅស្រែកជេរដៀលគ្នោះ ។

ទៀវដូឡុងបានឮប្រុះខឹងណាស់ ក៏ពាក់ក្រោះឡើងជិះសេះកាន់ទួនចេញមកមុខទាហាន ឡៅពីក្រឡេកទៅឃើញក៏ស្គាល់ច្បាស់ជាដូឡុង ឡៅពីក៏បររសេះចេញទៅបង្ហាញខ្លួនឲ្យទៀវដូឡុងឃើញ ទៀវដូឡុងក្រឡេកទៅស្គាល់ជាក់ជាឡៅពីក៏ត្រេកអរណាស់ លោតចុះពីលើសេះបោះទួនចេញពីដៃ ហើយចូលទៅគំនាប់ឡៅពី ៗ គួនអ៊ូក្រឡេកឃើញទៀវដូឡុងចូលមក ក៏ចុះពីលើសេះទៅគំនាប់ហើយសួរទៀវដូឡុងថា ហេតុដូចម្ដេចបានជាអ្នកមកនៅលើភ្នំនេះ? ទៀវដូឡុងឆ្លើយថា កាលខ្ញុំបាទនៅជាមួយកងស៊ុនចាន ៗ បានធ្វើសង្គ្រាមមិនព្រមជឿស្ដាប់ពាក្យទីប្រឹក្សាទាំងពួង ទើបចុះការបាញ់អ៊ួនសៀវតាលតែខ្លួនអនិច្ចកម្ម អ៊ួនសៀវឲ្យទាហានមកល្បួងលួងលោមខ្ញុំបាទជាច្រើនគ្រា ខ្ញុំបាទដឹងចិត្តអ៊ួនសៀវបានជាមិនព្រមទៅនៅជាមួយផង លុះខ្ញុំបាទដឹងថាលោកមកនៅស្រុកគីជីវនេះក៏ស្ទួងនឹងទៅរកលោក លុះទៅដល់កណ្ដាលផ្លូវឮដំណឹងថាលោកបាញ់ទ័ពបួច ខ្លួនលោកក៏បែកទៅនៅនឹងអ៊ួនសៀវ ឮថាអ៊ួនសៀវក្លាត់ទៅនៅនឹងបួច លុះខ្ញុំបាទនឹងតាមលោកទៅស្រុកគីជីវក៏នឹកខ្លាចអ៊ួនសៀវដឹងនឹងទឹងចងគំនុំព្យាបាទធ្វើអន្តរាយខ្ញុំបាទ ៗ ក៏ស្ទួងមកជួបនឹងពួកចោរនៅលើភ្នំនេះ ហ៊ុយង៉ួនសៀវក៏លើកបក្ខពួកចេញមកនឹងដណ្ដើមយកសេះខ្ញុំបាទ ៗ បានច្បាំងគ្នាជាពន្ទឹក ខ្ញុំបាទក៏សម្លាប់

ហ៊ុយជួនសៀវស្លាប់ ស្រាប់តែពួកចោរបែកទៅខ្លះ ខ្ញុំបាទក៏ឃុំពួកចោរនៅសំពកលើភ្នំនេះ បានព្រួដំណឹងថាទៀវហ៊ុយមកធ្វើចៅហ្វាយស្រុកកៅសៀ ខ្ញុំបាទក៏ចាំស្តាប់ដំណឹងឲ្យប្រាកដទើបទៅរកទៀវហ៊ុយ ។

ឡៅពីទឹងគួនអ៊ូ ទាំងអស់គ្នាក៏ពណ៌នារឿងរ៉ាវដែលបែកទៅនៅទឹងអ៊ួនសៀវទឹងប្អូននោះឲ្យទៀវជូឡុងស្តាប់គ្រប់ប្រការ ហើយឡៅពី ថា យើងបានជួបទឹងអ្នកកាលគ្រាដែលអ្នកនៅទឹងកង់ស៊ុនចាននោះ យើងក៏ជាប់ចិត្តស្រឡាញ់ពេកណាស់ តែដោយឥតបុណ្យកុសល បានជាមិនបានអ្នកមកជួយធ្វើការផង ឥឡូវបុណ្យសំណាងយើងល្អត្រូវកាល ទើបបណ្តាលឲ្យមកជួបប្រទះគ្នានៅទីនេះ គួរអ្នកទឹងរិះគិតទៅនៅធ្វើការជាមួយទឹងយើងចុះ ។ ទៀវជូឡុងឆ្លើយថា៖ "ខ្ញុំបាទស្វះស្វែងគ្រប់ស្រុកគ្រប់ដំបន់ច្រើនដំណាក់ ដើម្បីទឹងរកទីពឹងពំនាក់ឲ្យមានស្វាមីភក្តិស្ម័គ្រ ស្រឡាញ់ឲ្យអស់អញ ដូចខ្ញុំបានរាប់អានស្រឡាញ់លោកនោះគ្មានសោះ គ្រានេះជាបុណ្យកុសលរបស់ខ្ញុំបាទបានមកជួបប្រទះទឹងលោកហើយ ខ្ញុំបាទក៏សូមផ្ញើរូបអង្គប្តូរចិត្តនៅជាបាវលោកឲ្យលោកប្រើប្រាស់តាមការចុះ ទោះបីស្លាប់រស់ប្តូរមិនបានសេចក្តីក្រីក្រលំបាកប្រការដូចម្តេចក៏ដោយ ខ្ញុំបាទក៏សូមយកអាសាត្រាតែរលត់ផុតជីវិតទៅចុះ" លុះពណ៌នាប្រាប់សព្វគ្រប់ប្រការដូច្នេះហើយ ទៀវជូឡុងក៏នាំពួកកៀនទាំងនោះតាមឡៅពីទៅស្រុកកៅសៀ ។

ឯទៀវហ៊ុយទឹងប៊ីតុកប៊ីហាង ដឹងថាឡៅពីមកជិតដល់ស្រុកហើយ មានអំណរណាស់នាំគ្នាចេញទៅទទួលឡៅពីនាំចូលមក ។ ខណៈនោះ

នាងគាំហ៊ួយិន នាងបែហ៊ួយិនក៏ចេញមកគំនាប់ឡៅតី ហើយពណ៌នារឿងដែលព្រាត់ប្រាសនិពសគ្នា តាំងពីដើមរហូតដល់គ្រាបាក់បែកខូចស្រុកហៃហ៊ី ទីងដែលគួនអ៊ូទៅនៅជាមួយនឹងបួធូសពួគ្រប់ប្រការឲ្យឡៅតីស្តាប់ ឡៅតីបានស្តាប់ហើយក៏សរសើរគួនអ៊ូ ថាជាមនុស្សមានសេចក្តីស័ត្យកតញ្ញូនឹងរកនរណាស្មើគ្មាន ទើបហ៊ុយក៏ឲ្យតែងគ្រឿងបួងសួងដល់ទេពតា ហើយលៀងភោជនាហារ ។

លុះគន្ទងមក ថ្ងៃមួយនោះឡៅតីក៏ប្រជុំប្រឹក្សានឹងគួនអ៊ូ ទៀវហ៊ុយនៅអស់សេនាទាហានទាំងពួងថា: ស្រុកកៅសៀនេះ ជាស្រុកតូចដែលនឹងនៅជាទីមាំមួននោះមិនបានទេ គួរយើងនាំគ្នាទៅនៅស្រុកយី-ហ៊ាំវិញ ព្រោះជាទីដែនស្រុកធំនឹងបានជាទីមាំមួនគិតការតទៅ ។ ទទួលមានបំរើសេះម្នាក់កាន់សំបុត្រឡៅផេក មកជូនឡៅតី សេចក្តីថា: ឥឡូវឡៅផេកដឹងថាឡៅតីមកនៅស្រុកកៅសៀនោះ មិនជាទីមាំមួនទេ បានជាមានសំបុត្រមកសុំអញ្ជើញឡៅតីទៅតាំងនៅស្រុកយីហ៊ាំវិញ" ។ លុះឡៅតីដឹងក្នុងសេចក្តីសំបុត្រដូច្នោះហើយក៏មានអំណរណាស់ ប្រឹក្សាឃើញព្រមគ្នា ទើបនាំគួនអ៊ូ ទៀវហ៊ុយនូវអស់គ្រួសារនឹងទាហានឯកព្រមទាំងពលសេនាទាហានទាំងពួងប្រហែល ៥០០ ប្រុយនាក់ ទៅនៅស្រុកយីហ៊ាំ ។

ឯអ៊ួនសៀវដឹងច្បាស់ដូច្នោះក៏ខឹងណាស់ ទើបកេណ្ឌសេនាទាហាននឹងលើកទ័ពទៅចាប់ឡៅតី ។ គួរសៅដំរាបថា: ដែលលោកនឹងលើក

ទ័ពទៅចាប់ឡៀតនោះ ខ្ញុំបាទឃើញថាមិនគួរសោះ ទោះបីឡៀតមិន
បានទៅបញ្ចុះបញ្ចូលឡៅជៀវមកជួយគិតការក៏មិនជាការអ្វី សព្វថ្ងៃនេះ
ខ្ញុំបាទមានបារម្ភណ៍ខ្វាចតែចូចូជាសឹកសត្រូវទីងស៊ុនសេក ដែលតាំង
នៅស្រុកកង់តាំងនោះ មានទាហានជាច្រើន ស្បៀងអាហារចំណី
ត្រីសាច់ក៏បរិបូណ៌ មានស្រុកឡើង៦មណ្ឌល សូមលោករិះគិតរក
តាត់ប្រើអ្នកណាដែលមានសតិបញ្ញា ឲ្យទៅនិយាយបញ្ចុះបញ្ចូលស៊ុន
សេកមកចុកឲ្យជួយគិតការកំចាត់ចូចូដែលជាសឹកសត្រូវធំពេញទើបគួរ ឯ
ឡៀតតែនោះទាហានក៏តិច បើលោកនឹងលើកទ័ពទៅច្បាំងវេលាណាក៏
បេះតែបានដោយងាយណាស់ ៗ អ៊ួនសៀវយល់ព្រមផង ទើបធ្វើ
សំបុត្រតាត់ប្រើគាន់ជីនឲ្យទៅបញ្ចុះបញ្ចូលស៊ុនសេក គាន់ជីនក៏ទទួល
សំបុត្រហើយលាអ៊ួនសៀវទៅ ៗ ឯស៊ុនសេកចៅហ្វាយស្រុកកង់
តាំងនោះ កាលព្រះចៅហៀនតេសោយរាជ្យ ស្តេចយាងទៅនៅក្រុង
ហ៊ូតោបាន ៤ ឆ្នាំនោះ ស៊ុនសេកលើកទ័ពទៅវាយស្រុកលោកង ស្រុក
អ៊ីចៀង បានហើយរៀបយកគ្រឿងមកចុកបានជាច្រើន ៗ

* * *

## កណ្ឌទី ២៦

តាំងពីស៊ុនសេកវាយយកបានអាណាខែត្រមកជាចំណុះច្រើន ហើយមានចិត្តកំរើបធ្វើ
ចុតម៉ាយក្រាបទូលព្រះចៅហៀនតេយកគុណគាប់ របួតផិលអ្នួនសៀវលើកទ័ពទៅច្បាំងនឹង
ចូចូនៅដំបន់ប៊ូអៀង ។

ស៊ុនសេកមានចិត្តកំរើប ទើបធ្វើចុតម៉ាយប្រើទៀវហៀនឲ្យគាន់
ចូលទៅក្រាបទូលព្រះចៅហៀនតេ ព្រាថ្នាទីងឲ្យមាននេឈ្មោះសំឡេង

យសបណ្ណាស័ក្តិ សេចក្តីសំបុត្រនោះថ្លែងជារឿងរ៉ាវថា: ស៊ុនសេឹកចៅហ្វាយស្រុកក័ងតាំងបានប្រាប់ប្រាមអាណាខែត្រជាប្រេទតំបន់ឲ្យរាបទាបអស់ហើយ ៗ ទៀវហៀនក៏នាំបុតម៉ាយនោះទៅឲ្យបូឆ្វ ៗ ឃើញសេចក្តីបុតម៉ាយដូច្នោះក៏ដកដង្ហើមធំ ហើយគិតថា " ធម្មតាជាតិកូនខ្លាមែងតែសាហាវ នរណានឹងប៉ងប្រាថ្នាទៅធ្វើអន្តរាយដល់កូនខ្លានោះ ក៏ក្រែមនឹងបាន បើដូច្នោះតាំងយើងគិតលើកបុត្រីជាប្អូននាងហោយិន ឲ្យជាភរិយាស៊ុនខងជាប្អូនស៊ុនសេឹក ទើបបានស្រុលជាផ្លូវមួយនឹងស៊ុនសេឹក" ហើយបូឆ្វក៏យកខ្លួនទៀវហៀនទុកធ្វើជាការនៅក្នុងហ៊្វូគោ ៗ ឯស៊ុន-សេឹកលុះដឹងដំណឹងថា បូឆ្វមិនបានយកសំបុត្រទៅថ្វាយព្រះចៅហៀនតេ ហើយយកខ្លួនទៀវហៀនទុកធ្វើជាការក្នុងក្រុង ស៊ុនសេឹកក៏ទឹកខឹងខ្លាំងណាស់គិតនឹងលើកកងទ័ពទៅវាយកំចាត់បូឆ្វជារឿយ ៗ ៗ

ឯខៅកង់ចៅហ្វាយស្រុកង៉ុនដែលជាចំណុះស្រុកក័ងតាំងនោះ លុះដឹងថា ស៊ុនសេឹកធ្វើការប្រទូសរ៉ាយអាក្រក់ផ្សេង ៗ ក៏តែងសំបុត្របក្តឹងចូលទៅដល់បូឆ្វ ជាសេចក្តីថា: "ស៊ុនសេឹកធ្វើការអាក្រក់ដល់អាណាខែត្រទាំងពួងខ្លាំងពេកណាស់ សព្វថ្ងៃនេះ អ្នករាជការនឹងបណ្តាពស្ត្រ បានសេចក្តីក្តៅក្រហាយគ្រប់ខែត្រខ័ណ្ឌ សូមមហាឧបរាជរិះគិតឲ្យមានព្រះតម្រាស់ព្រះចៅហៀនតេ ឲ្យហៅយកខ្លួនស៊ុនសេឹកចូលមកធ្វើរាជការឯស្រុកក្រុងវិញ បើនឹងបង្អង់ទុកឲ្យស៊ុនសេឹកនៅធ្វើជាធំ ខាងក្រោយយូរទៅនឹងប្រែជាក្បត់ផែនដីមិនខាន" លុះតែងសំបុត្រហើយក៏ប្រើពាហានឲ្យកាន់ផ្លូវកាត់ជ្រោយសមុទ្រទៅ ៗ

លុះទាហានកងក្រវែលស្រុកក័ងតាំងឃើញប្លែក ក៏ចាប់យកខ្លួនទុក ត្រួតឃើញសំបុត្រក៏បញ្ជូនខ្លួននឹងសំបុត្រទៅដល់ស៊ុនសេ៊ីក ។ ឃើញសំបុត្រដូច្នោះក៏ខឹងណាស់ ទើបឲ្យយកខ្លួនអ្នកកាន់សំបុត្រនោះទៅសម្លាប់ ហើយស៊ុនសេ៊ីកក៏ធ្វើជាកលឧបាយបញ្ឆោតឲ្យទាហានទៅអញ្ជើញខៅកងចៅហ្វាយស្រុកង៉ីកុនមកស៊ីលៀង ខៅកងមិនមានសេចក្តីមន្ទិលសង្ស័យ ក៏ចូលមករកស៊ុនសេ៊ីក ៗ ក៏យកសំបុត្រនោះមកបង្ហាញឲ្យខៅកងមើលហើយស្រែកគំរាមថា ហេតុម្តេចក៏ឯងក្លែងធ្វើសំបុត្រថាអញជាមនុស្សក្បត់ផែនដី ឲ្យចូចូហៅយកខ្លួនអញចូលទៅឯស្រុកក្រុងវិញ, ខៅកងទាល់គំនិតឥតហ៊ានឆ្លើយថាម្តេចសោះ, ស៊ុនសេ៊ីកក៏ឲ្យចាប់ចងនាំយកខ្លួនទៅសម្លាប់ ៗ ឯបណ្តាគ្រួសារនឹងបាវព្រាវទាំងអស់របស់ខៅកង លុះដឹងដូច្នោះក៏នាំគ្នារត់បែកខ្ចាត់ខ្ចាយទៅពីស្រុកង៉ីកុន នៅសល់តែទាហាន ខៅកង ៣ នាក់ ទាហាននោះមានចិត្តព្យាបាទស៊ុនសេ៊ីកគិតនឹងសងសឹកវិញឲ្យបាន ទើបបបួលគ្នាទៅនៅក្នុងព្រៃជិតស្រុកក័ងតាំងប្រាថ្នានឹងលបលួចធ្វើអន្តរាយស៊ុនសេ៊ីកវិញ ៗ

មានកាលថ្ងៃមួយ ស៊ុនសេ៊ីកនាំទាហានចេញទៅបរបាញ់សត្វក្នុងព្រៃ ឃើញប្រើស ១ ក៏ក្រទាក់ធ្នូឡើងសេះដេញតាមទៅតែម្នាក់ឯង ទទួលឃើញទាហាន ៣ នាក់នោះកាន់ធ្នូនឹងខ្លួនឈរអែបប្រែបដើមឈើ ស៊ុនសេ៊ីកក៏សួរថា: ខ្លួនជាបាវនរណា មកពីណា? ទាហានទាំង ៣ នាក់នោះក៏ប្រែឧបាយឆ្លើយថា: ខ្ញុំបាទជាបាវហ័នតុងដែលជាទាហានឯករបស់លោក បបួលគ្នាចេញមកបរបាញ់សត្វក្នុងព្រៃ ៗ ស៊ុនសេ៊ីក

បានស្ដាប់គឺឥតមានចិត្តសង្ស័យ ហើយបរសេះត្រឡប់ចេញពីទីនោះទៅ ។ ទាហានទាំង ៣ នាក់នោះឃើញបានការ ទាហានម្នាក់យកខ្លួនចាក់ត្រូវជើងឆ្វេងស៊ុនស៊ើក ១ ផ្លែ ម្នាក់លើកធ្នូបាញ់ទៅត្រូវមុតស៊ុនស៊ើកៗក៏យស្ទុះកន្ត្រាក់ដងព្រួញបាន ហើយបាញ់ទៅត្រូវទាហាននោះស្លាប់ម្នាក់ ។ ឯទាហាន ២ នាក់ក៏យកខ្លួនចូលមកចោមចាក់ស៊ុនស៊ើក ហើយស្រែកគំរាមថា: អញជាទាហានទៅកង ដែលអញនាំគ្នាមកធ្វើដូច្នេះប្រាថ្នានឹងសងសឹកចៅហ្វាយអញ ។ ស៊ុនស៊ើកគ្មានអាវុធនៅដៃសោះ យកតែដងធ្នូទាត់ទះការពារខ្លួនមិនឲ្យកាប់ចាក់ត្រូវខ្លួន មានត្រូវរបួសមុតជាច្រើនអន្លើ ។

ទទួលទៀវផៅ ជិះសេះនាំទាហានប្រហែល ៩ ឬ ១០ នាក់តម្រង់ចូលមកជិត, ស៊ុនស៊ើកក៏ស្រែកហៅឲ្យជួយ ទៀវផៅនឹងទាហានឃើញដូច្នោះក៏បរសេះចូលទៅកាប់ទាហានទាំង ២ នាក់នោះដាច់ខ្ទេចខ្ទីអស់ទាំងខ្លួនទាល់តែស្លាប់ ហើយត្រឡប់ទៅមើលស៊ុនស៊ើកឃើញមុខត្រូវព្រួញមួយអន្លើ ពងកាយក៏ត្រូវរបួសនឹងខ្លួនជាច្រើនអន្លើ ទៀវផៅក៏យកក្រប៊ីកាត់ជាយអាវមករុំរបួសឲ្យស៊ុនស៊ើក ហើយគ្រាហ៍នាំចូលមកស្រុកវិញ ស៊ុនស៊ើកក៏ប្រើបរើឲ្យទៅរកខ្លួនហ៊ួគោជាពេទ្យឲ្យមករក្សារបួសនោះ ។

( មានត )

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិន ម្ចៀនជមះតែង

## លោករ៉ាយ-ប៊ុក ក្រមការ ដើមខ្មែរ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ២៩

មានកាលមួយថ្ងៃ, ព្រះបាទភោជៈ ទ្រង់ស្ដេចចូលទៅជិតបល្ល័ង្កទិព្វដើម្បីនឹងអភិសេកសោយរាជ្យ ៗ រូបទេពនិម្មិតទី ២៩ បានឃើញព្រះបាទភោជៈមានព្រះរាជបំណងដូច្នោះ ក៏ក្រាបទូលថា:

---

"មានកាលមួយថ្ងៃ, វៃតាលិក (Vaitalika) ម្នាក់ បានទៅដល់មុខក្លោងទ្វារព្រះបរមរាជវាំងនៃព្រះបាទវិក្រមាទិត្យហើយ និយាយទៅកាន់នាយទ្វារបាលថា: "នែនាយទ្វារបាល ! ខ្ញុំបានឮនូវព្រះរាជកិត្តិសព្ទនៃព្រះមហារាជដែលជាស្ដេចចក្រពត្រ ព្រះនាម ព្រះបាទវិក្រមាទិត្យ ខ្ញុំទើបមកអំពីប្រទេសឆ្ងាយកាត់ប្រទេសជាច្រើន ដើម្បីនឹងមកក្រាបបង្គំគាល់ព្រះអង្គ, ដូច្នេះ សូមអ្នកអញ្ជើញទៅក្រាបបង្គំទូលព្រះអង្គឲ្យទ្រង់ជ្រាបផង" ។ នាយទ្វារបាលបានស្ដាប់នូវពាក្យវៃតាលិកហើយ ក៏យកដំណឹងនេះទៅជំរាបអ្នកនាំព្រះរាជសារ ៗ ក៏បានយកសេចក្ដីក្រាបបង្គំទូលព្រះនរបតី ៗ ទ្រង់បានព្រះរាជានុញ្ញាតឲ្យវៃតាលិកនោះ ចូលក្រាបបង្គំគាល់ព្រះអង្គ ។ វៃតាលិកនេះបានកាន់ដំបងមួយថ្លៃមាស ២០០៨ ដំឡឹង

ដើរចូលទៅដល់ក្រុមព្រះរាជទីប្រឹក្សា ហើយក្រឡេកមើលនូវការរៀបចំ កន្លែងនេះ ឃើញមានរបៀបរៀបរយល្អអស្ចារ្យ ។ គាត់ក៏បានបោល កន្ទុយភ្នែកទៅកាន់ព្រះចក្រពត្រាធិរាជ ព្រះនាម ព្រះបាទវិក្រមាទិត្យ ដែលមានព្រះរាជទីប្រឹក្សាជាច្រើនរូប, រដ្ឋមន្ត្រីប៉ិនប្រសប់, ក្រុមវិញ្ញូ-ជន ដូចជាកូលីតាស: និងបណ្ឌិតឯទៀត ដែលមានកិត្តិសព្ទល្បីល្បាញ ជាងគេ ជាព្រះរាជបរិវារ ព្រមទាំងមានអ្នកកាន់ផ្លិតសធំ ៗ និងផ្លិតតូច ៗ កាន់ព្រះឆត្រដែលមានណាបលនដោយទឹកមាសដាំត្បូងដើរអមព្រះអង្គ គាត់ក៏ធ្វើអញ្ជលីថ្វាយបង្គំ ហើយក្រាបទូលថា: "បពិត្រព្រះចមកត, ទូលព្រះបង្គំបានមើលពិនិត្យនូវព្រះរាជទីប្រឹក្សាព្រះអង្គ និងព្រះរាជបរិវារ ព្រះអង្គ ទូលព្រះបង្គំហាក់ដូចជាបានមើលពិធីបុណ្យអ្វីមួយដ៏ឧឡារិក ដែលទូលព្រះបង្គំមិនធ្លាប់បានឃើញពីមុនមកសោះ" ។

ក្រោយដែលវៃតាលិកបានក្រាបបង្គំទូល ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះរាជបញ្ជាឲ្យវៃតាលិកថយចេញទៅខាងក្រៅ ។ ក្នុងវេលានោះ ស្រាប់តែមានបុរសម្នាក់ដៃម្ខាងកាន់ដាវ, ដៃម្ខាងទៀតកាន់ដៃនារីម្នាក់ ដែលមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ, នាំចូលមកដល់ព្រះអង្គ ហើយក្រាបបង្គំទូលថា "បពិត្រព្រះនរបតី មានបុគ្គលជាច្រើនបានយល់ថា នៅក្នុងវដ្តសង្សារនេះ វិទ្យាសាស្ត្រជាវត្ថុដ៏សំខាន់បំផុត; នេះមិនមែនជាសេចក្តីយល់នៃទូលព្រះបង្គំឡើយ ។ បើតាមយោបល់ទូលព្រះបង្គំ គឺនារីប្រកបដោយលំអយ៉ាងក្រៃលែង និងការត្រេកត្រអាលនៃបុរសចំពោះនារីនោះជាច្រើនលើក, នេះទើបទុកជាការសំខាន់បំផុត ។

វត្ថុទាំងពីរយ៉ាងនេះ ទូលព្រះបង្គំមិនបានលះបង់ទៅឲ្យអ្នកដទៃទេ ។ តែក្នុងពេលឥឡូវនេះ នៅលើមេឃ (នភាល័យ) មានការតយុទ្ធរវាងទេវតានឹងទានវៈ ។ ទូលព្រះបង្គំត្រូវចូលទៅយកអាសាព្រះឥន្ទ្រាធិរាជក្នុងសង្គ្រាមនោះ ។ ស្ត្រីនេះជាភរិយាទូលព្រះបង្គំ ដែលទូលព្រះបង្គំមានចិត្តស្នេហាស្មើជីវិតទូលព្រះបង្គំ តែតាមពិត ការចូលទៅតយុទ្ធនៅសមរភូមិមិនត្រូវយកភរិយាទៅផងទេ ។ បើទូលព្រះបង្គំយកភរិយានេះទៅផ្ញើនឹងអ្នកឯទៀតក្រៅអំពីព្រះអង្គ, ទូលព្រះបង្គំមិនអាចទុកចិត្តបានឡើយ ។ តែទូលព្រះបង្គំបានយល់ថា ព្រះអង្គទ្រង់មានព្រះរាជហឫទ័យស្មោះត្រង់ចំពោះបទបញ្ញត្តិច្បាប់, ទ្រង់ជាព្រះរាជូបត្ថម្ភក៍ចំពោះប្រជាជនទាំងអស់ព្រមទាំងព្រះរាជសេវកាមាត្យ, ទ្រង់ជាអ្នកឈ្នះនូវរាគាទិកិលេស, ទ្រង់ជាអ្នកប្រកបដោយព្រះមហាករុណាទិគុណ; គឺថាក្រោយដែលទូលព្រះបង្គំយកភរិយាមកផ្ញើនឹងព្រះអង្គ ទើបទូលព្រះបង្គំទៅកាន់សមរភូមិបាន ។ នេះជាបំណងរបស់ទូលព្រះបង្គំ ។ ទូលព្រះបង្គំជាប់បានយកអាសាអ្នកដទៃជាច្រើនណាស់មកហើយ; ហេតុនេះសូមទ្រង់ព្រះមេត្តាប្រោសទទួលភរិយាទូលព្រះបង្គំទុកឲ្យនៅជាមួយព្រះអង្គផង, ចាំទូលព្រះបង្គំវិលត្រឡប់មកពីធ្វើសង្គ្រាមវិញ" ។

ព្រះបាទវិក្រមាទិត្យយល់ព្រមទទួលភរិយាបុរសនោះយកទៅថែរក្សា ។ បុរសនោះក៏ធ្វើដំណើរទៅកាន់សមរភូមិកណ្ដាលអាកាស ។ ព្រះមហាក្សត្រិយ៍, ព្រះរាជទេវីប្រិក្សា មានចិត្តជឿងឆ្ងល់ពន់ពេកចំពោះ

អាកប្បកិរិយានៃបុរសនោះ  ក៏ឈរងើយមើលទៅបុរសនោះដែលកំពុងហោះទៅក្នុងអាកាសទាល់តែផុតកន្ទុយភ្នែក ។

កាលបុរសនោះបាត់ខ្លួន  អ្នកនោះលែងមើលឃើញហើយក្តាម, នគាល័យទាំងមូលពេញទៅដោយស័ព្ទស្នូរសំឡេងគឹកកងរំពងដូចជាមានកងទ័ពប្រយុទ្ធគ្នាលើទីនោះ ។ ព្រះមហាក្សត្រិយ៍ព្រមទាំងព្រះរាជទីប្រឹក្សាទាំងជនានុជនឯទៀត,  សឹងតែបាននូវស្នូរស័ព្ទដែលលាន់ខ្ទរខ្ទារពាសពេញមេឃនោះ  ហើយមានសេចក្ដីសង្ស័យគ្រប់គ្នា ។ ក្នុងពេលនោះ, ស្រាប់តែដៃពីរនៃស្វាមីនាង ក៏ដាច់ធ្លាក់មកចំមាត់ទ្វារចូលទៅក្នុងទីក្រុមព្រះរាជទីប្រឹក្សាអមព្រះអង្គ,  ដៃដាច់តមក,  ជើងពីរក៏ធ្លាក់មកទៀត, រួចក្បាលបុរសនោះក៏ជ្រុះមកជាដាច់ ៗ ភរិយានៃបុរសដាច់ក្បាល  ក្រឡេកទៅឃើញក្បាលស្វាមី ដាច់ធ្លាក់មកដូច្នោះ ក៏យំសោកស្តាយស្រណោះអាឡោះអាល័យជាខ្លាំង ហើយក្រាបបង្គំទូលព្រះមហា-ក្សត្រិយ៍ថា:  "ប្ដីខ្ញុំម្ចាស់ដូចជាព្រះចន្ទពេញបូណ៌មីបិតនៅក្នុងអាកាសដែលមានពពកបិទបាំងឬដូចជាផ្លេកបន្ទោរក្ដី ហើយរលត់រលាយបាត់នៅក្នុងពពក, ករណីយកិច្ចនៃភរិយាត្រូវតែរស់នៅជាមួយស្វាមី គឺថាភរិយាមិនត្រូវបោះបង់ចោលស្វាមី ខ្ញុំម្ចាស់នឹងមិនលះបង់ចោលស្វាមីទេ ។ ដូច្នេះសូមព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យគេប្រមូលឧសនឹងវត្ថុផ្សេង ៗ  មកគរសម្រាប់ធ្វើឈាបនកិច្ចនូវខ្លួនខ្ញុំម្ចាស់ជាមួយនឹងសពប្ដីនេះ" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់  នូវពាក្យភរិយានៃបុរសនោះក៏មានព្រះរាជហឫទ័យតក់ស្លុត  ព្រមទាំងអាណិតអាសូរដល់នាងពន់ពេក

ហើយមានព្រះពុទ្ធដីកាថាៈ "ទុនាង! មនុស្សរស់មានការធ្វើគមនាគមន៍ជាមួយគ្នា ក្នុងវេលាដែលជីវិតរស់នៅ ។ បើស្វាមីនាងមានជីវិតរស់នៅ ស្វាមីនោះមានចំណងជាប់នឹងនាងជាប្រពន្ធ ។ តែហេតុម្ដេចក៏នាងចង់លះបង់រូបនាង ដោយហេតុតែបុរសម្នាក់ដែលគ្មានធ្វើអ្វីល្មមឲ្យនាងសោកស្ដាយ តើមានបទបញ្ញត្តិច្បាប់ណាដែលបង្ខំនាងឲ្យប្រព្រឹត្តការតពូតកិច្ចបែបនេះ ដែលនាងត្រូវធ្វើឥឡូវនេះ? ។ បើនាងនឿយណាយនឹងវដ្តត្រៅ, ចូរនាងកក្រព្រហ្មចរិយធម៌ឲ្យគង់វង់ហើយនាងខំគោរពបូជាព្រះឥស្សរជានិរន្តរ៍ចុះ ។ បើនាងមានចិត្តសប្បាយក្នុងលោកាមិសនៅឡើយ ចូរនាងយកស្វាមីមួយទៀត ដែលនាងពេញចិត្ត ហើយត្រេកត្រអាលសប្បាយឲ្យបាននៅសុខជុំរមនាគតទៅ ។ យើងនឹងប្រគល់នូវភោគទ្រព្យឲ្យនាង ដើម្បីកុំឲ្យនាងមានទោសទុក្ខអ្វីសោះឡើយ" ។

នាងនោះលុះបានស្ដាប់នូវព្រះបន្ទូលស្បូវសីហនាទហើយ ក៏ទូលតបថាៈ "បពិត្រព្រះបក្រពត្រាធិរាជ ខ្ញុំម្ចាស់ជានិមិត្តរូបនៃករណីយកិច្ចទាំងឡាយចំពោះប្ដីខ្ញុំម្ចាស់; ព្រោះហេតុដូច្នោះ ស្នាដៃរបស់ខ្ញុំម្ចាស់ គឺការគោរពតាមករណីយកិច្ចនេះ ។ ដោយគុណធម៌នៃខ្ញុំម្ចាស់, ខ្ញុំម្ចាស់អាចប្រព្រឹត្តព្រហ្មចរិយធម៌ ដែលមានគោលការណ៍ថា លះបង់កាមឆន្ទៈបាន ហើយខ្ញុំម្ចាស់នឹងប្រព្រឹត្តករណីយកិច្ច ដែលញ៉ាំងចិត្តខ្ញុំម្ចាស់ឲ្យស្មោះត្រង់នឹងស្វាមី ។ តែបញ្ហានៃតណ្ហាដែលស្ថិតនៅក្នុងរូបមនុស្ស, សេចក្ដីយល់ឃើញជាក់ច្បាស់ចំពោះបថាមិត្ត ដែលមានអានុភាពអស្ចារ្យ, ការអនុវត្តន៍

ចំពោះបុណ្យកុសល, វត្ថុទាំងនេះត្រូវមានវីរិយភាពជាមូលដ្ឋាន ទើបប្រព្រឹត្តទៅបាន; ខ្ញុំម្ចាស់មានចិត្តទុព្វលភាពមិនអាចប្រព្រឹត្តបានទេ ។ ការប្រតិបត្តិតាមបទបញ្ញត្តិច្បាប់ សម្រាប់ស្ត្រីមេម៉ាយដែលមានសាស្ត្រៈបានកំណត់ទុក មានសភាពលំបាកពន់ពេក ។ លក្ខណៈនៃស្ត្រីមេម៉ាយនាំឲ្យស្ត្រីនោះប្រព្រឹត្តខុសផ្ទុយគ្នា ។ ដូចជាភរិយាត្រូវបានទទួលកេរ្តិ៍មត៌ករបស់ស្វាមី, មរណភាពនៃភរិយា គឺមកពីមរណភាពនៃស្វាមីដូចគ្នាដែរ ។ បតិវ្រតព្រះនរបតី កុងទុកាសធ្វើវិវាហមង្គលការ, កាលណាគេបានអុជភ្លើងក្រោយដែលបានសូត្រមន្តវេទ កាលនោះគឺជាអភិលក្ខិតកាល ដែលគេធ្វើពិធីផ្សំដំណេករវាងស្វាមីនឹងភរិយា គឺចំពោះកិច្ចព្រមព្រៀងរវាងគ្នាទៅវិញទៅមក ដែលជាមូលដ្ឋាននៃវិវាហមង្គលការ ។ ឧទាហរណ៍ ដូចស្ត្រីជាទម្រង់ក្រៅនៃថាមភាពបុរស ។ បិតនៅបានដោយគ្មានថាមភាព តែបើគ្មានបុរសថាមភាពក៏មិនអាចបិតនៅបាន ។ មួយទៀតដូចអគ្គីដែលគេយកមហាឱសធ (ausadhis) ទឹងមន្តវិសេសយកមកអុជ អគ្គីអាចកើតមានបានដោយសារមានអានុភាពនេះ, តែអានុភាពនេះមិនអាចមានបានបើគ្មានអគ្គី ។ បតិវ្រតព្រះសម្មតិទេព គេអាចស្គាល់បានដោយសុក្រិតកុងលោកថា បុគ្គលណាប៉ងនឹងបូជាជីវិតដល់វត្ថុណា បុគ្គលនោះឈ្មោះថាអ្នកធ្វើពលិកម្មដោយជីវិត ដែលមានសេចក្តីពេញចិត្តនឹងវត្ថុនោះពេញលក្ខណៈ ។ ព្រោះហេតុដូច្នោះ, បតិវ្រតព្រះបមកត, តាមយោបល់លោកសន្និវាស, សាស្ត្រៈនឹងតក្កវិជ្ជាត្រូវតែប្រព្រឹត្តសកម្មភាពនេះ ជាដាច់ខាតខានមិនបាន ។ តើមានផលប្រយោជន៍អ្វីត្រង់ការ

ស្តាបនាទូវនូវបសុគ្គមានទំនងយ៉ាងនេះ ? កាលណា ប្រាជ្ញាបុគ្គលផ្ដិតជាប់នៅនឹងវត្ថុមួយ បុគ្គលឯទៀតរិតរំហាម តែជាការឥតប្រយោជន៍សោះ ។ ដូចជាទឹកហូរទៅកាន់ទីទាប បើអ្នកណាចង់ឃាត់ឲ្យទឹកនោះឈប់ហូរទៅវិញ ជាការឥតប្រយោជន៍ទាំងអស់ ” ។

ព្រះនរបតីទ្រង់ព្រះសណ្ដាប់នូវពាក្យ នៃនាងជាភរិយាបុរសនោះ ហើយទ្រង់ឈ្វេងយល់ថា “នារីនេះសម្រេចដាច់ខាតថានឹងទទួលអនិច្ចកម្ម ដើម្បីស្វាមីជាប្រាកដ ”, ទ្រង់ក៏មានព្រះបន្ទូលថា “ល្អហើយដែលនាងមានចិត្តស្មោះត្រង់នឹងស្វាមី ពាក្យដែលនាងពោលទាំងអម្បាលម៉ាន ជាពាក្យថ្លៃថ្លាបំផុត ! ។ ពាក្យដែលយើងពោល គឺជាពាក្យគ្មានដំឡៃឡើយ ; ពាក្យនេះគឺយើងគ្រាន់តែពិសោធមើលចិត្តនាងតែប៉ុណ្ណោះ” ។

ព្រះនរបតី, ក្រោយដែលបានទ្រង់ត្រាស់ទៅនឹងស្ត្រីដែលមានចិត្តស្មោះត្រង់នឹងស្វាមី, ទ្រង់ត្រាស់បង្គាប់ឲ្យគេធ្វើជាឈាបនដ្ឋាន ។ ដល់ពេលធ្វើពលិកម្មនាងជាភរិយាមានចិត្តក្ដៅ ដោយសេចក្ដីស្នេហាចំពោះស្វាមី បានដើរចូលទៅក្នុងគំនរភ្លើង ដូចជាបុរសដែលមានសភាពក្ដៅស្អុះចុះទៅក្នុងទឹកត្រជាក់ដូច្នោះឯង ។ ព្រះមហាក្សត្រិយ៍នឹងព្រះរាជទីប្រឹក្សាបានសរសើរនូវគុណនៃនាងជាអនេកប្បការ ។

(មានត)

# ការដាំដើមឈើយកផ្លែ

ឃុនអគ្គការិទ ជា - យឿវ ពុទ្ធសាសនបណ្ឌិត្យ

ប្រែពីសៀវភៅកសិករ ឆ្នាំទី ១២ ភាសាថៃ

---

ដើមឈើដែលគេបរិភោគផ្លែ គឺដើមឈើដែលមានអាយុយឺនយូរបានច្រើនឆ្នាំ ដូចខ្នុរ ស្វាយ ក្រូចផ្សេងៗ រហូតដល់ក្រូចសើច ក្រូចឆ្មារជាដើម ។ បើភូមិលំនៅរបស់យើងមានទីដីទំនេរ យើងគួរដាំដើមឈើទាំងនោះទុក ព្រោះថាកាលយើងដាំទៅហើយ ឈើនោះក៏រស់នៅយូរអង្វែងជាប្រយោជន៍រហូតដល់កូនចៅ ជាមរតកសំខាន់សំរាប់ផ្ដល់ឲ្យដល់អ្នកដែលតវង្សត្រកូលៗ ក្រៅអំពីយកផ្លែបរិភោគ ដើមឈើទាំងនោះនាំឲ្យមានម្លប់ត្រជាក់ដល់ទីលំនៅរបស់យើង ហើយជាគ្រឿងលំអដល់ភូមិលំនៅទៀតផង ។ ដូច្នេះសូមលោកកុំបោលឱកាសដ៏ល្អនេះឲ្យសោះ បើប្រសិនជាមានទីដីទំនេរ ។ គោលទូទៅនៃការដាំដើមឈើទាំងនោះ នឹងចាត់របៀបទុក ដូចតទៅនេះ :

## ការរើសពូជយកមកដាំ

ការរើសពូជឈើយកមកដាំ ជាកិច្ចសំខាន់បំផុត ព្រោះដូច្នោះ មុនដែលនឹងយកពូជឈើណាមួយមកដាំ ត្រូវរើសពូជឲ្យល្អជាមុនសិន ។ គោលទូទៅនៃការរើសពូជ គួរនឹកដល់សេចក្ដីទាំងនេះ :

១– រើសយកពូជដែលគេនិយមរាប់អានច្រើន ,

២– រើសយកពូជដែលមានរសជាតិល្អ ,

៣ - រើសយកពូជដែលមានពណ៌សម្បុរល្អ គួរស្រឡាញ់ គួរបរិភោគ

៤ - រើសយកពូជដែលលក់បានថ្លៃច្រើន,

៥ - រើសយកពូជដែលមានផ្លែកាន់ច្រើន,

៦ - រើសយកពូជដែលមិនមានរោគ,

៧ - រើសយកពូជដែលមានដើមដងរឹងប៉ឹង ( ដូច្នេះជាដើម ) ។

## ការត្រៀមពូជសំរាប់ដាំ

ឈើដែលគេបរិភោគផ្លែ ដោយច្រើនគេដាំដោយគ្រាប់ ហើយគ្រាប់ដែលទឹងយកទៅដាំនោះ ត្រូវបណ្តុះឬផ្សាំជាមុនសិន ។ បណ្តុះឬផ្សាំនេះល្អជាងការដាំដោយគ្រាប់ ព្រោះនាំឲ្យមានការថែរក្សាតិចជាងការដាំគ្រាប់ ហើយស្រួលក្នុងការថែរក្សា ទាំងមានឱកាសរើសដើមដងដែលរឹងប៉ឹងបានពេញទី ។ ការបណ្តុះឬផ្សាំដើមឈើដែលបានផលល្អនោះត្រូវធ្វើដូច្នេះ :

១ - ត្រូវយកគ្រាប់ដែលទឹងបណ្តុះនោះដាក់ចុះទៅក្នុងបំពង់ឫស្សី ហើយចោះរន្ធខាងបាតបំពង់លួមឲ្យទឹកជ្រាបចេញបាន ឬបណ្តុះក្នុងថើងតូច ៗ ក៏បាន ។ បំពង់ឫស្សីឬថើងនោះ ត្រូវយកវាតម្រៀង ៗ រងពីក្រោមដូចជាក្បាកបណ្តុះដែរ គឺយកដុំគ្រួសឬខ្សាច់គ្រើមមកដាក់រងខាងក្នុងបាតរួចយកស្មៅស្ងួតដាក់ឲ្យលួមសមគួរ ហើយយកដីដាក់ទាល់តែពេញ ហើយទើបយកគ្រាប់ឈើដែលទឹងបណ្តុះដាក់បណ្តុះទៅ ។ ក្នុង ១ បំពង់ឬ ១ ថើង គួរដាក់ ១ គ្រាប់ឬ ២ គ្រាប់ឬច្រើនជាងនោះក៏បាន ហើយត្រូវស្រោចទឹកឲ្យជោកជាំជានិច្ច ។ កាលគ្រាប់នោះមានពន្លកដុះឡើងមក

ហើយ ត្រូវថែរក្សាឲ្យល្អកុំឲ្យមានអន្តរាយ លុះដល់ចូលរដូវភ្លៀងក៏នាំយកទៅដាំ ។ ក្នុងពេលដែលដាំ ត្រូវពុះបំពង់បំបែក, បើដាំផើងក៏ត្រូវវាយបំបែកចេញដែរ ។

២- ការបណ្តុះគ្រាប់ក្នុងរង ក៏ត្រូវធ្វើរងដូចរងដាំបន្លែផ្សេងៗ ហើយបណ្តុះក៏ដូចជាការបណ្តុះបន្លែផងទាំងពួង ត្រូវឧស្សាហ៍ស្រោចទឹកហើយយកស្មៅស្ងួតមកគ្របទុកឲ្យដីសើមហើមទន់ជានិច្ច ។ កាលគ្រាប់នោះមានពន្លកដុះឡើងមកហើយ ត្រូវគាស់យកទៅដាំផ្ទាំទុកនៅរងផ្ទាំ ។ ពេលដល់រដូវភ្លៀងក៏គាស់យកទៅដាំក្នុងរណ្តៅ ។ ធ្វើតាមរបៀបនេះ ងាយជាងរបៀបទី ១ តែពេលដែលដាំហើយនោះ ដើមឈើច្រើនអន់ទន់ស្រពោនស្វិតរហូតដល់ទៅងាប់ក៏មាន ព្រោះដូច្នោះត្រូវប្រយ័ត្នកុំឲ្យប៉ះទង្គិចដាច់ឫសដាច់ដើមចេញដែរ ។

៣- ការបណ្តុះក្នុងរងមានរបៀបដូចវិធីទី ២ ដែរ តែកាលដើមខ្ចីនោះ ដុះឡើងមានសទឹកប្រហែលពីរ-បីគូហើយ ត្រូវដកយកទៅដាំផ្ទាំទុកក្នុងបំពង់ឫស្សីឬក្នុងផើងដូចរបៀបទី ១ ។

ដើមឈើហូបផ្លែ ក្រៅពីដាំដោយគ្រាប់ហើយ នៅមានរបៀបដាំដោយវិធីសាកមែកម្យ៉ាងទៀត ដូចក្រូចផ្សេងៗ ទុរេន មៀន ល្មុត ។ល។ ការដាំដោយការសាកមែក បានផលល្អជាងដាំដោយគ្រាប់ គឺធ្វើឲ្យឆាប់មានផ្លែទាំងមានផ្លែកាន់ច្រើនផង ដើមក៏ទាប គួរឲ្យចង់មើល ។ តែដើមឈើដែលដាំដោយមែកសាក ច្រើនតែមានអាយុមិនយឺនយូរ មិនដូចជាដាំដោយគ្រាប់ឬដោយដើមខ្ចីទេ ។ បើពូជឈើណាល្មមដាំដោយមែក

សាកបណ្ដុះក៏គួរសាកទុកពីក្នុងរដូវភ្លៀង ។ ពូជខ្លះចេញឫសឆាប់ ដូចទទឹមទឹងក្រូចថ្លុង ៗ គេសាកហើយដាំបានក្នុងឆ្នាំនោះឯង ។ មានពូជខ្លះក្រចេញឫសត្រូវកាត់យកមកផ្សាំទុកនៅក្នុងថង់ឬក្នុងប៉ោតជាមុនសិន ទំរាំយកទៅដាំក្នុងរណ្ដៅធំ ។ លុះដល់ចូលរដូវភ្លៀងឆ្នាំថ្មី ទើបគួរគាស់យកទៅដាំក្នុងរណ្ដៅ ។

ពូជខ្លះមានរសផ្អែមឬមានរសឆ្ងាញ់ល្អ មានផ្លែកាន់ច្រើនទាំងមានដំឡៃផងតែមិនសូវធន់ទឹកដីអាកាស ។ បើយើងយកមកដាំនៅទីកន្លែងដែលមានទឹកដីអាកាសខុសប្លែកពីកន្លែងដើម ពូជនោះច្រើនតែងាប់ឬមានរសជាតិក្លាយខុសពីរសជាតិដើម ។ មានវិធីមួយដែលទីងនាំពូជទាំងនោះមកដាំឲ្យទៅជាឈើដែលធន់ទាំងមានរសជាតិដូចដើម ហើយលក្ខណៈទីងគុណសម្បត្តិក៏នៅគង់វង់ដូចដើម ត្រូវប្រើវិធីបម្លាប់ឬវិធីតមែក គឺដាំដើមឈើដែលធ្លាប់មាននៅក្នុងស្រុក ដែលជាពូជឬជាពួកជាមួយគ្នាឲ្យជញ្ជក់យកអាហារ ព្រោះទឹកដីអាកាសនៅទីនោះ ឈ្មោះថាជាម្ដាយឪពុករបស់ឈើនោះបានពេញទី អាចឲ្យចំណីអាហារដល់កូនបានដោយបរិបូណ៌ ហើយទើបយកពកឬមែកឈើដែលពោលមកហើយនោះ មកភ្ជាប់ឬតដោយវិធីបម្លាប់ឬវិធីតមែក ។

ម្យ៉ាងវិញទៀត ត្រូវលាក់មែកឈើ ដែលធ្លាប់ដាំនៅក្នុងស្រុកដូចពោលមកហើយ ដូចវិធីលាក់សសរដោតរត តែលាក់ឲ្យឈៀងឡើងលើ ហើយលាបដីត្រង់កន្លែងដែលលាក់ ទើបយកមែកឈើដែលសាកដុះឫសហើយ ដែលជាពួកជាមួយគ្នាមកប្រហាកត្រង់កន្លែងដែលលាក់ ហើយ

យកដីបិទផ្ដុំវិញ យកស្រែកដូនរុំស្រោប ហើយយកទឹកបំពង់ដាក់សម្រក់ពីលើ ៗ កាលដុះសាច់ជាប់គ្នាស្រួលបួលហើយ ទើបកាត់មែកឈើដែលដាំនោះចោល ទុកតែមែកសាក ៗ ធ្វើដូច្នេះ ហៅថាវិធីបម្លាស់ឬភ្ជាប់មែក ៗ វិធីនោះឃើញមានគេធ្វើដោយច្រើន ទាំងបានលទ្ធផលដ៏ល្អ គឺបានបំរើនដុះដាលពលគុម្ពកង់ប្រទេសយើង មានផ្លែដក់ច្រើនរសជាតិគង់វង់ដូចដែល ៗ

## ការត្រៀមដីនិងការជីករណ្ដៅដាំ

ដើមឈើបរិភោគផ្លែគ្រប់ចំពូក ត្រូវមានការត្រៀមដីនិងការជីករណ្ដៅឲ្យល្អ ៗ ឯដីដែលដាំដើមឈើបរិភោគផ្លែ បើជាដីស្អិតហើយដាំដើមឈើខ្ពតធំ គួរជីករងើបង្ហូរទឹកចូលនឹងបង្ហូរទឹកចេញ, បើដីតែស្អិតច្រើន ត្រូវជីកបង្ហូរទឹកចេញចូលឲ្យយ៉ាងច្រើន, កាលទឹកហូរចេញពីដីអស់ហើយ គទៅយើងធ្វើដីនោះឲ្យល្អឡើងបានដោយងាយ ៗ

ហេតុនេះ ការដែលដាំដើមឈើបរិភោគផ្លែ គួរបំរុងដីឲ្យល្អល្មមសមគួរជាមុនសិន គឺត្រូវកាប់ឬភ្ជួររាស់ឲ្យដីល្បាយកាយល្អឬដាំបន្លែដទៃ ១ អួយឆ្នាំពីរឆ្នាំសិនក៏បាន ។ បើកន្លែងនោះមិនដែលដាំអ្វីទេ គួរដាំសណ្ដែកបាយសណ្ដែកអង្គុយ ១ ឆ្នាំ ឬ ២ ឆ្នាំសិន ៗ សណ្ដែកដែលដាំនោះបេះផ្លែស្រេចហើយ ត្រូវភ្ជួរលុបត្រឡប់ទៅក្នុងដី ៗ

ការត្រៀមរណ្ដៅដាំ, រណ្ដៅសម្រាប់ដាំឈើធំ គួរត្រៀមទុកជាមុនយ៉ាងតិចត្រឹមពីរអាទិត្យ, រណ្ដៅនោះត្រូវជីកឲ្យទូលាយប្រហែល១ម៉ែត្រ,

ដំពៅក៏ត្រូវជីកឲ្យជ្រៅប្រហែល ១ ម៉ែត្រដែរ ស្រាវមើលតាមតួដធំ-តូច ទាប-ខ្ពស់ បើជីករណ្ដៅឲ្យជ្រៅដូច្នេះជាហេតុឲ្យដីធូរ ងាយដំណាំល្អ, ពេលជីកនោះត្រូវយកដីខាងលើគរទុក ១ ផ្នែក យកដីខាងក្រោមគរទុក ១ ផ្នែកទៀត, កាលជីកហើយត្រូវទុករណ្ដៅនោះហាលថ្ងៃ ១ អាទិត្យសិន ហើយទើបយកដីដាក់ ទាំងបាតអន្លង់ចន្លោះប្រហែលបាន ហើយយកស្មៅស្ងួតដាក់ចុះទៅ យកដីខាងលើលុបជាមុនសិន ហើយទើបយកដីខាងក្រោមលុបបន្ថែមទៀតទាល់តែពេញរណ្ដៅ ហើយទុកហាល ១ អាទិត្យទៀតដើម្បីឲ្យស្មៅស្អុយឲ្យដីស្រួតទៅបន្តិចសិនហើយទើបដាំ ។

# រដូវដែលគួរដាំដើមឈើបរិភោគផ្លែ

ឈើបរិភោគផ្លែគប់ចំពូក ត្រូវដាំនៅដើមរដូវភ្លៀង ព្រោះមិនសូវកន្ទ្រល់ក្នុងការស្រោចទឹក, កាលអស់រដូវភ្លៀងហើយ ដើមឈើនោះក៏ធំល្មមសមគួរអាចធន់ទ៏ងរដូវរាំងក៏បាន, បើដាំក្នុងរដូវរាំងត្រូវមានកន្ទ្រល់ក្នុងការស្រោចទឹក ហើយដើមឈើក៏ច្រើនតែងាប់ ទោះបីមានរស់ខ្លះក៏មិនសូវលូតលាស់ល្អដែរ ។

# រយៈដាំដើមឈើ

ដើមឈើបរិភោគផ្លែផ្សេងៗ ដែលទីងដាក់គោលចារកឲ្យប្រាកដថាត្រូវដាំឲ្យឃ្លាតពីគ្នាប៉ុណ្ណេះប៉ុណ្ណោះពុំបានឡើយ ព្រោះដើមឈើមានខាតតូចធំជាងគ្នា ទាំងដីក៏មានជាតិមិនដូចគ្នា ព្រោះដូច្នោះយើងទីងដាក់កំរិតទុកដើម្បីត្រិះរិះខ្លួនឯងដូចតទៅនេះ ៖

១– ស្រេចតែរបៀបរបស់ដី បើដីល្អគួរដាំឲ្យឃ្លាតគ្នាបន្តិច ព្រោះឈើនោះអាចដុះដាលពលគុម្ព ពន្លឹកមែកធាងបានទូលំទូលាយ, បើដាំញឹកពេកឈើនោះនឹងលូតខ្ពស់មានស្លឹកច្រើនមិនសូវមានផ្លែ ទាំងមិនសូវធន់ធារចំពោះរោគផ្សេងៗផង ។ ក្នុងពេលដែលមានរោគ ច្រើនឆ្លងទៅដល់ដើមឈើឯទៀតពេញទាំងចំការ ។ បើដីមិនសូវមានជីជាតិល្អទេ ត្រូវដាំឲ្យញឹកជាងដីដែលមានជីល្អបន្តិច ព្រោះដីមិនល្អដើមឈើក៏មិនសូវដុះដាលពលគុម្ព ពន្លឹកមែកតែខ្លីៗ ។

២– ស្រេចតែការពន្លឹកមែកធាងនិងស្លឹក បើដើមឈើណាពន្លឹកមែកបានឆ្ងាយហើយមានស្លឹកច្រើន គួរដាំឲ្យឃ្លាតពីគ្នា, បើដាំញឹក ស្លឹកនឹងគ្របទៅលើគ្នា ពន្លឺថ្ងៃចាំងមិនដល់ផែនដី ។

៣– ទុករយៈឲ្យពន្លឺថ្ងៃចាំងដល់ផែនដី ប្រៀបដូចជាពូជឈើខ្លះពន្លឹកមែកបានត្រឹម ១ម,៥០ ឈើ ១ ទៀតក៏ពន្លឹកមែកបាន ១ម,៥០ ដែរ ឈើចំពូកនេះ បើដាំឃ្លាតគ្នា ៣ម, មែកនឹងលូតទៅដល់គ្នា ពន្លឺថ្ងៃចាំងមិនដល់ផែនដី ទើបគួរដាំឲ្យឃ្លាតគ្នាចំនួន ៤ម, ទុកឱកាសឲ្យពន្លឺថ្ងៃចាំងដល់ផែនដី ។

៤– ស្រេចនូវការចាក់ឫស បើពូជឈើឫសវែង គួរដាំឲ្យឆ្ងាយពីគ្នា តាមពួកឈើ មានកំរិតដូចមែកនិងស្លឹកដូច្នោះដែរ ។

ឥឡូវនេះ នឹងកំរិតគោលក្នុងការដាំដើមឈើប្រភេទខ្លះដូចតទៅនេះ ៖

| | | |
|---|---|---|
| បេក | ដាំឆ្ងាយពីគ្នា | ៣ម,៥០ – ៤ម៉ែត្រ |
| ទទឹម | – – | ៣ម,៥០ – ៤ – |

| | | | |
|---|---|---|---|
| ទៀប | ដាំឆ្ងាយពីគ្នា | ៤,៥០ – ៥ម៉ែត្រ | |
| លុង | – – | ៣,៥០ – ៤ | – |
| ក្របធ្នោរ | – – | ៥, – ៦ | – |
| ក្របផ្សេងៗទៀត | – – | ៥, – ៧ | – |
| ខ្នុរ | – – | ១០ | – |
| មៀន | – – | ១០ | – |
| ដូង | – – | ៨, – ១០ | – |
| ម៉ាក់ប្រាង | – – | ៧, – ៨ | – |
| ស្វាយ | – – | ១០ | – |
| លុត | – – | ៤, – ៥ | – |
| សាវម៉ាវ | – – | ៧, – ៨ | – |

## ធញ្ញជាតិ (ប៉ែកខាងបន្លែ)

## សណ្តែក

សណ្តែកជាបន្លែដែលឲ្យប្រយោជន៍ដល់កងកាយយ៉ាងច្រើន ទាំងជាចំនិញដ៏សំខាន់ ៗ សណ្តែកផ្សេង ៗ នៅស្រុកយើង គឺសណ្តែកដី សណ្តែកឡាន់តៅ សណ្តែកសៀង ទាំងបន្លែដែលមានដំឡូងដទៃទៀត ដូចជាពពាយផ្លែង ពពាយស្បែកជាដើម ៗ សណ្តែកទាំងនោះ យើងអាចចែកចេញជាប្រភេទ ៗ ដូចតទៅនេះគឺ

១ – សណ្តែកដែលឡើងច្រើន

## ២– សណ្តែកដែលមិនឡើងទ្រើង ។

សណ្តែកគ្រប់ប្រភេទ ចូលចិត្តដីល្បាយហើយសើម គេត្រូវដាំដោយគ្រាប់ ដាំបានគ្រប់រដូវ បេះផ្លែបានក្នុងរវាង ៩០ ថ្ងៃ ។ សំរាប់សណ្តែកគួរវែង, គួរដាំជាជួរ, ក្នុងមួយជួរឆ្ងាយពីគ្នាមួយម៉ែត្រ, ក្នុង១ គុម្ពឆ្ងាយពីគ្នា ៥ តឹក, •ក្នុង ១ រណ្តៅត្រូវដាំ ៣ គ្រាប់, កាលលូតលាស់ធំឡើងបន្តិចនឹងបោះទងឡើងទ្រើង ត្រូវរកទ្រើងមកបោះនៅក្បែររណ្តៅឲ្យចុងទ្រើងទាំងពីររួមចូលគ្នាជាពូក ។ ក្នុង១ ពូកបួនរណ្តៅ ។

សត្រូវមានក្រានិងខ្យងជាដើមច្រើនហើរមកស៊ីស្លឹកនិងផ្កាមានច្រើនក្នុងរដូវភ្លៀង ។ ចំណែកសណ្តែកឡាន់តៅត្រូវកំណត់រយៈឲ្យមានផ្លែនៅរដូវរងា, ត្រូវដាំជាជួរកោយគ្រាប់ឲ្យឆ្ងាយពីគ្នាក្នុងរវាង ១ តឹក ។, ធ្វើជួរឲ្យឆ្ងាយពីគ្នា ៣ តឹក, កោយគ្រាប់ឲ្យជ្រៅប្រមាណ ១ តឹក កុំឲ្យមានទឹកដក់ជោកដាំ, តែមានទឹកស្លឹករាទឹងលឿងនាំឲ្យខូចដើម វាត្រូវការស្នូសំរាប់តោង, ត្រូវបោះបង្គោលចំងាយពីគ្នា ១ ម៉ែត្រ ហើយយកស្នូមកបង់តាមបង្គោលនោះកំពស់ ១ ម៉ែត្រ, រយៈស្នូឆ្ងាយពីគ្នារវាងពីរតឹកកន្លះ ។

ចំណែកប្រពាយជ្រុងនិងផុះដាលបានតែក្នុងរដូវភ្លៀង ដល់រដូវរាំងងាប់ តែគល់មិនងាប់ទេ នឹងលូតលាស់បានក្នុងរដូវភ្លៀងម្តងទៀត ផ្លែវាគេធ្វើជាអាហារបានយ៉ាងល្អ គេដាំដោយគ្រាប់ឲ្យវាឡើងទ្រើងស្នូរបង ក្នុងរវាង ៦០ ថ្ងៃ នឹងបានផ្លែបរិភោគ, ដាំចំងាយពីគ្នាប្រមាណ ១ ម៉ែត្រ ក្នុងមួយជួរ ។ ឬ ១ ដើម ។ ព្រោះវាវារបានឆ្ងាយ ដាំក្បែររបងក៏បានដែរ ។

ធញ្ញជាតិម្យ៉ាងទៀតស្រដៀងនឹងពួកសណ្ដែកគឺប៉ិកគក់, គេដាំដោយគ្រាប់, ដាំនៅចុងរដូវភ្លៀង, ដាំក្នុង១ជួរឆ្ងាយពីគ្នា ៥ តឹក, ក្នុង ១ ដើមឆ្ងាយពីគ្នា ៣ តឹក, អាយុប្រមាណ ១៦០ ថ្ងៃ នឹងបានមើមបរិភោគ ផ្ទៃបាស់មានពិសបរិភោគពុល បើចង់ឲ្យមើមល្អត្រូវកាត់ដើមចោលខ្លះ ។

ដំណឹងថ្មី

## សូមជំរាបអស់លោក-អ្នក!

ក្នុងឆ្នាំ ១៩៥៦ នេះ មានអស់លោក-អ្នកជាច្រើននាក់ ដែលយឺតដំណើរក្នុងការផ្ញើឈ្មោះទៅចុះជាវកម្ពុជសុរិយា ហើយក៏ខកខានមិនបានអានទស្សនាវដ្ដីនេះទៅ ។

ឥឡូវឆ្នាំ ១៩៥៧ ជិតមកដល់ហើយ ដូច្នេះ អស់លោក-អ្នកដែលស្ម័គ្រអានទស្សនាវដ្ដីនេះ សូមផ្ញើនាមទៅពុទ្ធសាសនាបណ្ឌិត្យក្នុងខែវិច្ឆិកា និង ខែធ្នូ ១៩៥៦ នេះ កុំខាន ។

# កំណាត់ជីវប្រវត្តិការណ៍

## ពិធីបុណ្យកតញ្ញូកតវេទិតា

## នៃក្រុមសិស្ស ធ្វើចំពោះសម្តេចព្រះធម្មលិខិត ល្វី-ឯម

ព្រះមហា សម - សុខ សុមនោ

អាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា

វត្តលង្កា ភ្នំពេញ

រៀបរៀង

លោក ឯន - ប៉ង់ ពិនិត្យកែសម្រួល

---

### អាទិកថា

កាលពីវេលារសៀលថ្ងៃទី៩ មិថុនា ១៩៥៦, នៅធម្មកុដិក្នុងវត្តលង្កា សង្កាត់លេខ ៦ ភ្នំពេញ មានធ្វើពិធីបុណ្យមួយយ៉ាងឧឡារិក ដើម្បីឧទ្ទិសកុសលទាំងប្រសិទ្ធិពរជោគជ័យជាការតបព្រះគុណ ចំពោះសម្តេចព្រះធម្មលិខិត ល្វី - ឯម ឧត្តមប្រឹក្សាគណៈមហានិកាយ ចៅអធិការវត្តលង្កា ក្រោមការចាត់ចែងនៃក្រុមសិស្សានុសិស្សទាំងបព្វជិតទាំងគ្រហស្ថខ្លះ នៃពុទ្ធបរិស័ទទាំងឡាយ ដែលជ្រះថ្លាចំពោះសម្តេចខ្លះ ៗ

លើលានខាងមុខហោត្រៃ ទាំងខាងជើងធម្មកុដិនោះ គេតាក់តែងផ្កាទាំងស្លឹករុក្ខជាតិផ្សេង ៗ ទាំងមានរៀបបញ្ជរក្តាខៀនធំមួយចារិក

អក្សរធំៗថា "បុណ្យកតញ្ញូកតវេទិតា បំពោះសម្តេចព្រះធម្ម-លិខិតឧត្តមប្រឹក្សា" ។

នៅម៉ោង ៨, ៣០ នាទី ក្រុមព្រះភិក្ខុសង្ឃគ្រប់វត្តនោះ នាំគ្នាធ្វើគារវកិច្ចចំពោះសម្តេច ។ ក៏បានប្រទានឱវាទយ៉ាងខ្លីដោយឥតព្រាងទុកជាមុនថា "ខ្ញុំមានសេចក្តីត្រេកអរជាអនេកចំពោះលោកទាំងអស់អង្គ ដែលបានប្រមូលគ្នាធ្វើកិច្ចតបឧបការគុណដល់ខ្ញុំដែលជាគ្រូបាធ្យាយ៍ សូមឲ្យអស់លោករក្សាអប្បមាទធម៌ រក្សាសាមគ្គីធម៌ ដើម្បីថែទាំរក្សាព្រះពុទ្ធសាសនាឲ្យបានរុងរឿងទៅអនាគត" សម្តេចមានថេរដីការតែប៉ុណ្ណេះ ក៏គង់ស្ងៀមទៅ ។

ក្នុងឱកាសនោះ យើងសង្កេតឃើញការនិមន្តមកនិងការអញ្ជើញមកនៃព្រះភិក្ខុសង្ឃនិងគ្រហស្ថទាំងឡាយ ចំណែកខាងព្រះសង្ឃគឺ សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះសុធម្មាធិបតី កុល-ទេស ស្តីទីសង្ឃនាយកគណៈធម្មយុត្តិ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត បាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងព្រះសង្ឃរាជាគណៈឋានានុក្រមឯទៀតជាច្រើន ; ចំណែកខាងគ្រហស្ថគឺ លោក អេង-សុទ្ធ ព្រះរាជអាជ្ញាសាលាដំបូងភ្នំពេញ, លោក ឃិន-ផៃ បាងហ្វាងអនុវិទ្យាល័យកម្ពុជបុត្រ, លោក ប៉ាយ-ប៊ុក អធិបតីមិត្តពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, លោកគ្លី-គង់, លោកមាស-ម៉ន, លោកពុត-អ៊ុំ អតីតទីប្រឹក្សាជាតិ, លោកម៉ម-ម៉ែម អធិបតីគណៈកម្ម-

ការវត្តលង្កា, លោកចាប-ពិន នាយការិយាល័យទំនៀមទម្លាប់ខ្មែរ និងអស់លោក-អ្នកឯទៀតជាច្រើន ដែលយើងសូមអភ័យទោសដោយមិនបានរាប់នាមទាំងអស់គ្នាទីនេះ ។

ពេលដែលព្រះភិក្ខុសង្ឃទាំងពួងបរិស័ទទាំងឡាយ មកជួបជុំគ្នាសន្និបាតនោះ លោកឈឹម-ស៊ុំ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរ-ម្រិត តំណាងសិស្សានុសិស្សទាំងពួងបរិស័ទ បានថ្វាយសុន្ទរកថានៅចំពោះព្រះករុណាសម្តេចព្រះធម្មលិខិត រួចព្រះតេជព្រះគុណព្រះពុទ្ធវង្សកៅ-សឹម តំណាងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ថ្លែងសំវេគប្បកាសតបសិស្សានុសិស្សវិញ ។ បន្ទាប់មកព្រះតេជព្រះគុណព្រះពុទ្ធវង្សថ្លែងសង្កថារបស់លោកជាភាសាបាលីដ៏ខ្លីចំពោះសម្តេចទៀត ។ តមកព្រះភិក្ខុសង្ឃ ១០ រូបចំរើនព្រះបរិត្តជាជ័យមង្គលក្នុងទីចំពោះព្រះករុណាសម្តេច, រួចព្រះសង្ឃឯទៀត ៧៨ រូបចំរើនព្រះបរិត្តនៅក្នុងវិហារ, រួចសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយសំដែងធម៌ទេសនា ។

លុះចប់ធម៌ទេសនាហើយ សម្តេចបានបួងសួងថា " ដោយអានុភាពនៃធម៌ទេសនា ដែលខ្ញុំសំដែងប្រកបដោយទឹកចិត្តដ៏បរិសុទ្ធ ដោយមិនប្រាថ្នាលាភសក្ការៈប្តូរបៀតបៀនអ្នកណាមួយនោះ សូមឲ្យជួយអភិបាលសម្តេចព្រះធម្មលិខិតឲ្យបានជាសះស្បើយចាករោគ ទាំងសូមតេជះនៃធម៌នេះជួយបង្ហាញឱសថយ៉ាងចំណានដល់គ្រូពេទ្យ ដែលកំពុងតែព្យាបាលសព្វថ្ងៃ ដើម្បីព្យាបាលឲ្យបានជាសះស្បើយក្នុងពេលដ៏ខ្លីខាងមុខនេះ " ។

ពេលព្រឹកឡើងថ្ងៃទី ១០ ខែឆ្នាំដដែល ក្រុមសិស្សានុសិស្សខ្លះ និង

ពុទ្ធបរិស័ទទាំងឡាយខ្លះ បានរៀបចំតាក់តែងចង្ហាន់បិណ្ឌបាតដាក់បាត្រ ប្រគេនព្រះភិក្ខុសង្ឃដែលគេនិមន្តពីវត្តមហាមន្ត្រី ៣០ រូប, វត្តកោះ ៣០ រូប, វត្តបទុមវតី ១៨ រូប ។ ប៉ុន្តែគេរៀបតាក់តែងកប៉ាល់បាត្រជាពីរកន្លែង ១ កន្លែងនៅលានខាងជើងធម្មសភាទីនាំហោត្រៃ; ១ កន្លែងទៀតនៅលើយធម្មសភាសម្រាប់សម្តេចតែមួយអង្គដាក់បាត្រ ។

នៅមុនពេលដែលសម្តេចដាក់បាត្រ សម្តេចមានបន្ទូលថា " ខ្ញុំសូមផ្សាយកុសលដែលកើតឡើងពីចង្ហាន់បិណ្ឌបាតនេះ ចំពោះសត្វក្នុងត្រៃលោក សូមឲ្យសត្វទាំងនោះបានសេចក្តីសុខ ចំរើន កុំបីចងអាឃាតព្យាបាទគ្នា គប្បីរក្សាគ្នានឹងគ្នាឲ្យបានសុខរៀងរហូតទៅ " ដូច្នេះហើយសម្តេចចាប់ចង្ហាន់ដាក់បាត្រព្រះសង្ឃទាំងឡាយ ។

នៅពេលបញ្ចប់ការដាក់បាត្រ, ព្រះសង្ឃទាំងឡាយបានស្វាធ្យាយធម៌ប្រគេនសព្ទសាធុការពរចំពោះសម្តេច និងជូនពរដល់ទាយកទាយិកាទាំងឡាយគ្រប់ៗគ្នា: បន្ទាប់ពីនោះលោកម៉ម-ម៉ៃ ប្រធានគណៈកម្មការវត្តបានថ្លែងសង្កថាមួយដ៏ខ្លីទទួលអំណរគុណតាមឧត្តោសនសព្ទតាងនាមនៃសិស្សានុសិស្សទាំងអស់ ។

ពិធីបុណ្យនេះចប់ត្រឹមប៉ុណ្ណោះ ។

*
*   *

វិសុទ្ធកថា, សំរេគប្រកាស និងសង្កថា យើងស្រង់យកមកចុះដូចតទៅនេះ :

## សុន្ទរកថា

របស់លោក ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៃពុទ្ធិកវិទ្យាល័យសុរាម្រឹត តំណាងក្រុមសិស្សនឹងពុទ្ធបរិស័ទ

សូមគោរពចំពោះសម្តេចទាំងពីរព្រះអង្គជាសង្ឃបិតា !

សូមគោរពព្រះថេរានុត្ថេរទាំងឡាយ !

សូមឱកាសអស់លោក អ្នកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំប្របាទ ខ្ញុំបាទ ខ្ញុំ ជាតំណាងពុទ្ធបរិស័ទនឹងសិស្សានុសិស្សរបស់សម្តេច សូមថ្លែងសេចក្តីតជាសច្ចកថា ដើម្បីរំលឹកយកកាតផល នៃការកុសលរបស់សម្តេច ដែលសម្តេចបានធ្វើកន្លងទៅហើយ យកមកពូតផ្គុំផ្សំជាមួយគ្នានឹងផលនៃការកុសលបច្ចុប្បន្ននេះ ប្រគេនចំពោះសម្តេចជាសង្ឃបិតា ក្នុងវេលាដែលសម្តេចមានជរាពាធប្រចាំកាយនេះ ។

បពិត្រសម្តេចជាទីគោរព ! យើងខ្ញុំទាំងឡាយ ទាំងគ្រហស្ថទាំងបព្វជិត ខ្លះជាសិស្សានុសិស្ស ខ្លះជាឧបាសកបំណុះវត្តនេះ ខ្លះជាញាតិមិត្រ មានសេចក្តីស្រឡាញ់នឹងសេចក្តីគោរពដោយពិត ចំពោះសម្តេច ដែលជាឧត្តមបុរសមួយអង្គ ក្នុងប្រទេសកម្ពុជា ព្រោះយើងខ្ញុំដឹងពិតថា សម្តេចប្រកបដោយព្រះគុណទាំងពីរប្រការគឺ ឧបការគុណ ១ នេមិត្តកគុណ ១ ។

ព្រះគុណទី ១ ដែលហៅថាឧបការគុណ គឺសម្តេចប្រកបដោយព្រហ្មវិហារធម៌បានដល់មេត្តា, ករុណា មុទិតា, ឧបេក្ខា ។

យើងខ្ញុំទាំងឡាយ បានសង្កេតឃើញពិតថា សម្តេចមានធម៌ទាំង ៤ ប្រការនេះពេញលេញក្នុងព្រះអង្គមែន ។ ព្រោះកាលដែលសម្តេចទើបនឹងបានឧបសម្បទា សម្តេចបានគ្រប់គ្រងភិក្ខុសង្ឃសាមណេរនៅវត្តស៊ីធរ តាំងពី ព.ស ២៤៩៤ ដរាបមកដល់ឥឡូវនេះក្តី សម្តេចបានគ្រប់គ្រងភិក្ខុសង្ឃសាមណេរក្នុងវត្តលង្កានេះ ដែលមានភិក្ខុសាមណេរដ៏ច្រើនលើសលុបក្តី សេចក្តីរកាំរកូសក្នុងសង្ឃមណ្ឌល ពុំដែលមានដល់ម្តងសោះ ។ សេចក្តីសុខដ៏ធំទូលាយដែលកើតឡើងក្នុងមហាសង្គមយ៉ាងនេះ តាមរឿងក្នុងគម្ពីរថា ប្រាកដជាកើតឡើង ដោយសារព្រហ្ម-វិហារធម៌ នៃប្រមុខរបស់សង្គម ។

ខនេះ បើនិយាយឲ្យចំៗទៅថា កាលដែលវត្តលង្កានៅក្នុងផ្ទៃបឹងដ៏ជ្រៅ មានលំនៅភិក្ខុសង្ឃសុទ្ធតែតូបតូចៗ បន្តិចបន្តួច យើងខ្ញុំទាំងឡាយជាសិស្សក្នុងជំនាន់នោះ បានទទួលសេចក្តីប្រោសប្រណីអំពីសំណាក់សម្តេច គឺសម្តេចបានអនុញ្ញាតឲ្យយើងខ្ញុំគ្រប់គ្នានៅក្នុងទីអាពាមនេះដោយឥតរើសមុខ ថាកូនអ្នកមាន ឬអ្នកក្រ ថាកូនអ្នកក្រុង ឬអ្នកស្រែ-ចំការឡើយ លើកលែងតែមនុស្សដែលជាទីរង្កៀសចេញ ។ សម្តេចបានប្រឹងប្រែងកសាងវត្តនេះ ដើម្បីជាទីលំនៅយើងគ្រប់គ្នា ដោយឥតសំចៃព្រះកាយពល ដរាបដល់វត្តនេះបានប្រាកដជាអាពាមមួយដ៏ធំក្នុងកណ្តាលរាជធានីខ្មែរ ។ សព្វសព្វ កាលសម្តេចបានចែកសង្ឃលាភឲ្យភិក្ខុសាមណេរឥតរើសមុខមិនឲ្យលើសខ្វះ, វេលាជិតចេញវស្សា ក្រោយពេលដែលឲ្យយើងខ្ញុំជាសិស្ស សិក្សាធម្មវិន័យ

ច្រើនខែហើយ សម្តេចតែងចាត់ការឲ្យប្រឡងសាកមើល ដើម្បីប្រមាន ស្បង់ពីការនឹងវត្តផ្សេង ៗ ជារបស់ផ្ទាល់ព្រះអង្គ ទោះយ៉ាងថ្លៃតិចច្រើន ដល់សិស្សដែលប្រឡងជាប់លេខមាបខ្ពស់តាមលំដាប់, រាល់ ៗ ឆ្នាំរៀង មក អស់រយៈកាលជាយូរអង្វែង ។ សម្តេចបានបង្ហាត់បង្រៀនគម្ពីរ បាលី ធម្មវិន័យព្រមទាំងប្រមានទុកទជាប្រក្រតីផ្ទាល់ព្រះអង្គផង ចាត់ ឲ្យអាចារ្យ ៗ ជួយបង្ហាត់បង្រៀនថែមទៀតផង ។

ករណីយកិច្ចដ៏ថ្លៃថ្លាទាំងនេះ ប្រាកដជាផុសចេញអំពីព្រហ្មវិហារ ធម៌ គឺជាព្រោះតែសម្តេចមានព្រហ្មវិហារធម៌ ទើបបំពេញករណីយ- កិច្ចដ៏ប្រសើរទាំងនេះបាន ដែលចាត់ជាឧបការគុណដ៏ធំធេង មកលើយើង ខ្ញុំគ្រប់គ្នា ។

ទី ២– ដែលថាសម្តេចប្រកបដោយនេមិត្តកគុណ គឺគុណដ៏អស្ចារ្យ បានដល់កិត្តិសព្ទ កិត្តិនាមដ៏ល្បីល្បាញ ដែលផុលផុសផុះចេញផ្សាយ ទៅអំពីសមត្ថភាពរបស់សម្តេច ដូចខ្ញុំព្រះករុណារៀបរាប់តទៅ:

ក) កាលសម្តេចទើបនឹងបានឧបសម្បទាបាន ២ ក្នុង ព.ស ២៤៤៣ នោះ សម្តេចព្រះមហាសង្ឃរាជព្រះនាមទៀង បានតាំងសម្តេចជា អាចារ្យបង្ហាត់សូត្រធម៌គាណការបាលី ឲ្យប្រើខ្យល់វិយៈរស្សៈ វែងខ្លី ត្រឹមត្រូវតាមវិធីភាសាបាលី ក៏ព្រោះតែសម្តេចស្ទាត់ជំនាញក្នុងការនេះ ក្រាន់បើជាងគេ ទោះបីឋិតនៅក្នុងបឋមវ័យសោះក្តី ។

ខ) កាលពី ព.ស. ២៤៤៥ សម្តេចព្រះមហាសង្ឃរាជ បានតាំង

សម្ដេចជាចៅអធិការវត្តស៊ីធរ កំព្រោះតែសម្ដេចមានសមត្ថភាពខាងការបង្ហាត់បង្រៀនធម្មវិន័យផង ខាងការគ្រប់គ្រងគណៈសង្ឃផង ។

គ) កាលពី ព.ស. ២៤៥៤ ព្រះករុណាព្រះបាទសម្ដេចព្រះស៊ី-សុវត្ថិ-មុនីវង្ស កាលនៅជាព្រះអង្គម្ចាស់អធិបតីនៅឡើយ បានពិគ្រោះព្រមព្រៀងជាមួយនឹងសម្ដេចព្រះមហាសង្ឃរាជ នឹងព្រះសពព្រះមហាវិមលធម្មថោង បាននិមន្តសម្ដេចពីវត្តស៊ីធរ មកតាំងជាចៅអធិការវត្តលង្កានេះ កំព្រោះតែសម្ដេចមានសមត្ថភាព ហើយបានធ្វើការមានថ្វីព្រះហស្ត តាំងពីទើបនឹងបានឧបសម្បទាថ្មីៗមកម៉្លេះ ។

ឃ) កាលពី ព.ស. ២៤៥៦ សម្ដេចបានសមណស័ក្តិជាព្រះគ្រូវិមលបញ្ញា, កាលពី ព.ស ២៤៥៧ សម្ដេចបានឡើងសមណស័ក្តិជាព្រះញាណបវរវិជ្ជា រាជាគណៈក្នុងតំណែង កំព្រោះតែសម្ដេចមានសមត្ថភាព អាចជ្រោងវត្តលង្កាដែលឋិតនៅក្នុងផ្ទៃបឹងដ៏ជ្រៅ មានសេនាសនៈរេចរោកឲ្យឡើងជាអារាមមួយដ៏រុងរឿង តាំងជាវត្តដែលមានភិក្ខុសាមណេរ បួនប្រាំអង្គឲ្យបានក្លាយទៅជាអារាមមានភិក្ខុសង្ឃគុះករដល់ប្រាំមួយ-ប្រាំពីររយអង្គ ។

ង) កាលពី ព.ស. ២៤៥៨ រាជការបានតាំងសម្ដេចជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ កំព្រោះតែមានសមត្ថភាពខាងការចេះដឹង អាចប្រឡងយកឋានៈនោះបាន ។

ច) កាលពី ព.ស. ២៤៧២ រាជការបានតាំងសម្ដេចជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ហើយតមកបានតាំងជាអធិបតីក្រុមជំនុំព្រះត្រៃ-

បិដកទៀត  ក៏ព្រោះតែសម្តេច  អាចត្រូវការសិក្សាផ្លូវពុទ្ធសាសនាបាន ។

៥) តាំងពីគ្រាណោះដរាបមក  សម្តេចបាននាំផ្តើមប្រែព្រះត្រៃបិ-ដក  បានចាត់ការឲ្យសរសេរចម្លងបាលីព្រះត្រៃបិដក,  បានរួមប្រជុំក្នុងគណៈកម្មការបង្កើតពុទ្ធសាសនបណ្ឌិត្យ, បានផ្តើមបង្កើតសាលាបាលីរងក្នុងសកលកម្ពុជរដ្ឋព្រមទាំងជាគ្រូប្រឹក្សា ក្នុងការបង្កើតពុទ្ធសាសនបណ្ឌិត្យរង និងសាលាបាលីរង  នៅប្រទេសលាវនិងប្រទេសកូសាំងស៊ីនផង, សម្តេចបានទទួលចាត់ការឲ្យបង្ហាត់បង្រៀនពួកសមណនិស្សិតពីប្រទេសលាវនិងប្រទេសកូសាំងស៊ីនផង  ។  ដោយហេតុមានករណីដ៏ប្រសើរទាំងនេះ ទើបសម្តេចបានឡើងសមណសក្តិជាព្រះសិរីសម្មតិវង្ស, ជាព្រះធម្មលិខិត,  ជាសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា  ព្រមទាំងបានគ្រឿងឥស្សរិយយសដ៏ខ្ពង់ខ្ពស់តាំងពីមេដាយ មុនីសារាភ័ណ្ឌ រហូតដល់មេដាយអស្សរិទ្ធក្រមដូណើរ  ដែលបារាំងហៅថា ស៊ីវ៉ាលីយេរដឺឡាឡេស្យុងដូណើរ ។

គុណសម្បត្តិដ៏អស្ចារ្យ  ដែលផុសផុះចេញអំពីសមត្ថភាពយ៉ាងនេះហៅថា នេមិត្តកគុណ ។

សម្តេចប្រកបដោយព្រះគុណទាំងពីរប្រការ  ដូចបានថ្លែងមកហើយនេះ ទើបជាទីស្រឡាញ់ជាទីគោរព នៃយើងខ្ញុំគ្រប់គ្នា ។ បានជាយើងខ្ញុំគ្រប់គ្នា មានសេចក្តីសុតរន្ធត់ក្នុងចិត្តយ៉ាងក្រៃលែង ក្នុងវេលាដែលសម្តេចមានព្រះជរាពាធ  ទើបនាំគ្នាធ្វើបុណ្យកតញ្ញូកតវេទិតាកិច្ច

នេះ បានទិមន្តព្រះសង្ឃចំរើនព្រះបរិត្ត និមន្តជម្រាកចិកសំដែងធម៌ទេសនា ប្រគេនភេសជ្ជៈ ប្រគេនភិក្ខាហារចំពោះព្រះសង្ឃ ដើម្បីយកកាត់ផល ប្រគេនផ្ទាល់ចំពោះសម្តេច ។

មួយទៀត យើងខ្ញុំសូមអំពាវនាវដល់កុសលទាំងឡាយ ដែលសម្តេចបានធ្វើផ្ទាល់ព្រះអង្គ ដូចដែលបានរៀបរាប់មកពីខាងដើម សូមកុសលទាំងនោះផុសផុលឡើងមករួមកម្លាំងជាមួយគ្នា នឹងការកុសលដែលយើងខ្ញុំធ្វើប្រគេនសម្តេចក្នុងគ្រាឥឡូវនេះ សូមអតីតកុសលរបស់សម្តេច នឹងបច្ចុប្បន្នកុសលរបស់យើងខ្ញុំផ្គុំកម្លាំងគ្នាគាំពារសម្តេច កុំឲ្យមានទុក្ខវេទនា, សូមកុសលទាំងនោះក្លាយមកជាឱសថទិព្វ ស្រោចស្រប់រម្ងាប់រោគ ក្នុងព្រះកាយសម្តេចឲ្យបានសម្រេចជាសះស្បើយយ៉ាងឆាប់ៗ សូមសម្តេចប្រកបដោយព្រះជន្មាយុយឺនយូរវែងឆ្ងាយ ដើម្បីជាទីគោរពនៃយើងខ្ញុំទាំងឡាយអស់កាលជាអង្វែងតរៀងទៅ ។

*

* *

## សំពែងប្រាស

របស់ព្រះពុទ្ធង្ឃ កៅ - ស៊ីម សាស្ត្រាចារ្យ

នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត តំណាងសម្តេចថ្លែងគបពួកសិស្សនឹងពុទ្ធបរិស័ទ

សូមនមស្ការ

— សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក វត្តឧណ្ណាលោម,

— ព្រះតេជព្រះគុណ ព្រះពោធិវ័ង្សចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត,

– ព្រះតេជព្រះគុណ ព្រះសុធម្មាធិបតីស្ថិតសង្ឃនាយក វត្តបទុមវតី,

– – ព្រះអរិយកស្សប

– – ព្រះមុនីកោសល

– – ព្រះឃោសធម្មទីងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ,

សូមអភ័យទោស ដោយខ្ញុំព្រះករុណាពុំបានចេញព្រះនាមសព្វគ្រប់ ។

សូមទានមេត្តាប្រោស, ខ្ញុំព្រះករុណាសូមថ្លែងសំនេតប្បកាសដូចមានសេចក្តីតទៅនេះ :

សូមប្រកាសជូនដំណឹង ចំពោះក្រុមសិស្សានុសិស្សទាំងបព្វជិតទាំងគ្រហស្ថទាំងអស់លោក-អ្នក ឧបាសក ឧបាសិកា ដែលបានទិមន្តអញ្ជើញមកធ្វើបុណ្យកតញ្ញូកតវេទិតាកុងទីនេះប្រគេនចំពោះសម្តេច...

សូមជ្រាប ។

ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរគុណចំពោះអស់លោក-អ្នកជាជំនួសសម្តេចតាមសំនេតប្បកាសជាអនុស្សរណីយកថា របស់សម្តេចដែលមានសេចក្តីដូចតទៅនេះ :

អស់លោក-អ្នក បព្វជិត-គ្រហស្ថទាំងឡាយ !

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទ្រង់ផ្ទុនសំដែងធម៌ទេសនាណែនាំបំភ្លឺប្រជានិករឲ្យយល់ច្បាស់នូវទុក្ខធម៌ ដែលជាសភាវៈពិតសភាវៈទៀងទាត់ សភាវៈមិនប្រែប្រួលទៅជាដទៃ ដែលធ្លាក់ចំមកលើរូបប្រជានិករគ្រប់ឋានៈជាអ្នកទទួលរង ហើយទ្រង់បានប្រាប់អំពីលក្ខណៈជាគ្រឿងកំណត់កត់សំគាល់របស់រូប ដែលមានព្រឹត្តិការណ៍គួរដល់ការ

បាក់បែកទ្រុឌទ្រោមវិនាសទៅដោយរុប្បនលក្ខណៈ មានក្តៅនិងត្រជាក់ ណាប់ជាដើម ព្រោះថារូបនេះជាសម្បុកនៃរោគ ដែលចូលទៅជ្រកកោនទៅអាស្រ័យជាបច្ច័យញាំញីជីវភាពរបស់រូបនោះ ឲ្យទន់ខ្សោយថយចុះតាមលំដាប់ថ្ងៃខែឆ្នាំ ទៅទល់នឹងវិនាស ។ កាលបើរូបនេះជាទុព្វលហើយ ប្រយុទ្ធតស៊ូនឹងរោគមិនឈ្នះហើយ សកម្មភាពរបស់រូបនោះនឹងប្រព្រឹត្តទៅដូចម្តេចហ្ន៎ ! គួរបាត់ទៅតាមផ្លូវណា ? អើ ! បើដូច្នេះ ! រូបដែលមានរោគធ្វើឲ្យឈឺចាប់នេះ គួរបាត់កន្លងរូបសភាពក្រ ដូចមនុស្សក្រទ្រព្យសម្បត្តិនោះដែរ ។ ម៉េចក៏បាត់ជាសភាពក្រ ? ព្រោះថារោគៈនោះវាបំផ្លាញជីវភាពដែលជាដួងព្រលឹងរបស់មនុស្ស ដែលកំពុងតែរស់នៅដោយសេចក្តីសុខសប្បាយ វាធ្វើឲ្យអន្តរាយហិនហោចបាត់បង់ការមានការបានរបស់ជីវភាព ដែលជាសុខស្រួលរស់នៅនោះ ត្រឡប់ត្រឡិនបង្វែងជាទទៀខានបានលែងមានអ្វីតទៅមុខទៀត ធ្លាក់ទៅជាសភាពក្រមិនងាយនឹងមានជីវភាពរស់នៅស្រួលនោះទេ ។ នេះហើយហៅថាទុក្ខធម៌ មិនប្រែប្រួលទៅតាមសភាពដទៃ, ដល់ម្ល៉ឹងតើ ! គួរឲ្យនឹកស្តាយដល់ជីវភាពរបស់ប្រជាជនប្រុសស្រី ដែលតែងតែស្រឡាញ់ស្នេហាប្រាថ្នាចង់បានសុខភាព រស់នៅអស់កាលយូរតអង្វែងទៅ តែពុំសូវបានកបសោះបែរជាទុក្ខធម៌គ្រលុកអុកនៅជាប់ស្អិតក្នុងសន្តានយើងទាំងអស់គ្នា ។ ព្រះពុទ្ធដីកាត្រាស់ថា "បើរូបនេះជាអត្តាខ្លួនប្រាណមែន. រូបនេះមិនប្រព្រឹត្តទៅដើម្បីជម្ងឺអាពាធទេ ព្រោះ

រូបនេះមិនមែនអត្តាហើយបានជាក៏ចាប់ស្លាប់វិញ គឺរូបនេះជាអនត្តាមិនមែនខ្លួនយើងបានជាជម្ងឺមេរោគចូលជ្រលុកទៅពេញក្នុងរូបនេះកើត ។

ប្រកាសសេចក្តីប៉ុណ្ណេះ ដើម្បីស្រាលសេចក្តីទុក្ខព្រួយក្រុមសិស្សានុសិស្ស ព្រមទាំងអស់លោក-អ្នកសប្បុរសទាំងឡាយ ដែលមានសន្តានចិត្តមេត្រីភាពចំពោះខ្ញុំករុណាអាត្មា ហើយបានព្រួតដៃគ្នាតយុទ្ធប្រយុទ្ធនឹងរោគនេះ ដោយឱសថយ៉ាងជំទាញ ។ ផ្តាលផ្តាញ់រោគនេះឲ្យអន់ទន់កម្លាំងរោគថយក្រោយដោយអំណាចការព្យាបាល ទាល់តែរោគនេះសាយដៃធ្វើអត្តភាពខ្ញុំករុណាអាត្មា ឲ្យបានស្រួលបន្តិចនេះឡើង ។

លោក-អ្នក បព្វជិត គ្រហស្ថទាំងឡាយ!

កាល ព.ស. ២៤៩៧ គ.ស. ១៩៥៣ កន្លងទៅហើយ ជាកាលកំណើតរោគ ដែលចាប់កើតជាលើកដំបូងក្នុងរាងកាយរបស់ខ្ញុំករុណាអាត្មា សំដែងអាការកំឡោហួសហេតុ បានបញ្ចេញកំណាចកាចឃោរឃៅដូចអាសិរពិស ចាប់ឈឺតើតចាក់រុករាលដាលក្នុងកាយនេះស្ទើរតែអត់ទ្រាំពុំបាន តែបានដោយអំណាចតេជានុភាពសម្តេចព្រះមហាក្សត្រិយានី មានព្រះសវណ្ណីយ៍បញ្ជាឲ្យលោកអ្នកឧកញ៉ាវិសុទ្ធពេទ្យ អ៊ុន-អេម មកព្យាបាលជាលើកដំបូងប្រឆាំងទប់ទល់នឹងរោគនេះជារាល់ថ្ងៃ បន្ទាប់មកបានយកលោកវេជ្ជបណ្ឌិត ផ្លាស៊ី មកប្រយុទ្ធនឹងរោគនេះទៀត ក៏បានគ្រាន់បើរហូតមកដល់ ព.ស. ២៤៩៩ គ.ស. ១៩៥៦ រោគនេះក៏រើឡើងជាថ្មីវិញ, បានយកលោកវេជ្ជបណ្ឌិត ជួន.ជឿន នឹងលោក លាង-ហាន ពេទ្យនាយកមកព្យាបាលប្រយុទ្ធ

ទីឯកេតដែលនេះថែមទៀត ទាល់តែកេតនេះសាបរលាបខ្យាយកំលាំងទៅ នាំឲ្យខ្ញុំករុណាអាត្មាមានខ្យល់អស្សាសប្បស្សាសៈផូរស្រួលឡើងជាដរាប ។

ឱកាសនេះអស់លោក - អ្នកដែលជាគ្រូបព្វជិត ឧបាសកឧបាសិកាទាំងឡាយ ដែលមានសេចក្ដីស្នេហាចំពោះខ្ញុំករុណាអាត្មា បានមូលមតិគ្នាមកធ្វើបុណ្យកតញ្ញូតាដើម្បីឧទ្ទិសតបបដិការគុណ ចំពោះខ្ញុំករុណាអាត្មា ៗ មានអំណរណាស់ សូមទទួលយកកុសលនេះដោយសេចក្ដីពេញចិត្ត ។ ដោយអំណាចបុណ្យកតញ្ញូតានេះ សូមកុសលនេះជួយឧបត្ថម្ភជាកម្លាំងបណ្ដេញរោគាពាធ ដែលមានក្នុងអង្គកាយរបស់ខ្ញុំករុណាអាត្មាឲ្យរលាយបាត់ខ្ចាត់ខ្ចាយចេញពីសរីរៈតាំងពីថ្ងៃនោះតទៅ ។

បន្ទាប់អំពីនេះ ខ្ញុំករុណាអាត្មា សូមលើកកុសលដែលកើតអំពីបុណ្យកតញ្ញូតា របស់អស់លោក-អ្នក ដែលបានប្រគេនខ្ញុំករុណាអាត្មានេះ ថ្វាយជាព្រះរាជពលីចំពោះព្រះករុណាជាម្ចាស់ជីវិត, សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះឧបយុវរាជ សូមទ្រង់ឋិតនៅក្នុងសិរីរាជសម្បត្តិ និងសូមទ្រង់ប្រកបដោយសុខសួស្ដីជ័យមង្គលគ្រប់ប្រការអស់កាលជាអង្វែងតទៅ ។

សូមឧទ្ទិសភាគផលនេះ ជូនចំពោះទេវតានិងមនុស្សទាំងឡាយ ព្រមទាំងសត្វទាំងពួង សូមទទួលយកដោយសញ្ញា ហើយ សូមឲ្យមានអាយុយឺនយូរអស់កាលជាដ៏ឡូង ។

សូមឧទ្ទិសភាគផលនេះ ជូនចំពោះគ្រូសិស្សានុសិស្ស បព្វជិត គ្រហស្ថ ឧបាសក ឧបាសិកាទាំងឡាយ ដែលជាអ្នកខ្វល់ខ្វាយធ្វើបុណ្យកតញ្ញូតាផ្ដល់ជូនដូនចំពោះខ្ញុំករុណាអាត្មា ដែលជាគ្រូឧបជ្ឈាយរបស់អស់លោក-អ្នក សូមលោក-អ្នកទាំងនេះបានមូលមិត្តសំឡាញ់មូលគ្រូមគ្រួសារ កុំឲ្យបែកបាក់ចាកគ្នា កុំឲ្យមានរោគាបៀតបៀន សូមឲ្យប្រាសចាកទុក្ខភ័យឧបទ្រពចង្រៃគ្រប់យ៉ាង សូមឲ្យបានប្រកបដោយសេចក្ដីសុខ ចំរើន អាយុយឺនយូរ សូមឲ្យមានសាមគ្គីស្មោះស្ម័គ្រនឹងគ្នា កុំមានពៀរវេរាទីងគ្នាអស់កាលជានិរន្តរ៍ សូមឲ្យចំរើនក្នុងព្រះពុទ្ធសាសនាតរៀងទៅកុំបើឃ្លាតឡើយ ។

ទីបំផុតនៃសំរេចប្រកាសរបស់សម្ដេចនេះ ខ្ញុំព្រះករុណាអាត្មាភាព សូមបួងសួងប្រកបដោយមេត្តាករុណាចិត្តចំពោះសម្ដេចផង ចំពោះពុទ្ធបរិស័ទទាំងអស់ផង ជាគាថាបាលីដោយសង្ខេបថា:

អម្ហាកំ សម្ដេចព្រះធម្មលិខិត ឧត្តមប្រឹក្សា មហាថេរស្ស ពោគា តត្ថ ឆាឆាពាធកិលាឆាយ វិហេឋយន្តា អម្ហាកំ កតញ្ញូតានុភាវេន តេតា បង្ហាយ មា អហេសុំ វិនស្សន្តុ អសេសតោ ។

ពុទ្ធវិញ្ញ ឆាម អហាម្បន សព្វស្មំ លង្កាភមេ វិសន្តានំ ភិក្ខុសាមណោភានំ ឧបាសកឧបាសិកានញ្ច សាមគ្គិករណត្ថាយ

ឥទំ វិបនមព្រឹ សព្វេ តុម្ហេ មហាបុញ្ញា មហាបញ្ញា មហាពលា មហាភោគា មហាយសា មហានុភាវា សព្វធម្មេសុ ឋិតា សព្វធរា ពុទ្ធសាសនមាមកា សីលវន្តោ ជនានម្ហិយា សមគ្គា ហោថ សព្វេ តុម្ហេ អញ្ញមញ្ញាវិរោធិនោ, ឥទំ សព្វំ លង្កាភាមំ នាម អញ្ញំ អទុំ ឯវ មា វិសុំ ហោតុ មេត្តាយោគ្គេកសម្ពន្ធំ សុខំ ឋិរន្តិ ។

តេ តេ ភិក្ខុសាមណេរាទយោ អវិវាទា អវិកលហា អភិន្នា សម្មា សមគ្គា សាធុកំ សម្បដិច្ឆិត្វា ពុទ្ធសាសនំ ធម្មវិនយសម្បន្នំ រក្ខន្តុ, ចិរំ តិដ្ឋន្តុ សកសកអារាមេសុ ច សកសកាចរិយគណេសុ ច សកសកគេហដ្ឋានេសុ ច សុវត្ថិភាវេន សព្វទា ។

ព្រះមហាឧត្តមវិជ្ជា សម - សុខ ប្រែសំរួលជាភាសាខ្មែរ:

"សូមពេលដែលកំពុងបៀតបៀនដោយធម្មជំកាត់ផ្សេងៗ ក្នុងរដ្ឋកាលសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ជាមហាថេរយើង ជាសះស្បើយ តាំងពីថ្ងៃនេះទៅ ដោយអានុភាពនៃកតញ្ញុតាធម៌យើងរាល់គ្នា, ពេលទាំងនោះ ចូរនោសលាញទៅ កុំបីសេសសល់ឡើយ ។

ខ្ញុំឈ្មោះពុទ្ធវង្ស 'កាំ - ស៊ឹម ចង់ធ្វើសាមគ្គីធម៌រវាងពួកភិក្ខុសាមណេរ ដែលនៅក្នុងវត្តលង្កាទាំងមូល និងឧបាសកឧបាសិកាទាំងឡាយ (ឲ្យកើត

មាន ) ទើបពោលពាក្យនេះថា ៖ អស់លោកទាំងឡាយ ជាអ្នកមានបុណ្យច្រើន មានបញ្ញាច្រើន មានកម្លាំងច្រើន មានភោគៈច្រើន មានយសច្រើន មានអានុភាពច្រើន សូមឋិតនៅក្នុងសច្ចធម៌ ទ្រទ្រង់សច្ចៈ ការពារព្រះពុទ្ធសាសនា មានសីលជាទីស្រឡាញ់នៃប្រជាជន មានសេចក្ដីព្រមព្រៀងគ្នា, សូមអស់លោកកុំមានការក្រោធខឹងដល់គ្នានឹងគ្នា; ចិត្តលោកទាំងនេះ ទោះឯណោះក្ដី ឯណោះក្ដី កុំបីបែកបាក់គ្នាឡើយ; សូមសេចក្ដីសុខដែលជាប់ទាក់ទងដោយចង្កោមមេត្តាធម៌ ( ឋិតនៅ ) អស់កាលដ៏យូរ ។

ពួកភិក្ខុសាមណេរជាដើមនោះៗ កុំទាស់ឈ្លោះបែកបាក់គ្នា ជាអ្នកមានសាមគ្គីធម៌ដោយប្រពៃ ចូរព្រមទទួលថាសាធុ ហើយរក្សាព្រះពុទ្ធសាសនាដែលបរិបូណ៌ដោយធម៌វិន័យចុះ; សូមសហធម្មិកៈទាំងឡាយ ឋិតនៅដោយភាពជាអ្នកមានសេរីសួស្ដីអស់កាលដ៏យូរលង់ក្នុងអាវាសរៀងៗខ្លួន, ក្នុងត្រកូលអាចារ្យរៀងៗខ្លួន និងក្នុងគេហដ្ឋានរៀងៗខ្លួន សព្វកាលសព្វវេលា ។

•

*   *

## សង្កថា

## របស់លោកយោក្សត្រ ម៉ម-យ៉ែម

ថ្ងៃនេះ ជាតិថីមានបុណ្យ សន្មតថាជាអតិលក្ខិតសម័យដ៏ប្រសើរ ដែលព្រះតេជព្រះគុណនិងអស់លោក-អ្នកទាំងឡាយ បានអញ្ជើញមក

ជួយអបអរបុណ្យកតញ្ញូតាចំពោះសម្ដេច ជាគ្រូនៃយើងរាល់គ្នាក្នុងពេលនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការអញ្ជើញមកនៃព្រះតេជព្រះគុណ និងអស់លោកទាំងឡាយ ។ យើងទាំងអស់គ្នាដឹងហើយថា “សង្ខារៈក្នុងលោកសន្និវាសទាំងមូល តែងតែវិនាសទៅវិញជាធម្មតា គ្មានសង្ខារៈណាដែលមានឥទ្ធិពលមកជំទាស់កាំងតតាំងនឹងវិបរិណាមធម៌បានឡើយ តែយើងបានដឹងទៀតថា “គុណធម៌អាចជួយបង្កើនអាយុសព្វសត្វឲ្យចំរើនបានដោយអន្លើ ព្រោះហេតុនោះ ទើបយើងរាល់គ្នារួមគំនិតធ្វើបុណ្យកតញ្ញូតានេះឡើង ជាកិច្ចតបឧបការគុណផង ជាកិច្ចនៃអាយុវឌ្ឍនមង្គលផង ចំពោះសម្ដេចជាគ្រូនៃយើងរាល់គ្នា” ។

បពិត្រសម្ដេចជាទីគោរព!

ឧបការគុណដ៏ធ្ងន់របស់សម្ដេច ដែលផ្សាយមកគ្របដណ្ដប់យើងខ្ញុំរាល់គ្នាដោយព្រះទ័យប្រោសប្រាណជាពន់ពេកនោះ យើងខ្ញុំគ្មានអ្វីតបឲ្យសមគួរទេ ក្រៅពីកុសលធម៌ចេញ ដូច្នេះ យើងខ្ញុំព្រះករុណាទាំងឡាយ សូមបង្អោនកាយវាចាចិត្ត លើកករប្រណម្យផ្គងលើសិរសាទ្រកុសលទាំងនេះប្រគេនចំពោះសម្ដេច, សូមសម្ដេចជាម្ចាស់មេត្តាប្រោសអនុគ្រោះទទួលយកកុសលដែលសិស្សគណឧទ្ទិសប្រគេននេះ ដោយព្រះទ័យដ៏សោមនស្សចុះ ។

ដោយតេជានុភាពនៃកុសលចរិយាដែលកើតពីដួងចិត្តដ៏បរិសុទ្ធរបស់

យើងរាល់គ្នានេះ សូមសម្ដេចបានសះស្បើយចាកព្រះរោគាពាធ ដែលមានក្នុងព្រះករជ្ជកាយសព្វថ្ងៃ ជាបន្ទាន់ឆាប់រួសរាន់តាមពាក្យបន់ស្រន់នៃយើងខ្ញុំនេះ, សូមសម្ដេចមានព្រះជន្មាយុជាងរយវស្សា គ្រាន់ជាម្លប់ជាទីជ្រកកោននៃយើងខ្ញុំព្រះករុណាទាំងឡាយ ។

ម្យ៉ាងទៀត យើងសូមឧទ្ទិសកុសលនេះ ដល់សត្តក្នុងភាជនលោក សូមឱ្យមានបុញ្ញភាគីស្មើៗគ្នា កុំបីឃ្លៀងឃ្លាត!

អស់លោកជាកល្យាណមិត្ត ជាសិស្សគណ, ជាឧបាសកឧបាសិកាទាំងឡាយ! សូមឱ្យលោកបានប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត តាំងពីបច្ចុប្បន្ននេះ រហូតដល់អវសានជាតិ គឺព្រះនិព្វានកុំបីឃ្លាត ។